# អដ្ឋកថា ព្រះសុត្តន្តបិដក

## សារត្ថប្បកាសិនី

## នវមភាគ

## ភាគ ៣៧

ពុទ្ធសករាជ ២៥៥៦

# អដ្ឋកថា ព្រះសុត្តន្តបិដក

## សំយុត្តនិកាយ

ឈ្មោះ

## សារត្ថប្បកាសិនី

## ភាគ ៣៧

## មហាវារវគ្គ នវមភាគ

ពុទ្ធសករាជ ២៥៥៦

អធិប្បាយ

មគ្គសំយុត្ត និងពោជ្ឈង្គសំយុត្ត មាន ២០ វគ្គ

ព្រះអដ្ឋកថាកែសេចក្តី ៦៧ សូត្រ

# ស្រៈនិស្ស័យ

# *Signes et accents:*



# ស្រៈពេញតួ
# *Voyelles.*

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ខ្មែរ<br>Cambodgien | អ | អា | ឥ | ឦ | ឧ | ឩ | ឯ | ឱ |
| ឡូម<br>Romain | *a* | *.ā* | *i* | *i* | *u* | *ū* | *e* | *o* |
| សៀម<br>Siamois | อ | อา | อิ | อี | อุ | อู | เอ | โอ |
| លាវ<br>Laotien | ᩋ | ᩋᩣ | ᩍ | ᩎ | ᩏ | ᩐ | ᩑ | ᩒ |
| លង្កា<br>Cinghalais | අ | ආ | ඉ | ඊ | උ | ඌ | එ | ඔ |
| ភូមា<br>Birman | အ | အာ | ဣ | ဤ | ဥ | ဦ | ဧ | ဩ |

# ព្យញ្ជនៈ
## Consonnes:

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ក្ក | ខ្ខ | គ្គ | ឃ្ឃ | ង្ង |
| រ៉ូម Romain | *k* | *kh* | *g* | *gh* | *ṅ* |
| សៀម Siamois | ก | ข | ค | ฆ | ง |
| លាវ Laotien | ກ | ຂ | ຄ | ຆ | ງ |
| លង្កា Cinghalais | ක | ඛ | ග | ඝ | ඞ |
| ភូមា Birman | က | ခ | ဂ | ဃ | င |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ<br>Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រ៉ូម<br>Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម<br>Siamois | จ | ฉ | ช | ฌ | ญ |
| លាវ<br>Laotien | ຈ | ສ | ຊ | ຌ | ຍ |
| លង្កា<br>Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា<br>Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຊ | ຍ |
| សិង្ហ Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រ៉ូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຍ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រ៉ូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຍ |
| សិង្ហ Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| ឡូម Romain | c | ch | j | jh | ñ |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | [illegible] | ຍ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រ៉ូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ຉ | ຊ | ຌ | ຎ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

## ពាក្យផ្ដើម

ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ជាសាសនធម៌ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់មានអង្គ ៩ គឺ ៖

**សុត្ត** បានដល់ ឧភតោវិភង្គ និទ្ទេសៈ ខន្ធកៈ បរិវារៈ ព្រះសូត្រផ្សេង ៗ មានមង្គលសូត្រជាដើម ។

**គេយ្យ** បានដល់ ព្រះសូត្រដែលប្រកបដោយគាថាទាំងអស់ ។

**វេយ្យាករណ** គឺ ព្រះអភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមានគាថា និងពុទ្ធវចនៈដែលមិនបានចាត់ចូលក្នុងអង្គ ៨ ឈ្មោះថា វេយ្យាករណៈទាំងអស់ ។

**គាថា** គឺ ព្រះធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធ ៗ ដែលមិនមានឈ្មោះ ពោលដល់ ព្រះសូត្រក្នុងសុត្តនិបាត ។

**ឧទាន** គឺ ព្រះសូត្រ ៨២ សូត្រ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្ដែងដោយសោមនស្សញ្ញាណ ។

**ឥតិវុត្តក** គឺ ព្រះសូត្រ ១១០ សូត្រ ដែលផ្ដើមឡើងដោយពាក្យថា សេចក្ដីនេះ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុក ។

**ជាតក** គឺ ជាការសម្ដែងរឿងក្នុងអតីតជាតិរបស់ព្រះពុទ្ធជាម្ចាស់ មានអបណ្ណជាតកជាដើម មានទាំងអស់ ៥៥០ រឿង ។

**អព្ភុតធម៌** គឺ ព្រះសូត្រដែលបដិសំយុត្តដោយអច្ឆរិយព្ភុតធម៌ទាំងអស់ ។

**វេទល្ល** គឺ លំដាប់ពាក្យដែលអ្នកសួរបានយល់ច្បាស ព្រមទាំងបានទូវសេចក្ដី

វិកកាយ និងសួរជាបន្ត ៗ ទៅ ។

ព្រះពុទ្ធវចនៈទាំងឡាយនេះ ដោយសភាវធម៌ គឺ ជាសច្ចធម៌ដែលទ្រង់ត្រាស់សម្តែងថា ៖

> ជាធម៌ដ៏ជ្រាលជ្រៅ ដឹងបានដោយលំបាក ដឹងតាម
> ឃើញតាមបានដោយលំបាក ស្ងប់ ប្រណីត ល្អិត
> មិនអាចដឹងបានដោយការត្រិះរិះ ប៉ុន្តែជាធម៌ដែល
> បណ្ឌិតគប្បីដឹងបាន ។

ព្រោះសភាវៈនៃធម៌មានលក្ខណៈដូចពោលមកហើយនេះ ទើបត្រូវធ្វើឲ្យជាក់ច្បាស់ ឲ្យកើតការយល់ចូលចិត្តទាំងអត្ថ និងព្យញ្ជនៈ ដើម្បីញ៉ាំងការយល់ដឹងនូវធម៌ទាំងឡាយតាមសេចក្តីពិតក្នុងរឿងនោះ ៗ ។

ស្របតាមអធ្យាស្រ័យផ្សេងគ្នា របស់មនុស្សផ្សេងគ្នា ក្នុងទីកន្លែងផ្សេង ៗ ដែលទ្រង់ឧបមាទុកដូចជាផ្កាឈូក ៤ ពួក ព្រះពុទ្ធជាម្ចាស់ព្រះអង្គឈ្លាសក្នុងវិធីសម្តែងព្រះធម៌ តាមការបង្រៀនព្រះធម៌របស់ព្រះមានព្រះភាគមាន ៣ ប្រការ គឺ ៖

១ ទ្រង់បង្រៀនឲ្យយល់ដឹងដ៏ក្រៃលែង ឃើញពិតក្នុងវត្ថុដែលគួរដឹង គួរឃើញ ។

២ ទ្រង់សម្តែងធម៌មានហេតុផល ដែលអ្នកស្តាប់អាចពិចារណាឃើញតាមសេចក្តីពិតបាន ។

៣ ទ្រង់សម្ដែងធម៌ដ៏អស្ចារ្យ គឺ អ្នកប្រតិបត្តិតាមនឹងបានទទួលនូវប្រយោជន៍សមគួរដល់ការប្រព្រឹត្តប្រតិបត្តិ ។

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ប្រកបដោយបាដិហារ្យ ទ្រង់ឆ្លាតក្នុងវោហារ ព្រោះទ្រង់ជាម្ចាស់នៃព្រះធម៌ មុននឹងទ្រង់សម្ដែងនូវព្រះធម៌ដល់បុគ្គលណា ទ្រង់បានពិចារណាមើលនូវឧបនិស្ស័យរបស់បុគ្គលនោះ ដោយព្រះញាណ ទ្រង់ជ្រាបថា ការបានស្ដាប់នូវពុទ្ធោវាទ តែងនាំមកនូវប្រយោជន៍ ទើបទ្រង់សម្ដែង ។

ក្រោយពីព្រះមានព្រះភាគជាម្ចាស់ ទ្រង់បរិនិព្វានទៅ ទ្រង់បានតាំងព្រះធម៌-វិន័យទុកជាសាស្ដាជំនួសព្រះអង្គ ។ តែការមិនមានសតិបញ្ញាបារមី ការយល់ខុសក្នុងធម៌របស់បុគ្គលនោះ បានធ្វើការអធិប្បាយសេចក្ដីនៃព្រះធម៌វិន័យ តាមការយល់ឃើញរបស់ខ្លួនឯង ជាហេតុធ្វើឲ្យមានការបដិបត្តិផ្សេង ៗ គ្នា មានសីល និងទិដ្ឋិផ្សេង ៗ គ្នា រហូតមាននិកាយដល់ទៅ ១៨ ។

ព្រះអដ្ឋកថាចារ្យ ជ្រាបពុទ្ធាធិប្បាយទាំងដោយអត្ថ និងព្យញ្ជនៈនៃព្រះពុទ្ធ-វចនៈ ព្រោះការសិក្សាចាំស្ទាត់តគ្នាមកតាមលំដាប់ មានឆន្ទៈ និងឧស្សាហៈដ៏ខ្លាំងក្លា បានអធិប្បាយព្រះពុទ្ធវចនៈក្នុងព្រះត្រៃបិដក នូវសេចក្ដីដែលលំបាកយល់ឲ្យកើតការងាយយល់សម្រាប់អ្នកសិក្សា និងបដិបត្តិ ទើបសេចក្ដីសំខាន់នៃគម្ពីរក្នុងព្រះពុទ្ធសាសនា ខាងក្រោយតគ្នារហូតមក មាន ៖

១ ព្រះសូត្រ គឺ ព្រះពុទ្ធវចនៈ ដែលហៅថា ព្រះត្រៃបិដក ទាំងព្រះវិនយ-បិដក ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក ។

២ សុត្តានុលោម គឺ គម្ពីរដែលព្រះអដ្ឋកថាចារ្យរចនាឡើង អធិប្បាយ

សេចក្តីដែលលំបាកក្នុងព្រះត្រៃបិដក ។

៣ **អាចរិយវាទ** វាទៈរបស់អាចារ្យផ្សេង ៗ តាំងអំពីថ្នាក់ដីកា អនុដីកា និង បុញ្ញាចារ្យជំនាន់ក្រោយ ៗ ។

៤ **អត្តនោមតិ** ការគិតឃើញរបស់អ្នកនិយាយ អ្នកសម្តែងធម៌ក្នុងព្រះពុទ្ធ-សាសនា ។

ក្នុងកាលតមក មានការអធិប្បាយធម៌ប្រភេទអាចរិយវាទ គឺ កាន់តាម អាចារ្យរបស់ខ្លួន ទូន្មានទុកជាមួយអត្តនោមតិ ទៅតាមមតិរបស់ខ្លួនឯង ដោយ ច្រើនទាំងនេះអាចនឹងមាន ព្រោះគម្ពីរព្រះពុទ្ធសាសនា ដែលមានគោលសំខាន់ គឺ ព្រះត្រៃបិដក និងអដ្ឋកថាមិនទាន់បានប្រែ អដ្ឋកថាចំណែកច្រើននៅជាភាសាបាលី បុគ្គលដែលមានឆន្ទៈក្នុងភាសាបាលីតិចតួច សំនួនភាសាបាលីដែលប្រែចេញមក ហើយ លំបាកដល់ការយល់របស់អ្នកដែលមិនបានសិក្សាភាសាបាលីជាមុន ព្រោះ ខ្វះកល្យាណមិត្ត ខ្វះសប្បុរស ដែលមានការចេះដឹង ក្នុងព្រះពុទ្ធសាសនាជាដើម ។

ការអធិប្បាយធម៌ ដែលជាផលនៃការត្រាស់ដឹងរបស់ព្រះអរហន្តសម្មា-សម្ពុទ្ធជាម្ចាស់មានអន្តរាយច្រើន ព្រោះនឹងមានឱកាសដែលយល់ខុស និយាយ ខុស បដិបត្តិខុស ។ ព្រះត្រៃបិដកប្រៀបដូចជារដ្ឋធម្មនុញ្ញ ច្បាប់ទូទៅនឹងជំទាស់ ដល់ច្បាប់រដ្ឋធម្មនុញ្ញមិនបាន យ៉ាងណា ការអធិប្បាយធម៌ជំទាស់នឹងព្រះត្រៃបិដក ពុទ្ធសាសនិកជនដែលល្អប្រកាន់ថាធ្វើមិនបានដូចគ្នា ដូច្នោះ ។

សូមអានុភាពនៃព្រះរតនត្រ័យ ប្រតិស្ឋានក្នុងហឫទ័យ

របស់ពុទ្ធសាសនិកជនទាំងឡាយ សូមបានជួបប្រសព្វ
សេចក្តីចម្រើនក្នុងព្រះធម៌ ដែលព្រះមានព្រះភាគទ្រង់
ប្រកាសទុកល្អហើយបរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ ។

ក្រុមរៀបរៀងព្រះអដ្ឋកថា

# និទានកថា

សេចក្តីសង្ខេបថា ក្នុងទីបំផុតនៃការសម្តែងយមកប្បាដិហារ្យ ព្រះមានព្រះ-ភាគជាម្ចាស់ ស្តេចចូលចាំវស្សានៅលើផ្ទាំងបណ្ឌុកម្ពលសិលាសនៈ ក្រោមដើមបារិច្ឆត្តកព្រឹក្សក្នុងទេវនគរ ទ្រង់ធ្វើព្រះមាតាឲ្យជាអង្គសាក្សី ត្រាស់ព្រះអភិធម្ម-កថាដល់ទេវបរិស័ទ លុះទ្រង់សម្តែងបករណ៍ធម្មសង្គណីបាន ១០០ ឆ្នាំកន្លងទៅពួកភិក្ខុវជ្ជីបុត្រសម្តែងវត្ថុ ១០ ប្រការ ដែលប្រាសចាកព្រះធម៌វិន័យ គឺ ៖

១ ភិក្ខុទុកដាក់អំបិលក្នុងក្លាក់សម្រាប់ឆាន់ជាមួយអាហារថា គួរ ។

២ ភិក្ខុឆាន់អាហារពេលព្រះអាទិត្យជ្រេទៅ ២ ធ្នាប់ គួរ ។

៣ ភិក្ខុហាមភត្តហើយ ចូលទៅក្នុងចន្លោះស្រុក ហើយឆាន់ភត្តដែលមិនបានធ្វើវិនយកម្មមុន ឬ មិនជាដែនរបស់ភិក្ខុឈឺ គួរ ។

៤ ភិក្ខុនៅក្នុងអាវាសជាមួយគ្នា បំបែកគ្នាធ្វើសង្ឃកម្ម គួរ ។

៥ ភិក្ខុធ្វើឧបោសថកម្មមិនរង់ចាំឆន្ទានុមតិ គួរ ។

៦ ប្រការបដិបត្តិដែលឧបជ្ឈាយ៍ អាចារ្យធ្លាប់ប្រព្រឹត្តមកខុសត្រូវ យ៉ាងណាប្រព្រឹត្តតាម គួរ ។

៧ ភិក្ខុហាមភត្តហើយ ឆាន់ទឹកដោះស្រស់ដែលមិនទាន់ប្រែជាទឹកដោះជូរគួរ ។

៨ ភិក្ខុផឹកស្រាខ្សោយ ៗ គួរ ។

៩ ភិក្ខុក្រាលសំពត់និសីទនៈដែលមិនមានជាយ គួរ ។

១០ ភិក្ខុទទួល ឬត្រេកអរចំពោះមាស និងប្រាក់ ដែលគេទុកដាក់ដើម្បីខ្លួន គួរ ។

ព្រះយសត្ថេរដែលជាបុត្ររបស់ព្រាហ្មណ៍ ឈ្មោះថា កាកណ្ឌកៈ បានស្ដាប់វត្ថុ ១០ ប្រការនោះហើយបានកាន់យកព្រះចៅអសោករាជដែលជា ព្រះឱរសរបស់ ព្រះចៅសុសុនាគៈធ្វើជាសម្ពាញ់ ហើយជ្រើសរើសព្រះថេរៈ ៧០០ អង្គក្នុងចំណោម ភិក្ខុ ១.២០០.០០០ អង្គ គឺ ( ដប់ពីរសែន ) ញាំញីវត្ថុ ១០ ប្រការទាំងនោះ ហើយលើកសរីរៈ គឺ ព្រះធម៌វិន័យឡើងសង្គាយនា ។

ភិក្ខុវជ្ជីបុត្រមានប្រមាណ ១០.០០០ អង្គ ត្រូវព្រះធម្មសង្គាហកត្ថេរទាំងឡាយគ្របសង្កត់ហើយ គឺ ទិតៀនហើយ ទើបស្វែងរកពួកគណៈ គ្រាបានពួកដែលជាទុព្វលវៈដ៏សមគួរដល់ខ្លួន ក៏ចាត់តាំងសម្នាក់ត្រកូលអាចារ្យថ្មី ឈ្មោះថា មហាសង្ឃិកៈ និងឯកព្យោហារិកៈ ដែលបែកចេញមកពីត្រកូលអាចារ្យសង្ឃិកៈនោះ ។ ត្រកូលអាចារ្យពីរពួកដទៃទៀត គឺ បញ្ញត្តិវាទៈ និងពហុលិយៈ ដែលមានឈ្មោះម៉្យាងទៀតថា ពហុស្សុតិកៈ ដែលបែកចេញមកពីនិកាយគោកុលិកៈ ។ អាចរិយ-វាទដទៃទៀតឈ្មោះថា ចេតិយវាទ កើតឡើងហើយក្នុងរវាងនិកាយពហុលិយៈនោះ នោះឯង ។ ក្នុងរយៈនៃឆ្នាំទីពីរ គឺ ក្នុងព្រះពុទ្ធសករាជ ២០០ ត្រកូលអាចារ្យទាំងប្រាំ បានកើតឡើងពីត្រកូលអាចារ្យមហាសង្ឃិកៈដោយប្រការ ដូច្នេះ ។

ត្រកូលអាចារ្យទាំងប្រាំនោះ រួមជាមួយមហាសង្ឃិកៈដើមមួយ ក៏បានជា

ប្រាំមួយត្រកូល ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ អាចរិយវាទទាំងពីរ គឺ មហិ-សាសកៈ និងវជ្ជីបុត្តកៈកើតឡើង ដែលបែកចេញមកពីថេរវាទ ។ ក្នុងបណ្តាអាចរិយវាទទាំងពីរនោះ អាចរិយវាទទាំងបួន គឺ ធម្មុត្តរិយៈ ១ ភទ្រយានិកៈ ១ ឆន្នាគារិកៈ ១ សម្មិតិយៈ ១ កើតឡើង ព្រោះបែកចេញមកពីនិកាយវជ្ជីបុត្តកៈ ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ នោះឯង អាចរិយវាទពីរពួក គឺ សព្វត្ថិកវាទ និង ធម្មគុត្តិកៈកើតឡើង ព្រោះការបែកចេញពីត្រកូល អាចារ្យមហិសាសកៈទៀត ។ កាលនិកាយកស្សបិកៈទាំងឡាយបែកគ្នាហើយ ក៏ជាហេតុឲ្យនិកាយឈ្មោះថា សង្កន្តិកៈផ្សេងទៀតកើតឡើង កាលនិកាយសង្កន្តិកៈទាំងឡាយបែកគ្នាហើយ និ-កាយឈ្មោះថា សុត្តវាទក៏កើតឡើង ។ អាចរិយវាទ ១១ និកាយនេះកើតឡើង ហើយ ព្រោះបែកចេញមកពីថេរវាទ យ៉ាងនេះ ដោយប្រការដូច្នេះ ។ អាចរិយ-វាទ ១១ និកាយនេះ រួមទាំងថេរវាទដើម ក៏ជា ១២ និកាយ ។

ក្នុងពុទ្ធសករាជ ២០០ អាចរិយវាទ គឺ លទ្ធិនៃអាចារ្យទាំងអស់ រួម ១៨ និកាយ គឺ ១២ និកាយបែកចេញអំពីថេរវាទនេះ និងនិកាយអាចរិយវាទ ៦ បែកចេញមកពីត្រកូលអាចារ្យមហាសង្ឃិកៈទាំងឡាយ ដូច្នេះឯង ។

ពាក្យថា និកាយ ១៨ ក្តី ត្រកូលអាចារ្យ ១៨ ក្តី ជាឈ្មោះ របស់និកាយដែលពោលមកហើយទាំងនោះឯង ។ ម្យ៉ាងទៀត បណ្តានិកាយទាំង ១៨ នោះ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលបែកចេញពីគ្នា , ចំណែកថេរវាទ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលមិនបែកគ្នា គឺ តាំងនៅដូចដើម ។

## តារាងសម្តែងនិកាយសង្ឃក្នុងសតវត្ស ទី ៣




*ភិក្ខុដ៏លាមកទាំងឡាយ ដែលជាពួកវជ្ជីបុត្តជាអធម្មវាទី ត្រូវព្រះថេរៈជាធម្មវាទីទាំងឡាយបានបណ្តេញចេញហើយ បានពួកដទៃទៀត ទើបផ្តើមតាំងជាគណាចារ្យថ្មី ។*

*( ស្រង់ចេញពីអដ្ឋកថា បរមត្ថទីបនី អដ្ឋកថាអភិធម្មបិដក កថាវត្ថុ )*

# ប្រវត្តិអ្នកតែងព្រះអដ្ឋកថា

ព្រះពុទ្ធឃោសត្ថេរ ដែលយើងនិយមហៅថា **ព្រះពុទ្ធឃោសាចារ្យ** បានប្រាប់ទុកខាងក្រោយនៃអារម្ភកថា ព្រះគម្ពីរអដ្ឋកថាអដ្ឋសាលិនីថា ព្រះភិក្ខុមាននាមថា ពុទ្ធឃោសៈដូចគ្នា បានអារាធនាលោកឲ្យតែងព្រះគម្ពីរនេះឡើង ( គម្ពីរអដ្ឋសាលិនី ) ។ ទាំងនេះឃើញថា នាមព្រះពុទ្ធឃោសៈមានច្រើន ដូចក្នុងសម័យនោះ ក៏នៅមានព្រះពុទ្ធឃោសៈអារាធនាឲ្យព្រះ ពុទ្ធឃោសៈតែងគម្ពីរនេះជាដើម ។

កិត្តិសព្ទរបស់ព្រះពុទ្ធឃោសៈ ជាមង្គលដ៏អង្វែង ព្រោះលោកបានធ្វើការកសាងព្រះគម្ពីរទុកយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ព្រះពុទ្ធឃោសាចារ្យជាអ្នកស្រុកជម្ពូទ្វីប គឺ ប្រទេសឥណ្ឌាប៉ែកខាងត្បូង មានជីវិតរស់នៅក្នុងរវាងពុទ្ធសករាជ ៩៤៥ ដល់ ១.០០០ ឆ្នាំ កើតក្នុងត្រកូលព្រាហ្មណ៍នាតំបន់ ពុទ្ធគយាដែនមគធៈ ជិតស្ថានទីត្រាស់ដឹង ។ មុនចូលមកបួសក្នុងព្រះពុទ្ធសាសនា បានសិក្សាសិល្ប៍-សាស្ត្រទាំងពួង រៀនចប់ត្រៃវេទ បានត្រាច់ទៅ កាន់ទីផ្សេង ៗ ក្នុងជម្ពូទ្វីប បានឆ្លើយបញ្ហាជាមួយសមណៈ និងព្រាហ្មណ៍ទាំងឡាយ ប្រាកដជាអ្នកមានសតិបញ្ញាច្រើន ។ សមណព្រាហ្មណ៍ និងបណ្ឌិតដទៃ ៗ មិនអាចឆ្លើយដោះស្រាយបញ្ហាព្រាហ្មណ៍កំលោះនេះបាន ។ តែព្រាហ្មណ៍កំលោះនេះ អាចដោះស្រាយបញ្ហា ដែលសមណព្រាហ្មណ៍ និងបណ្ឌិតសួរបាន ដូច្នោះ ព្រាហ្មណ៍កំលោះ ទើបមានឈ្មោះបោះសំឡេងខ្ទរខ្ទារ គ្របសង្កត់រហូតសកលជម្ពូទ្វីប ។

គ្រាមួយ ព្រាហ្មណ៍កំលោះដើរផ្លូវ មកដល់វត្តមួយដែលជាស្ថានទីពុទ្ធ-គយា បានជួបជាមួយព្រះរេវតត្ថេរ ដែលជាព្រះមហាខីណាស្រពសម្រេចបដិ-សម្ភិទា ៤ ។

ថ្ងៃមួយព្រាហ្មណ៍កំលោះ បានស្វាធ្យាយមន្តក្នុងគម្ពីរបតញ្ជលី យ៉ាងត្រឹមត្រូវ ពីរោះគួរចាប់ចិត្តរហូតដល់យប់ ព្រះថេរៈបានឮសំឡេងព្រាហ្មណ៍នោះស្វាធ្យាយហើយ ក៏ដឹងថាជាអ្នកមានសតិបញ្ញាច្រើន ទើបហៅព្រាហ្មណ៍នោះមកដើម្បីបានសន្ទនាគ្នា ព្រាហ្មណ៍កំលោះបានសួរបញ្ហាផ្សេង ៗ ក្នុងគម្ពីរត្រៃវេទដែលខ្លួននៅមានការសង្ស័យមិនយល់ ចំពោះព្រះថេរៈ ព្រះថេរៈក៏ឆ្លើយអធិប្បាយបានទាំងអស់ ក្រោយមកព្រះថេរៈទើបសួរបញ្ហាក្នុងព្រះអភិធម្មខ្លះ ៗ ព្រាហ្មណ៍កំលោះឆ្លើយមិនបាន ទើបសួរថា នេះឈ្មោះថាអ្វី ព្រះថេរៈឆ្លើយថា ឈ្មោះថា **ពុទ្ធមន្ត** ទើបសូមរៀនពុទ្ធមន្ត ហើយក៏បានបព្វជ្ជាឧបសម្បទាក្នុងព្រះពុទ្ធសាសនា បានរៀនព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក បានប្រាកដឈ្មោះថា ព្រះពុទ្ធឃោសៈ ។

កាលព្រះពុទ្ធឃោសៈ គង់នៅក្នុងវត្ត នាតំបន់ពុទ្ធគយានោះ បានរចនាបករណ៍ឈ្មោះ **ញាណោទ័យ** ទុកក្នុងវត្ត ហើយផ្តើមរចនាគម្ពីរអដ្ឋកថា ឈ្មោះអដ្ឋសាលិនី ដែលជាអដ្ឋកថាព្រះគម្ពីរធម្មសង្គណីបករណ៍ និងគម្ពីរបរិត្តដ្ឋកថា គឺ អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ព្រះរេវតមហាថេរៈ បានឃើញអដ្ឋកថាដែលលោកបានរចនាហើយ ទើបណែនាំលោកថា ក្នុងជម្ពូទ្វីបមានតែព្រះបាលីព្រះត្រៃបិដកប៉ុណ្ណោះ មិនមានអដ្ឋកថាបាលីព្រះត្រៃបិដកនៅឡើយ តែក្នុងលង្កា-ទ្វីបនៅមាន ដោយព្រះថេរៈទាំងឡាយ មានព្រះសារីបុត្ត (ឈ្មោះដូចអគ្គសាវក)

ជាដើម បានរចនាទុក និងតមកព្រះមហិន្ទត្ថេរៈបានត្រួតពិនិត្យ ហើយរចនាទុកជាភាសាសីហឡៈ សូមឲ្យព្រះពុទ្ធឃោសៈទៅលង្កាទ្វីប ត្រួតពិនិត្យមើលអដ្ឋកថាទាំងនេះ ហើយប្រែមកជាភាសាមគធៈវិញ នឹងបានជាប្រយោជន៍ និងសេចក្ដីចម្រើនដល់មនុស្សលោកទាំងពួង កាលព្រះថេរៈបានណែនាំយ៉ាងនេះ ហើយព្រះពុទ្ធឃោសៈ ក៏មានបីតិសោមនស្ស ក្រាបបង្គំលាព្រះឧបជ្ឈាយ៍ និងព្រះភិក្ខុសង្ឃ ហើយធ្វើដំណើរទៅកាន់លង្កាទ្វីបតាមទូក បានជួបព្រះពុទ្ធទត្តត្ថេរៈ ដែលបាននិមន្តជ្រួសផ្លូវគ្នានៅកណ្ដាលសមុទ្រ បានសន្ទនាគ្នា និងប្រាស្រ័យទាក់ទងរឿងប្រែគម្ពីរជាភាសាមគធៈ ហើយធ្វើដំណើរតទៅរហូតដល់ កំពង់ផែក្រុងលង្កា សម័យនោះ គឺ ជាកាលរបស់ក្សត្រលង្កាទ្រង់ព្រះនាមថា **មហានាម** មាននាមដទៃទៀតថា ( សិរិនិវាស ) ខ្វះ ( សិរិកុថៈ ) ខ្វះ ( សិរិកូដៈ ) ខ្វះ ពុទ្ធសករាជ ( ៩៥២-៩៧៤ ) ។

កាលដែលព្រះពុទ្ធឃោសៈទៅដល់លង្កា បានទៅជួបព្រះភិក្ខុសង្ឃក្នុងមហាវិហារនាក្រុងអនុរាធបុរៈ ហើយបានទៅកាន់សម្នាក់របស់ព្រះសង្ឃបាលត្ថេរៈ ដែលជាព្រះសង្ឃរាជនៅក្នុងក្រុងអនុរាធបុរៈ នៃសម្នាក់មហាបធាន បានស្ដាប់អដ្ឋកថាជាភាសាសីហឡៈ និងថេរវាទទាំងអស់ហើយ បានធ្វើទុកក្នុងចិត្តថាជាពុទ្ធាធិប្បាយរបស់ព្រះមានព្រះភាគពិត ទើបបានសុំការអនុមតិអំពីសង្ឃដើម្បីបានឱកាសរចនា អដ្ឋកថាព្រះត្រៃបិដក ជាភាសាមគធៈ ។ ដើម្បីផ្ទៀងផ្ទាត់ការចេះដឹង និងសមត្ថភាពរបស់ព្រះពុទ្ធឃោសៈ គណៈសង្ឃលង្កា ដែលមានព្រះសង្ឃបាលត្ថេរៈជាប្រធាន បានប្រគល់ព្រះគាថា ២ ព្រះគាថាឲ្យលោករចនា

សិន ទើបអនុញ្ញាតឲ្យលោកត្រួតពិនិត្យគម្ពីរទាំងអស់ ។ ព្រះពុទ្ធឃោសៈបាន រចនាបករណ៍ឈ្មោះ វិសុទ្ធិមគ្គឡើង មានសេចក្ដីយ៉ាងល្អប្រសើរ រហូតដល់ ព្រះសង្ឃលង្កាទទួលស្ដាប់នូវសេចក្ដីជំនាញរបស់លោក តាមប្រវត្តិបាននិយាយ ថា ដើម្បីនឹងប្រកាសនូវភាពជំនាញរបស់ព្រះពុទ្ធឃោសៈនោះឲ្យប្រាកដ ទេវតា បានបណ្ដាលឲ្យគម្ពីរដែលរចនាស្រេចហើយ បាត់ទៅ ព្រះពុទ្ធឃោសៈក៏បាន រចនាជាថ្មីម្ដងទៀត ទេវតាក៏បណ្ដាលឲ្យបាត់ទៀត លោកក៏បានរចនាឡើងម្ដង ទៀតគម្រប់ ៣ ដង បន្ទាប់មក ក៏ថ្វាយគម្ពីរដែលបានរចនាទាំងពីរគម្ពីរនោះវិញ វេលានោះ ទើបបានគម្ពីរវិសុទ្ធិមគ្គ ជា ៣ ចប់ ព្រះពុទ្ធឃោសៈក៏បាននាំគម្ពីរ ទាំង ៣ ចប់នោះ ថ្វាយដល់ព្រះភិក្ខុសង្ឃ ព្រះភិក្ខុសង្ឃបានអានទាំងបីគម្ពីរ ប្រៀបធៀបគ្នាហើយមិនមានការខុសគ្នាទាំងដោយព្រះគម្ពីរ ឬអក្ខរៈ ឬដោយបទ ឬដោយព្យញ្ជនៈ ឬដោយអត្ថ ឬដោយបទដើម បទចុង ឬដោយថេរវាទ ឬ ដោយព្រះបាលី ទាំងឡាយក្នុងកន្លែងណាទីមួយឡើយ ទាំងបីច្បាប់ដូចគ្នា ដើម្បី សម្ដែងសេចក្ដីអង់អាចយ៉ាងក្រៃលែងរបស់លោក ទេវតាទាំងឡាយបានសាធុការ ព្រះសង្ឃប្រមាណ ១.០០០ អង្គ ប្រជុំគ្នាក្នុងមហាវិហារបានឃើញសេចក្ដីអស្ចារ្យ នាំគ្នាត្រេកអរ កោតសរសើរ សោមនស្ស សាធុការ បានប្រកាសថា លោកអង្គ នេះ ជាព្រះមេត្តេយ្យពោធិសត្វ ពិតប្រាកដ និងបានអនុមតិឲ្យលោកប្រែគម្ពីរ ពីភាសាសីហឡៈមកជាភាសាមគធៈ ។

ក្នុងគ្រានោះ ព្រះចៅមហានាមក្សត្រនៃលង្កា ទ្រង់បានស្ដាប់កិត្តិគុណរបស់ លោក ស្ដេចបានចេញចាកពីព្រះនគរទៅដល់មហាវិហារ ទ្រង់នមស្ការព្រះសង្ឃ

ហើយនមស្ការព្រះពុទ្ធឃោសៈ និមន្តឲ្យគង់នៅក្នុងប្រាសាទមួយ ឈ្មោះ **បធានឃរ** នាទិសទក្សិណរបស់មហាវិហារ បានប្រែអដ្ឋកថាភាសាសីហឡៈ ជាអដ្ឋកថាព្រះត្រៃបិដកភាសាមគធៈ ។

អដ្ឋកថាក្នុងភាសាសីហឡៈពីបុរាណនោះមាន ៣ យ៉ាង គឺ ៖

១ មហាអដ្ឋកថា

២ បច្ចរិយអដ្ឋកថា

៣ កុរុន្ទីអដ្ឋកថា អដ្ឋកថាដែលបានលើកឡើងកាន់សង្គាយនា

ព្រះមហិន្ទត្ថេរៈនាំមកពីជម្ពូទីប ហើយរចនាទុកជាភាសាសីហឡៈឈ្មោះ **មហាអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុទាំងឡាយប្រជុំគ្នារចនានៅក្នុងផែ ( ផ្ទះទឹក ) ដែលក្នុងភាសាសីហឡៈហៅថា បច្ចរិយៈ ឈ្មោះថា **បច្ចរិយអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុសង្ឃទាំងឡាយប្រជុំគ្នារចនា ក្នុងកុរុន្ទីវេឡុវិហារ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

វាទៈដែលអាចារ្យទាំងឡាយក្នុងកាលមុន មានព្រះអាចារ្យថ្នាក់ព្រះថេរៈជាដើម បានរចនាទុកដោយកាន់យកន័យព្រះបាលីឈ្មោះថា **ថេរវាទ** ។

គម្ពីរអដ្ឋកថាភាសាសីហឡៈ ដែលព្រះពុទ្ធឃោសៈបានប្រែមកជាអដ្ឋកថាព្រះត្រៃបិដកជាភាសាមគធៈ មានច្រើនជាងពាក់កណ្តាលនៃគម្ពីរអដ្ឋកថាទាំងអស់ មានរាយនាមព្រះគម្ពីរដូច្នេះ ៖

១ សមន្តបាសាទិកា អដ្ឋកថាព្រះវិន័យបិដក

២ កង្ខាវិតរណី ឬមាតិកដ្ឋកថា អដ្ឋកថាព្រះបាតិមោក្ខ

៣ សុមង្គលវិលាសនី អដ្ឋកថាទីឃនិកាយ

៤ បបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយ

៥ សារត្ថប្បកាសិនី អដ្ឋកថាសំយុត្តនិកាយ

៦ មនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយ

៧ បរមត្ថជោតិកា អដ្ឋកថាខុទ្ទកបាឋៈ និងសុត្តនិបាត

៨ ធម្មបទដ្ឋកថា អដ្ឋកថាធម្មបទ

៩ ជាតកដ្ឋកថា អដ្ឋកថាជាតក

១០ អដ្ឋសាលិនី អដ្ឋកថាធម្មសង្គណីបករណ៍

១១ សម្មោហវិនោទនី អដ្ឋកថាវិភង្គបករណ៍

១២ បញ្ចករណដ្ឋកថា ឈ្មោះបរមត្ថទីបនី ជាព្រះអដ្ឋកថាព្រះអភិធម្មទាំងប្រាំគម្ពីរ គឺ ធាតុកថា កថាវត្ថុ បុគ្គលប្បញ្ញត្តិ យមក និងបដ្ឋាន ។

១៣ វិសុទ្ធិមគ្គ បករណ៍វិសេសពោលដោយ សីល សមាធិ បញ្ញា ។

១៤ ញាណោទ័យ តែងមុនកាលនៅឥណ្ឌា ច្បាប់ដើមអន្តរធានហើយ ។

១៥ បរិត្តដ្ឋកថា អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ច្បាប់ដើមអន្តរធានហើយ ។

ព្រះគម្ពីរទាំងនេះ បានជាប្រយោជន៍ដ៏ក្រៃលែង ចំពោះមនុស្សក្នុងប្រទេសផ្សេង ៗ លោកពោលទុកថា គម្ពីរទាំងអស់ប្រើពេលវេលាត្រឹមតែ ១ ឆ្នាំ ក៏បានសម្រេច បានកើតសេចក្តីអស្ចារ្យ សូម្បីផែនដីក៏កម្រើកញាប់ញ័រ ។

*លទ្ធផលការងារ វណ្ណកម្មរបស់ព្រះពុទ្ធឃោសៈ អ្នកសិក្សាភាសាបាលីទូទៅ បានសរសើរ និងរាប់អានលោកថា ជាបុរាណាចារ្យយ៉ាងសំខាន់ក្រៃលែងរបស់លោក ។*

# រាយនាមលោកអ្នកមានឧបការៈ

លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

លោកគ្រូធម្មបណ្ឌិត រស់ សុផាត

លោកគ្រូវិនិយាចារ្យ គាំ អ៊ីវ

ឧបាសក ក្អាត ហ៊ិន

ឧបាសក ទុំ ទូន

ឧបាសក ជឹម ជំនិត

ឧបាសក សន ម៉ារឌី

ឧបាសក អ៊ឹម វ៉ៃយ៉ា

ឧបាសក សោម រតនៈ

ឧបាសក ម៉ៅ ផុន

ឧបាសិកា ថាច់ លឿម

ឧបាសិកា ប៊ុត សុម៉ាលី

ឧបាសិកា ពូ ហ៊ាង

ឧបាសិកា ប៉ែន រមណី

ឧបាសក នាក់ ម៉ៅ

ឧបាសក ហុក សឹងហួត

ឧបាសក កើត ទិត្យ

ឧបាសក ហាយ ចំរើន

ឧបាសក សុក្រ ហ៊ត

ឧបាសក សំ ឆាយ

ឧបាសក ជា ស៊ីបាន

ឧបាសិកា ហាយ សារ៉ាត់

ឧបាសិកា យស សម្បត្តិ

ឧបាសិកា ប៊ុត សេដាដួង

ព្រមទាំងពុទ្ធបរិស័ទក្នុង និងក្រៅប្រទេស

# រាយនាមអ្នកប្រែសម្រួល

ព្រះសង្ឃអាស្រមព្រះគន្ធកុដិ

| | | |
|---|---|---|
| ព្រះភិក្ខុអគ្គទិន្នោ | នួវ ប៉ូវ៉ា | ប្រធានអាស្រម |
| ព្រះភិក្ខុចិត្តរក្ខិតោ | សំ សម្បត្តិ | ធម្មាចារ្យ |
| ព្រះភិក្ខុធម្មប្បញ្ញោ | ផុំ សារឿន | ធម្មាចារ្យ |
| ព្រះភិក្ខុវរធម្មោ | ផុត តៅ | ធម្មាចារ្យ |

សាមណេរ កោវិនោ ឡោះ សូវៀត សមណសិស្ស សាលាសតិប្បដ្ឋាន

ផ្នែកឧបាសក

ឧបាសក ក្អាត ហ៊ិន ឧបាសក ហាយ ចំរើន

# បត្តិទានកថា

ការរៀបរៀង ប្រែសម្រួលអដ្ឋកថាព្រះត្រៃបិដកជាខេមរភាសា ដើម្បីបូជាចំពោះព្រះរតនត្រៃ ម្យ៉ាងទៀតដើម្បីតម្កល់ទុកជាសម្បត្តិវប្បធមិជាតិ និងជាចំណែកចូលរួមក្នុងការតាំងនៅនៃព្រះសទ្ធម្មគម្រប់ ៥.០០០ ព្រះវស្សា ។

យើងខ្ញុំជាក្រុមប្រែសម្រួលអដ្ឋកថា សូមលើកនូវបុណ្យកុសលដែលកើតឡើងអំពីការងារនេះ ៖-

**ឧទ្ទិសថ្វាយ និងគោរពជូន:**

-ព្រះមហាវរក្សត្រ និងមហាវរក្សត្រិយានី

-ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

-សម្តេចព្រះសង្ឃរាជទាំងពីរគណៈ

-មាតាបិតានៃយើងខ្ញុំទាំងអស់គ្នា

-លោកគ្រូអគ្គបណ្ឌិតធម្មចារ្យ ប៊ុត សាវង្ស

-លោកគ្រូធម្មបណ្ឌិត រស់ សុផាត

-សព្វមុខមន្ត្រីរាជការ និងប្រជានុរាស្ត្រនៃកម្ពុជរដ្ឋ

-សព្វសត្វទាំងអស់ក្នុងត្រ័យភព

សូមលោកត្រេកអរ អនុមោទនានូវចំណែកបុណ្យនេះ

សូមអនុមោទនា !.....

ក្រុមរៀបរៀង និងប្រែសម្រួល

# មាតិកាធម៌

ឈ្មោះធម៌ | ទំព័រ

## មគ្គសំយុត្តទី ១

### អវិជ្ជាវគ្គទី ១


| | | |
|---|---|---|
| អដ្ឋកថា អវិជ្ជាសូត្រ | ទី ១ | ១ |
| អដ្ឋកថា ឧបឌ្ឍសូត្រ | ទី ២ | ៩ |
| អដ្ឋកថា សារីបុត្តសូត្រ | ទី ៣ | ១០ |
| អដ្ឋកថា ព្រាហ្មណសូត្រ | ទី ៤ | ១១ |
| អដ្ឋកថា កិមត្ថិយសូត្រ | ទី ៥ | ២២ |
| អដ្ឋកថា ទុតិយភិក្ខុសូត្រ | ទី ៧ | ២៣ |
| អដ្ឋកថា វិភង្គសូត្រ | ទី ៨ | ២៤ |
| អដ្ឋកថា សុកសូត្រ | ទី ៩ | ៣៥ |
| អដ្ឋកថា នន្ទិយសូត្រ | ទី ១០ | ៣៧ |


### វិហារវគ្គទី ២


| | | |
|---|---|---|
| អដ្ឋកថា បឋមវិហារសូត្រ | ទី ១ | ៣៨ |
| អដ្ឋកថា ទុតិយវិហារសូត្រ | ទី ២ | ៤៦ |
| អដ្ឋកថា សេក្ខសូត្រ | ទី ៣ | ៤៨ |
| អដ្ឋកថា បឋមកុក្កុ...សូត្រ | ទី ៤ | ៤៩ |


### មិច្ឆត្តវគ្គទី ៣


| | | |
|---|---|---|
| អដ្ឋកថា មិច្ឆត្តសូត្រជាដើម | | ៥១ |

**បដិបត្តិវគ្គទី ៤**

អដ្ឋកថា បដិបត្តិសូត្រជាដើម ៥៣

**អញ្ញតិត្ថិយវគ្គទី ៥**

អដ្ឋកថា អញ្ញតិត្ថិយបេយ្យាល ៥៦

**សុរិយបេយ្យាលវគ្គទី ៦**

អដ្ឋកថា សុរិយបេយ្យាល ៥៧

**ឯកបេយ្យាល និងគង្គាបេយ្យាល**

អដ្ឋកថា ឯកបេយ្យាល និងគង្គាបេយ្យាល ៥៩

**អប្បមាទវគ្គទី ១០**

អដ្ឋកថា អប្បមាទវគ្គ ៦០

**ពលករណីយវគ្គទី ១១**

អដ្ឋកថា បឋមពលករណិយសូត្រ ទី ១ ៦៣

អដ្ឋកថា ពីជសូត្រ ទី ២ ៦៤

អដ្ឋកថា នាគសូត្រ ទី ៦ ៦៥

អដ្ឋកថា កុម្ភសូត្រ ទី ៨ ៦៧

អដ្ឋកថា អាកាសសូត្រ ទី ១០ ៦៨

អដ្ឋកថា បឋមមេឃសូត្រ ទី ១១ ៦៩

អដ្ឋកថា នាវាសូត្រ ទី ១៣ ៧០

អដ្ឋកថា អាគន្តុកាគារសូត្រ ទី ១៤ ៧០

## ឯសនាវគ្គទី ១២


| | | | |
|---|---|---|---|
| អដ្ឋកថា | បឋមឯសនាសូត្រ | ទី ១ | ៧២ |
| អដ្ឋកថា | វិធាសូត្រ | ទី ៩ | ៧៣ |
| អដ្ឋកថា | និយសូត្រ | ទី ១៥ | ៧៤ |


## ឱឃវគ្គទី ១៣


| | | | |
|---|---|---|---|
| អដ្ឋកថា | ឱឃវគ្គ | | ៧៥ |


## ពោជ្ឈង្គសំយុត្តទី ២
## បព្វតវគ្គទី ១


| | | | |
|---|---|---|---|
| អដ្ឋកថា | ហេមវន្តសូត្រ | ទី ១ | ៧៧ |
| អដ្ឋកថា | កាយសូត្រ | ទី ២ | ៨១ |
| អដ្ឋកថា | សីលសូត្រ | ទី ៣ | ៨៧ |
| អដ្ឋកថា | វត្ថុសូត្រ | ទី ៤ | ៩៤ |
| អដ្ឋកថា | ភិក្ខុសូត្រ | ទី ៥ | ៩៦ |
| អដ្ឋកថា | កុណ្ឌលិយសូត្រ | ទី ៦ | ៩៧ |
| អដ្ឋកថា | កូដសូត្រ | ទី ៧ | ១០៣ |
| អដ្ឋកថា | ឧបវាណសូត្រ | ទី ៨ | ១០៤ |
| អដ្ឋកថា | បឋមឧប្បាទសូត្រ | ទី ៩ | ១០៥ |
| អដ្ឋកថា | ទុតិយឧប្បាទសូត្រ | ទី ១០ | ១០៦ |


## គិលានវគ្គទី ២


| | | | |
|---|---|---|---|
| អដ្ឋកថា | ពាណូបមសូត្រ | ទី ១ | ១០៧ |
| អដ្ឋកថា | បឋមគិលានសូត្រ | ទី ៤ | ១០៨ |

## ឧទាយិវគ្គទី ៣


| | | |
|---|---|---|
| អដ្ឋកថា ពោធនសូត្រ | ទី ១ | ១១០ |
| អដ្ឋកថា ទេសនាសូត្រ | ទី ២ | ១១១ |
| អដ្ឋកថា ឋនិយសូត្រ | ទី ៣ | ១១២ |
| អដ្ឋកថា ខនិយសូត្រ | ទី ៦ | ១១៣ |
| អដ្ឋកថា និព្វេធសូត្រ | ទី ៨ | ១១៦ |
| អដ្ឋកថា ឯកធម្មសូត្រ | ទី ៩ | ១១៧ |
| អដ្ឋកថា ឧទាយិសូត្រ | ទី ១០ | ១១៨ |


## នីវរណវគ្គទី ៤


| | | |
|---|---|---|
| អដ្ឋកថា ឧបក្កិលេសសូត្រ | ទី ៣ | ១២០ |
| អដ្ឋកថា អាវរណានីវ..សូត្រ | ទី ៧ | ១២២ |
| អដ្ឋកថា នីវរណាវរណសូត្រ | ទី ៨ | ១២៣ |
| អដ្ឋកថា រុក្ខសូត្រ | ទី ៩ | ១២៥ |
| អដ្ឋកថា នីវរណសូត្រ | ទី ១០ | ១២៦ |


## ចក្កវត្តិវគ្គទី ៥


| | | |
|---|---|---|
| អដ្ឋកថា វិធាសូត្រ | ទី ១ | ១២៧ |
| អដ្ឋកថា ចក្កវត្តិសូត្រ | ទី ២ | ១២៨ |
| អដ្ឋកថា ទុប្បញ្ញសូត្រ | ទី ៤ | ១៣៥ |


## ពួក ៦ នៃពោជ្ឈង្គវគ្គទី ៦


| | | |
|---|---|---|
| អដ្ឋកថា អាហារសូត្រ | ទី ១ | ១៣៦ |
| អដ្ឋកថា បរិយាយសូត្រ | ទី ២ | ១៦៥ |
| អដ្ឋកថា អគ្គិសូត្រ | ទី ៣ | ១៧២ |

អដ្ឋកថា មេត្តាសូត្រ ទី ៤ ១៧៣
អដ្ឋកថា សគារវសូត្រ ទី ៥ ១៨០
អដ្ឋកថា អភយសូត្រ ទី ៦ ១៨៤

## អានាបានានិបេយ្យាលវគ្គទី ៧

អដ្ឋកថា អដ្ឋិកសញ្ញា ១៨៦
អដ្ឋកថា បុឡវកសញ្ញា ១៨៨
អដ្ឋកថា អសុភសញ្ញា ១៨៩

# ព្រះសុត្តន្តបិដក
# សំយុត្តនិកាយ មហាវារវគ្គ
# ឈ្មោះ
# សារត្ថប្បកាសិនី
# នវមភាគ
# ភាគ ៣៧

សូមនមស្ការដល់ព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធអង្គនោះ

## មគ្គសំយុត្ត

ពោលដោយអវិជ្ជា និងវិជ្ជា ជាប្រធាននៃអកុសល និងកុសល

## អវិជ្ជាវគ្គទី ១
### អដ្ឋកថា អវិជ្ជាសូត្រ

*គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ១ នៃមហាវគ្គ[1] ដូចតទៅនេះ ៖*

---

១ បាលីជា មហាវារវគ្គ ។

[២] បទថា **ជាប្រធាន (បុព្វង្គមា)** បានដល់ ជាប្រធានដោយអាការ ២ យ៉ាង គឺ ដោយអំណាចសហជាតប្បច្ច័យ ១ ដោយអំណាចឧបនិស្សយ-ប្បច្ច័យ ១ ។ បទថា **ឲ្យដល់ព្រម (សមាបត្តិយា)** សេចក្តីថា ដើម្បីការចូលដល់ ដើម្បីការបាន ដើម្បីការកើតឡើង ។

បទថា **ការកើតរួមគ្នាជាមួយការមិនខ្មាសបាប ការមិនខ្លាចបាប (អន្វទេវ អហិរិកំ អនោត្តប្បំ)** សេចក្តីថា ក៏អហិរិកៈ តាំងនៅដោយអាការនៃការមិនខ្មាស និងអនោត្តប្បៈតាំងនៅដោយអាការនៃការមិនខ្លាចនោះឯង ។ អវិជ្ជានោះ រមែងកើតឡើងរួមជាមួយអហិរិកៈ និងអនោត្តប្បៈនោះ វៀរអហិរិកៈ និងអនោត្តប្បៈនោះចេញ កើតឡើងមិនបាន ។ បទថា **អ្នកប្រកបដោយអវិជ្ជា (អវិជ្ជាគតស្ស)** សេចក្តីថា មិច្ឆាទិដ្ឋិរមែងកើតមានដល់បុគ្គលចូលដល់ គឺ ប្រកបដោយអវិជ្ជា ។ បទថា **ការឃើញខុស (មិច្ឆាទិដ្ឋិ)** បានដល់ ការមិនឃើញតាមសេចក្តីពិត គឺ ការមិនឃើញធម៌ជា គ្រឿងនាំសត្វឲ្យរួចផុតចាកទុក្ខ ។ បទថា **រមែងកើត (បហោតិ)** គឺ រមែងមាន បានដល់ រមែងកើតឡើង ។ សូម្បីក្នុងមិច្ឆាសង្កប្បៈជាដើម គប្បីជ្រាប ជាមិច្ឆាដោយអំណាចសេចក្តីមិនពិត និងមិននាំសត្វឲ្យរួចផុតចាកទុក្ខនោះឯង ។

ឈ្មោះថា អង្គនៃមិច្ឆា (លក្ខណៈការឃើញខុស) នេះ រមែងមានដើម្បីការកើតឡើងនៃអកុសលធម៌ ៨ ដោយប្រការដូច្នេះ ។ ចំណែកអង្គ (លក្ខណៈ) នៃការឃើញខុសទាំងឡាយនោះ រមែងមិនកើតក្នុងខណៈតែមួយ រមែងកើតក្នុងខណៈផ្សេងៗ គ្នា ។

សួរថា ដូចម្តេច? ។ ឆ្លើយថា កាលណា ចិត្តប្រកបដោយទិដ្ឋិ កាលញុំាងកាយវិញ្ញត្តិឲ្យតាំងឡើងរមែងកើត កាលនោះ ក៏រមែងមានអង្គ ៦ គឺ មិច្ឆាទិដ្ឋិ (ការឃើញខុស) មិច្ឆាសង្កប្បៈ (ការត្រិះរិះខុស) មិច្ឆាវាយាមៈ (ការព្យាយាមខុស) មិច្ឆាសតិ (ការរឭកខុស) មិច្ឆាសមាធិ (ការតាំងចិត្តខុស) មិច្ឆាកម្មន្តៈ (ការងារខុស) ។ កាលណា ចិត្តមិនប្រកបដោយទិដ្ឋិ កាលនោះ មានអង្គ ៥ វៀរទិដ្ឋិ ។ ក្នុងន័យពីរយ៉ាងនោះឯង កាលណាញុំាងវចីវិញ្ញត្តិឲ្យតាំងឡើង កាលនោះ រមែងមានអង្គ ៦ ឬអង្គ ៥ តាំងនៅក្នុងមិច្ឆាវាចា ក្នុងឋានៈមិច្ឆាកម្មន្តៈ ។ ឈ្មោះថា អាជីវៈនេះ កាលកម្រើក រមែងកម្រើកក្នុងកាយទ្វារ និងវចីទ្វារ ទ្វារណាមួយប៉ុណ្ណោះមិនកម្រើកក្នុងមនោទ្វារទេ ។ ព្រោះដូច្នោះ អង្គ ៦ ឬអង្គ ៥ ទាំងនោះឯង រមែងមានដោយអំណាចមិច្ឆាជីវៈ ថា កាលណា ចិត្តទាំងនោះឯង ញុំាងកាយវិញ្ញត្តិ និងវចី-

វិញ្ញត្តិឲ្យតាំងឡើង ដោយបំណងដល់អាជីវៈ កាលនោះ កាយកម្ម ទើបឈ្មោះថា មិច្ឆាជីវៈ វចីកម្មក៏យ៉ាងនោះ ។ ក៏កាលណា ចិត្តទាំងនោះរមែងកើតឡើង តែមិនញ៉ាំងវិញ្ញត្តិឲ្យតាំងឡើង កាលនោះ រមែងមានអង្គ ៥ ដោយអំណាចនៃមិច្ឆាទិដ្ឋិ មិច្ឆាសង្កប្បៈ មិច្ឆាវាយាមៈ មិច្ឆាសតិ និងមិច្ឆាសមាធិ ឬមានអង្គ ៤ ដោយអំណាចនៃមិច្ឆាសង្កប្បៈជាដើម ដូច្នោះ អង្គទាំងឡាយនោះ រមែងមិនកើតក្នុងខណៈជាមួយគ្នា រមែងកើតក្នុងខណៈផ្សេងៗ គ្នាយ៉ាងនេះ ដោយប្រការដូច្នេះ ។

[៣] ក្នុងសុក្កបក្ខ (ចំណែកល្អ) ពាក្យថា **វិជ្ជា** បានដល់ សេចក្ដីដឹងថា សត្វមានកម្មជារបស់ខ្លួន ។ សូម្បីក្នុងវិជ្ជានេះ គប្បីជ្រាបអត្ថរបស់វិជ្ជាដោយអាការ ២ យ៉ាង គឺ ដោយអំណាចសហជាតប្បច្ច័យ ១ ដោយអំណាចឧបនិស្សយប្បច្ច័យ ១ ។ បទថា **ការខ្មាសបាប ការខ្លាចបាប** (ហិរោត្តប្បំ) បានដល់ ការខ្មាសបាប និងការខ្លាចបាប ។ ក្នុងធម៌ ២ យ៉ាងនោះ **ហិរិ** តាំងនៅដោយអាការនៃសេចក្ដីខ្មាស **ឱត្តប្បៈ** តាំងនៅដោយអាការនៃសេចក្ដីខ្លាច ។ នេះជាសេចក្ដីសង្ខេបក្នុងប្រការនេះ ។ ចំណែកសេចក្ដីពិស្ដារ លោកពោលទុកក្នុងវិសុទ្ធិមគ្គហើយ ។ បទថា **បុគ្គលប្រកបដោយវិជ្ជា (វិជ្ជាគត-**

ស្ស) បានដល់ សម្មាទិដ្ឋិរមែងកើតមានដល់អ្នកចូលដល់ គឺ ប្រកបដោយវិជ្ជា ។ បទថា **អ្នកដឹងច្បាស់ (វិទ្ទសុនោ)** បានដល់ បុគ្គលដឹងច្បាស់ គឺ បណ្ឌិត ។ បទថា **សេចក្តីឃើញត្រូវ (សម្មាទិដ្ឋិ)** បានដល់ ការឃើញតាមសេចក្តីពិត គឺ ការឃើញដែលនាំសត្វឲ្យផុតចាកទុក្ខ ។ សូម្បីក្នុងសម្មាកម្មន្តៈជាដើម ក៏មានន័យនេះដូចគ្នា ។ អង្គ ៨ ទាំងនេះ រមែងមានដើម្បីការកើតឡើងនៃកុសលធម៌ ដោយប្រការដូច្នេះ ។ សូម្បីអង្គទាំង ៨ នោះ រមែងមិនកើតព្រមគ្នាក្នុងខណៈនៃលោកិយមគ្គ តែរមែងកើតព្រមគ្នាក្នុងខណៈនៃលោកុត្តរមគ្គ ។ ក៏អង្គទាំង ៨ នោះ រមែងមានក្នុងមគ្គដែលប្រកបដោយបឋមជ្ឈាន ចំណែកក្នុងមគ្គដែលប្រកបដោយទុតិយជ្ឈានជាដើម រមែងមានអង្គ ៧ ប៉ុណ្ណោះ វៀរសម្មាសង្កប្បៈ ។

ក្នុងអង្គ ៧ នោះ បុគ្គលណាគប្បីពោលយ៉ាងនេះថា ព្រោះក្នុងមហាសឡាយតនសូត្រ ក្នុងមជ្ឈិមនិកាយ លោកពោលថា ការឃើញរបស់បុគ្គលយ៉ាងនោះឯង ការឃើញនោះ រមែងជាសម្មាទិដ្ឋិរបស់បុគ្គលនោះ , ការត្រិះរិះរបស់បុគ្គលយ៉ាងនោះឯង ការត្រិះរិះនោះ រមែងជាសម្មាសង្កប្បៈរបស់បុគ្គលនោះ , ការព្យាយាមរបស់បុគ្គលយ៉ាងនោះឯង ការព្យាយាមនោះ ក៏

ជាសម្មាវាយាមៈរបស់បុគ្គលនោះ , ការរឭករបស់បុគ្គលយ៉ាងនោះឯង ការរឭកនោះ រមែងជាសម្មាសតិរបស់បុគ្គលនោះ , ការតម្កល់ចិត្តត្រូវយ៉ាងនោះឯង ការតម្កល់ចិត្តត្រូវនោះ រមែងជាសម្មាសមាធិរបស់បុគ្គលនោះ ។ ក្នុងខាងដើមនៃកាយកម្ម វចីកម្ម និងអាជីវៈរបស់បុគ្គលនោះ ក៏រមែងបរិសុទ្ធិដោយល្អ ដូច្នេះ ។ ដូច្នោះ លោកុត្តរមគ្គក៏ប្រកបដោយអង្គ ៥ ប៉ុណ្ណោះ ដូច្នេះ ។ បុគ្គលនោះ ត្រូវគេតវ៉ាក្នុងសូត្រនោះថា ព្រោះហេតុអ្វី លោកទើបមិនឃើញពាក្យនេះថា អរិយមគ្គដែលប្រកបដោយអង្គ ៨ នេះ រមែងដល់នូវការចម្រើនពេញលេញដល់ភិក្ខុនោះយ៉ាងនេះ ដូច្នេះ ។ ចំណែកប្រការដែលលោកពោលថា **បុព្វេ ខោ បនស្ស** នោះ លោកពោលហើយ ដើម្បីសេចក្តីបរិសុទ្ធិ ចាប់ផ្តើមពីថ្ងៃដែលបួស ក្នុងសេចក្តីនេះ លោកសម្តែងន័យទុកដូច្នេះថា ផ្តើមពីថ្ងៃដែលបួសហើយ កាយកម្មជាដើមដែលបរិសុទ្ធិ រមែងបរិសុទ្ធិក្រៃលែង ក្នុងខណៈនៃលោកុត្តរមគ្គ ដូច្នេះ ។

សូម្បីពាក្យណា ដែលលោកពោលក្នុងអភិធម្មថា ក៏ក្នុងសម័យនោះឯង មគ្គប្រកបដោយអង្គ ៥ ពាក្យនោះ លោកពោលដើម្បីសម្តែងក្នុងរវាងកិច្ចមួយយ៉ាង ។ ក៏ក្នុងកាលណា បុគ្គលលះបង់ការងារខុសហើយ រមែង

ញ៉ាំងការងារត្រូវឲ្យបរិបូរក្នុងកាលនោះ ។ មិច្ឆាវាចា ឬមិច្ឆាជីវៈរមែងមិនមាន សម្មាកម្មន្តៈរមែងឲ្យបរិបូរក្នុងអង្គដើរត្តួកិច្ចការទាំងឡាយ ៥ នេះ គឺ ទិដ្ឋិ ១ សង្កប្បៈ ១ វាយាមៈ ១ សតិ ១ សមាធិ ១ ។ សម្មាសង្កប្បៈ ឈ្មោះថា រមែងឲ្យបរិបូរបានដោយអំណាចនៃវិរតិ សូម្បីក្នុងសម្មាវាចា និង សម្មាអាជីវៈ ក៏មានន័យនេះឯង ។ ពាក្យដែលលោកពោលហើយយ៉ាងនេះ ដើម្បីសម្តែងក្នុងវាងកិច្ចនេះ ។ ចំណែកក្នុងខណៈនៃលោកិយមគ្គ រមែង មានអង្គ ៥ ដោយពិត ព្រោះដូច្នោះ លោកមិនពោលថា មានអង្គ ៦ តែ ពោលថា មានអង្គ ៥ ប៉ុណ្ណោះ ដោយប្រការដូច្នេះ ។ ក៏បណ្ឌិតគប្បីជ្រាប ថា លោកុត្តរមគ្គរមែងមានអង្គ ៨ ព្រោះសេចក្តីសម្រេចនៃសម្មាកម្មន្តៈ ជា ដើម ជាអង្គនៃលោកុត្តរមគ្គ ក្នុងច្រើនសូត្រ មានមហាចត្តាឡីសកសូត្រជា ដើម យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុមានចិត្តជាអរិយៈ រក អាសវៈមិនបាន ព្រមព្រៀងដោយអរិយមគ្គ ចម្រើនអរិយមគ្គហើយ ការលះ ការវៀរ ការវៀរដាច់ខាតចាកកាយទុច្ចរិត ៣ គឺ ចេតនាជាគ្រឿងវៀរ មិន ធ្វើ ការមិនធ្វើណា ម្នាលភិក្ខុទាំងឡាយ សម្មាកម្មន្តៈនេះ រមែងជាលោកុត្តរ-មគ្គ ជាអរិយៈ រកអាសវៈមិនបាន ដូច្នេះ ។ ព្រះមានព្រះភាគ ត្រាស់មគ្គ

*មានអង្គ ៨ នេះ លាយដោយលោកិយៈ និងលោកុត្តរៈ ។*

ចប់អដ្ឋកថា អវិជ្ជាសូត្រទី ១

# អ ដ្ឋ ក ថា

## ឧបឌ្ឍសូត្រទី ២

[៤] ឧបឌ្ឍសូត្រទី ២ បានពោលទុកហើយក្នុងកោសលសំយុត្តនោះ

ឯង ។

# អ ដ្ឋ ក ថា

## សារីបុត្តសូត្រទី ៣

គប្បីជ្រាបវិនិច្ឆ័យក្នុង *សារីបុត្តសូត្រទី ៣* ដូចតទៅនេះ ៖

[៨] បទថា *នេះជាព្រហ្មចារ្យទាំងអស់ (សកលមិទំ ភន្តេ)* សេចក្ដីថា ព្រះអានន្ទត្ថេរមិនដឹងថា មគ្គព្រហ្មចារ្យទាំងអស់ដែលខ្លួនបាន ព្រោះអាស្រ័យកល្យាណមិត្រ ដូច្នេះ ព្រោះនៅមិនទាន់ដល់ទីបំផុតនៃសាវកបារមីញាណ ។ ចំណែកព្រះធម្មសេនាបតីបានដឹងហើយ ព្រោះតាំងនៅក្នុងទីបំផុតនៃសាវកបារមីញាណ ។ ព្រោះដូច្នោះ លោកទើបក្រាបទូលយ៉ាងនេះ ។ ព្រោះហេតុនោះឯង ព្រះមានព្រះភាគ ទើបទ្រង់បានប្រទានសាធុការដល់ព្រះថេរៈនោះថា ប្រពៃហើយ ប្រពៃហើយ ដូច្នេះ ។

ចប់អដ្ឋកថា សារីបុត្តសូត្រទី ៣

# អ ដ្ឋ ក ថា

## ព្រាហ្មណសូត្រទី ៤

*គប្បីជ្រាបវិនិច្ឆ័យក្នុង សារីបុត្តសូត្រទី ៣ ដូចតទៅនេះ ៖*

[១២] *បទថា រថទឹមដោយសេះសសុទ្ធ (សព្វសេតេន វឡវាភិរថេន) សេចក្តីថា រថទឹមដោយសេះ ៤ ក្បាល ដែលសសុទ្ធ ។ បានឮថា រថមានជុំ និងកាំស្រោបដោយប្រាក់ ។ ឈ្មោះថា រថ មាន ២ យ៉ាង គឺ រថចម្បាំង ១ រថទ្រង់គ្រឿង ១ ។ ក្នុងរថនោះ រថចម្បាំង មានសណ្ឋានបួនជ្រុងមិនធំពេក អាចផ្ទុកមនុស្សបាន ២ ឬ ៣ នាក់ ។ រថទ្រង់គ្រឿង ជារថធំ គឺ មានបណ្តោយវែង ទទឹងក៏ធំ ។ មនុស្សកាន់ឆ័ត្រ កាន់ផ្លិតរោមសត្វ កាន់ផ្លិតស្លឹកត្នោត នៅក្នុងរថនោះ ដូច្នោះ មនុស្ស ៧ ឬ ១០ នាក់ អាចនឹងឈរក៏បាន អង្គុយក៏បាន ដេកក៏បាន តាមសប្បាយយ៉ាងនោះឯង រថនេះ ចាត់ជារថទ្រង់គ្រឿង ។*

*បទថា សេះស (សេតា សុទំ អស្សា) សេចក្តីថា សេះស គឺ មានសម្បុរសតាមប្រក្រតី ។ បទថា គ្រឿងប្រដាប់ស (សេតាលង្ការា) សេចក្តីថា គ្រឿងប្រដាប់របស់សេះទាំងនោះ ជារបស់សម្រេចដោយប្រាក់ ។ បទថា*

**តួរថស (សេតោ រថោ)** រថ ឈ្មោះថា ស ព្រោះបិទបាំងដោយប្រាក់ និង ព្រោះប្រដាប់ដោយក្កុកក្នុងទីនោះៗ ដូចន័យដែលពោលហើយ ។ បទថា **ដំបូលរថស (សេតបរិវារោ)** សេចក្តីថា រថដទៃបិទបាំងដោយស្បែករាជសីហ៍ ខ្លះ បិទបាំងដោយស្បែកខ្លាខ្លះ បិទបាំងដោយសំពត់កម្ពលលឿងខ្លះ យ៉ាង ណា រថនេះមិនដូច្នោះ ។ ចំណែករថនេះបានបិទបាំងដោយសំពត់យ៉ាងល្អ ។ បទថា **ខ្សែស (សេតា រស្មិយោ)** សេចក្តីថា ខ្សែស្រោបដោយប្រាក់ និង កែវប្រវាឡ ។ បទថា **ជន្លជន្ទួញស (សេតា បតោទលដ្ឋិ)** សេចក្តីថា សូម្បី ជន្លជន្ទួញក៏ស្រោបដោយប្រាក់ ។ បទថា **ឆ័ត្រស (សេតំ ឆត្តំ)** សេចក្តីថា សូម្បីឆ័ត្រដែលគេលើកឡើងកណ្តាលរថក៏ស ។ បទថា **សំពតជួតក្បាលស (សេតំ ឧណ្ហីសំ)** សេចក្តីថា ឆ្នួតក្បាលធ្វើដោយប្រាក់ទទឹង ៨ ធ្នាប់ ក៏ស ។ បទថា **សំពត់ស្លៀកស (សេតានិ វត្ថានិ)** សេចក្តីថា សំពត់ស្លៀកស គឺ មានពណ៌ដូចដុំពពុះទឹក ។ ក្នុងសំពត់ទាំងនោះ សំពត់ស្លៀកមានតម្លៃ ៥០០ សំពត់ដណ្តប់មានតម្លៃ ១.០០០ ។ បទថា **ស្បែកជើងស (សេតា ឧបាហនា)** សេចក្តីថា ស្បែកជើងរមែងមានសម្រាប់មនុស្សដើរផ្លូវ ឬសម្រាប់មនុស្សចូល ព្រៃ ។ ចំណែកស្បែកជើងនេះ សម្រាប់ឡើងរថ ។ ដោយហេតុនោះ គប្បី

ជ្រាបថា នោះឈ្មោះថា គ្រឿងប្រដាប់ជើងរបស់គាត់លាយដោយប្រាក់ ដែលសមគួរដល់ស្បែកជើងនោះ លោកពោលទុកយ៉ាងនេះ ។ បទថា **ផ្ចិតរោមសត្វស (សេតាយ សុទំ វាលវីជនិយា)** សេចក្ដីថា ប្រដាប់បោសធូលី និងផ្ចិតរោមសត្វមានពណ៌ស មានដងធ្វើដោយកែវផលិក ។ ក៏ចំពោះគ្រឿងប្រដាប់ទាំងនេះស មានហើយដល់ព្រាហ្មណ៍នោះតែម្យ៉ាងប៉ុណ្ណោះក៏ទេ ។ សូម្បីគ្រឿងប្រដាប់របស់ព្រាហ្មណ៍នោះ បានធ្វើដោយប្រាក់ មានជាដើមយ៉ាងនេះថា ក៏ព្រាហ្មណ៍នោះលាប ដោយគ្រឿងលាបស ប្រដាប់ផ្កាឈើស ម្រាមដៃទាំង ១០ ពាក់ចិញ្ចៀន ត្រចៀកទាំងពីរពាក់ក្រវិល ដូច្នេះ ។ សូម្បីពួកព្រាហ្មណ៍ជាបរិវាររបស់គាត់ មានប្រមាណមួយម៉ឺន សំពត់ គ្រឿងលាប ផ្កាឈើ និងគ្រឿងប្រដាប់ស ក៏មានហើយដូចៗ គ្នា ។

[១៣] ចំណែកសេចក្ដីនោះ លោកពោលថា **ចេញចាកក្រុងសាវត្ថី (សាវត្ថិយា និយ្យាយន្តំ)** ដូច្នេះ សេចក្ដីជាក់ច្បាស់នៃការចេញទៅ (របស់ព្រាហ្មណ៍) ក្នុងសេចក្ដីនោះ មានដូចតទៅនេះ ៖

ពោលដោយកិច្ច ព្រាហ្មណ៍នោះ រមែងធ្វើប្រទក្សិណនគរ ៦ ខែម្ដង មនុស្សប្រកាសទុកជាមុនថា អំពីនេះទៅព្រាហ្មណ៍នឹងធ្វើប្រទក្សិណនគរដោយថ្ងៃទាំងឡាយប្រមាណប៉ុណ្ណេះ ជនពួកណា បានស្ដាប់ការប្រកាស

នោះហើយ កំពុងចេញពីនគរ ជនទាំងនោះនឹងមិនចេញទៅ ។ សូម្បីជនពួកណាចេញទៅហើយ សូម្បីជនពួកនោះ រមែងត្រឡប់មកវិញ ដោយគិតថា ពួកយើងនឹងបានឃើញនូវសិរិសម្បត្តិរបស់អ្នកមានបុណ្យ ។ ព្រាហ្មណ៍រមែងត្រាច់ទៅកាន់នគរហូតដល់ថ្ងៃណា អ្នកនគរទាំងឡាយបោសសម្អាតថ្នល់ក្នុងនគរក្នុងកាលនោះអំពីព្រឹកព្រលឹម ក្រាលខ្សាច់ រោយដោយផ្កាឈើទាំងឡាយ ដែលមានលាជជាគម្រប់ ៥ តាំងឆ្នាំងទឹក នាំគ្នាលើកដើមចេកទាំងឡាយ និងទង់ទាំងឡាយឡើង រមែងធ្វើនគរទាំងមូលឲ្យផ្សាយទៅដោយក្លិនធូប ។

ព្រាហ្មណ៍ជូតក្បាលអំពីព្រឹកព្រលឹម បរិភោគអាហារពេលព្រឹកហើយក៏តែងខ្លួនដោយគ្រឿងអាភរណៈមានសំពត់ស្លៀកសជាដើម ដោយន័យដូចពោលហើយនោះឯង ចុះចាកប្រាសាទឡើងយាន លំដាប់នោះព្រាហ្មណ៍ទាំងនោះ ក៏តាក់តែងដោយសំពត់ គ្រឿងលាប និងផ្កាឈើសទាំងអស់ កាន់ឆ័ត្រស ហែហមព្រាហ្មណ៍នោះឯង ។ តពីនោះ ជនទាំងឡាយរមែងបោះផល្លាផលដល់ពួកក្មេងជំទង់មុន ដើម្បីការប្រជុំរបស់មហាជន តពីនោះ ទើបបាចប្រាក់មាសក: តពីនោះ ទើបបាចកហាបណៈទាំងឡាយ ។ មហាជនរមែងប្រជុំគ្នា ការទះដៃហ៊ោ និងការគ្រវីសំពត់ក៏ប្រព្រឹត្តទៅ ពេលនោះ ព្រាហ្មណ៍

រមែងត្រាច់ទៅកាន់នគរដោយមហាសម្បត្តិ ពេលជនទាំងឡាយមានការត្រូវការដោយមង្គល និងត្រូវការសេចក្តីសុខជាដើម ធ្វើមង្គល និងសេចក្តីសុខហើយ ។ មនុស្សទាំងឡាយអ្នកមានបុណ្យ ឡើងទៅលើប្រាសាទមានជាន់មួយជាដើម បើកបង្អួចដូចជាស្វាបសេក ក្រលេកមើលហើយ សូម្បីព្រាហ្មណ៍រមែងមានមុខឆ្ពោះទៅទ្វារទិសខាងត្បូង ហាក់ដូចជាគ្រប់គ្រងនគរដោយយសនិងសិរិសម្បត្តិរបស់ខ្លួន ពាក្យនេះ លោកសំដៅដល់ប្រការនោះឯង ទើបពោល ។

បទថា ***មហាជនឃើញគេហើយ (តមេនំ ជនោ ទិស្វា)*** សេចក្តីថា មហាជនឃើញរថនោះ ។ បទថា ***ប្រសើរ (ព្រហ្មំ)*** បានដល់ ជាឈ្មោះរបស់បុគ្គលប្រសើរ ។ បទថា ***លោកដ៏ចម្រើនទាំងឡាយ យានដ៏ប្រសើរហ្ន៎ (ព្រហ្មំ វត ភោ យានំ)*** ក្នុងសេចក្តីនេះ មានអធិប្បាយដូច្នេះថា លោកដ៏ចម្រើនទាំងឡាយ យាននេះ ជាយានដ៏ប្រសើរហ្ន៎ ។

[១៤] បទថា ***ពាក្យនោះជា ឈ្មោះរបស់អរិយមគ្គនេះឯង (ឥមស្សេវ ខោ ឯតំ)*** សេចក្តីថា ម្នាលអានន្ទ ធម្មតាថា មនុស្សទាំងឡាយឲ្យទ្រព្យដល់អ្នកដែលពោលសរសើរហើយ រមែងឲ្យច្រៀងពោលសរសើរទារិកាទាំងឡាយរបស់ខ្លួនថា ជាអ្នកគួរស្រឡាញ់ គួរមើល មានទ្រព្យច្រើន មានភោគៈច្រើន

ដូច្នេះ តែក៏រកជាអ្នកគួរស្រឡាញ់ ឬមានភោគៈច្រើន ដោយត្រឹមតែការពោលសរសើរនោះក៏ទេ មហាជនឃើញរថរបស់ព្រាហ្មណ៍យ៉ាងនេះហើយ ទើបពោលសរសើរយ៉ាងនេះថា លោកដ៏ចម្រើនទាំងឡាយ យានដ៏ប្រសើរស្អប្បីនេះក៏ពិត តែយាននោះ នឹងឈ្មោះថា ជាយានប្រសើរដោយត្រឹមតែការពោលសរសើរក៏មិនមែន ដែលពិត យាននោះ ជារបស់លាមក អាក្រក់ ។ ម្នាលអានន្ទ តែដោយបរមត្ថ យាននោះ ជាឈ្មោះរបស់អរិយមគ្គមានអង្គ ៨ នេះប៉ុណ្ណោះ ។ ក៏អរិយមគ្គនេះប្រសើរ ព្រោះប្រាសចាកអំពីទោសទាំងពួង ព្រោះថា ព្រះអរិយៈទាំងឡាយរមែងទៅកាន់និព្វានដោយអរិយមគ្គនេះ ដូច្នោះ ទើបគួរពោលថា ព្រហ្មយានខ្លះ ជាធម្មយានខ្លះ ព្រោះជាធម៌ និងជាយាន ថារថពិជ័យសង្គ្រាមដ៏កំពូលខ្លះ ព្រោះមិនមានវត្ថុដែលក្រៃលែងជាង និងព្រោះឈ្នះសង្គ្រាម គឺ កិលេសហើយ ។

[១៥] ឥឡូវនេះ ព្រះមានព្រះភាគជាម្ចាស់ កាលទ្រង់សម្តែងអរិយមគ្គនោះមិនមានទោស និងជាពិជ័យសង្គ្រាម ទើបត្រាស់ពាក្យជាដើមថា **មានការកម្ចាត់រាគៈជាទីបំផុត** (រាគវិនយបរិយោសានា) ដូច្នេះ ។ ក្នុងបទនោះ **សម្មាទិដ្ឋិ** ពេលកម្ចាត់រាគៈឲ្យអស់ គឺ ឲ្យដល់ទីបំផុត បានដល់ រមែងសម្រេច ព្រោះហេតុនោះ ទើបឈ្មោះថា មានការកម្ចាត់រាគៈជាទីបំផុត ។

ក្នុងបទទាំងពួង ក៏ន័យនេះឯង ។

[២៤] បទថា **សទ្ធា និងបញ្ញា (យស្ស សទ្ធា ច បញ្ញា ច)** សេចក្តីថា សម្រាប់យាន គឺ អរិយមគ្គ មានធម៌ទាំង ២ នេះ គឺ សទ្ធា ដោយអំណាចនៃសទ្ធានុសារី និងបញ្ញា ដោយអំណាចនៃធម្មានុសារី ប្រកប គ្នាជានឹមគ្រប់កាល អធិប្បាយថា ប្រកបក្នុងនឹមមានខ្លួនជាកណ្តាល ក្នុង អរិយមគ្គនោះ ។ បទថា **មានហិរិជាជន្ទោល (ហិរិ ឦសា)** សេចក្តីថា ហិរិដែលកើតឡើងខាងក្នុង ព្រមជាមួយឱត្តប្បៈដែលកើតឡើងក្នុងខាងក្រៅ ប្រកបជាមួយ ជាជន្ទោលរបស់រថ គឺ មគ្គ ។ បទថា **មានចិត្តជាខ្សែបរ (មនោ យោត្តំ)** សេចក្តីថា វិបស្សនាចិត្ត និងមគ្គចិត្តជាខ្សែបរ ។ ដូចខ្សែ ដែលធ្វើដោយសំបកធ្មៃជាដើមរបស់រថ រមែងធ្វើគោទាំងឡាយឲ្យជាប់គ្នា គឺ ឲ្យរួមគ្នាបាន យ៉ាងណា វិបស្សនាចិត្តដែលជាលោកិយៈរបស់រថ គឺ មគ្គ មាន ៥០ ជាង វិបស្សនាចិត្តដែលជាលោកុត្តរៈ រមែងធ្វើកុសលធម៌ ៦០ ជាង ឲ្យជាប់គ្នា គឺ ឲ្យរួមគ្នាបានយ៉ាងនោះដូចគ្នា ព្រោះហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ ទើបត្រាស់ថា **មនោ យោត្តំ** ដូច្នេះ ។ បទថា **សតិជាសារថីអ្នកថែរក្សា (សតិ អារក្ខសារថិ)** សេចក្តីថា សតិសម្បយុត្ត ដោយមគ្គ ឈ្មោះថា សារថីអ្នកថែរក្សា ។ បុគ្គលណារប្រកបក្នុងការចាត់

ថែនកំណល់នឹម បន្ទក់ប្រេងក្ងៅ បញ្ជូនរថទៅ រមែងធ្វើសេះដែលទឹមក្នុង រថនោះឲ្យអស់អំណាច បុគ្គលនោះឈ្មោះថា សារថីអ្នករក្សា យ៉ាងណា សតិ របស់រថ គឺ មគ្គក៏ដូច្នោះ ។ លោកពោលថា សតិនេះ មានការរក្សាជាហេតុ ប្រាកដ និងរមែងពិចារណាគតិនៃធម៌ទាំងឡាយ ទាំងកុសល និងអកុសល ដូច្នេះ ។

បទថា **រថ (រថោ)** បានដល់ រថ គឺ អរិយមគ្គដែលប្រកបដោយអង្គ ៨ ។ បទថា **មានសីលជាគ្រឿងពាស (សីលបរិក្ខារោ)** សេចក្តីថា រថ មាន ចតុប្បារិសុទ្ធិសីលជាគ្រឿងប្រដាប់ ។ បទថា **មានឈានជាក្ងៅ (ឈានក្ខោ)** សេចក្តីថា មានក្ងៅធ្វើដោយឈាន ដោយអំណាចនៃអង្គឈាន ៥ សម្បយុត្ត ដោយវិបស្សនា ។ បទថា **មានសេចក្តីព្យាយាមជាកង់ (ចក្កវីរិយោ)** គឺ មានការព្យាយាមជាកង់ អធិប្បាយថា សេចក្តីព្យាយាម ២ ពោលគឺ ផ្លូវ កាយ និងផ្លូវចិត្ត ជាកង់របស់ការព្យាយាម ។ បទថា **មានឧបេក្ខាជាកំណល់ នឹម (ឧបេក្ខា ធុរសមាធិ)** សេចក្តីថា ទីភ្ជាប់របស់នឹម ឈ្មោះថា ធុរសមាធិ (កំណល់នឹម) អធិប្បាយថា ចំណែករបស់នឹមសូម្បីទាំងពីរស្មើគ្នា ព្រោះ មិនមានអាការឡើងចុះ ។ ចំណែក តត្រមជ្ឈត្តុបេក្ខានេះ រមែងនាំចិត្តប្បាទ ដែលនឿយណាយ និងរាយមាយចេញទៅ ទើបតម្កល់ចិត្តក្នុងកណ្តាលនៃ

ការប្រកបសេចក្តីព្យាយាម ព្រោះដូច្នោះ ព្រះអង្គទើបត្រាស់ថា ជាធុរ-សមាធិរបស់រថ គឺ មគ្គនេះ ។ បទថា **មានការមិនលោភជារនាំងបាំង (អនិជ្ឈា បរិវារណំ)** សេចក្តីថា ការមិនប្រាថ្នា ពោលគឺ អលោភៈ ឈ្មោះថា ជារនាំងបាំងរបស់រថ គឺ អរិយមគ្គ ដូចស្បែកកាជសីហ៍ជាដើម ជាគ្រឿងបិទបាំងខាងក្រៅរថ ដូច្នោះ ។

បទថា **ការមិនព្យាបាទ (អព្យាបាទោ)** បានដល់ មេត្តា និងចំណែកខាងដើមនៃមេត្តា ។ បទថា **ការមិនបៀតបៀន (អវិហឹសា)** បានដល់ករុណា និងចំណែកខាងដើមនៃករុណា ។ បទថា **សេចក្តីស្ងប់ស្ងាត់ (វិវេកោ)** បានដល់ វិវេក ៣ យ៉ាង មានកាយវិវេកជាដើម ។ បទថា **ជាអាវុធរបស់អរិយមគ្គណា (យស្ស អាវុធំ)** សេចក្តីថា អាវុធ ៥ យ៉ាង យ៉ាងនេះ រមែងមានដល់កុលបុត្តអ្នកស្ថិតនៅនៅក្នុងរថ គឺ អរិយមគ្គ បុគ្គលឈរនៅក្នុងរថ រមែងកម្ចាត់សត្រូវទាំងឡាយដោយអាវុធ ៥ បាន យ៉ាងណា សូម្បីយោគាវចរ ឈរនៅក្នុងរថនៃលោកិយមគ្គ និងលោកុត្តរមគ្គនេះ រមែងកំចាត់នូវទោសៈដោយមេត្តា កម្ចាត់ការបៀតបៀនដោយករុណា កម្ចាត់ការសេចក្តីស្និទ្ធស្នាលក្នុងគណៈដោយកាយវិវេក កម្ចាត់សេចក្តីស្និទ្ធស្នាលក្នុងកិលេសដោយចិត្តវិវេក នឹងកម្ចាត់អកុសលទាំងពួងដោយឧបធិវិវេក ដូច្នោះ

ដោយហេតុនោះ លោកទើបពោលថា អាវុធ ៥ យ៉ាងនោះ រមែងជារបស់កុលបុត្តនោះ ។ បទថា **សេចក្តីអត់ទ្រាំ (តីតិក្ខា)** សេចក្តីថា ការអត់ធន់ដោយការអត់ទ្រាំនឹងពាក្យរបស់បុគ្គលនិយាយអាក្រក់ ។ បទថា **ជាគ្រឿងក្រោះ (ចម្មសន្នាហោ)** បានដល់ មានស្បែកជាក្រោះ ដូចបុគ្គលមានអាវក្រោះស្បែក ឈរនៅលើរថ រមែងអត់ទ្រាំអំពីកូនសរទាំងឡាយដែលបាញ់មកហើយ កូនសរទាំងឡាយ រមែងកម្ចាត់បុគ្គលនោះមិនបាន យ៉ាងណាភិក្ខុអ្នកប្រកបដោយអធិវាសនខន្តី រមែងអត់ធន់នឹងពាក្យសំដីដែលមកហើយបាន ពាក្យទាំងនោះ រមែងចាក់ភិក្ខុអ្នកប្រកបដោយអធិវាសនខន្តីមិនបាន ដូច្នោះ ។ ព្រោះហេតុនោះ លោកទើបពោលថា សេចក្តីអត់ធន់ ជាក្រោះស្បែក ។ បទថា **រមែងប្រព្រឹត្តទៅដើម្បីសេចក្តីក្សេមចាកយោគៈ (យោគក្ខេមាយ វត្តតិ)** សេចក្តីថា រមែងបដិបត្តិដើម្បីសេចក្តីក្សេមចាកយោគៈ ៤ គឺ ដើម្បីព្រះនិព្វាន កុលបុត្តអ្នកប្រាថ្នាព្រះនិព្វាន រមែងដើរទៅតែម្យ៉ាង អធិប្បាយថា រមែងមិនឈប់ រមែងមិនទម្លាយ ដូច្នេះ ។

បទថា **យាននោះកើតក្នុងខ្លួន (ឯតទត្តនិ សម្ភូតំ)** សេចក្តីថា យាន គឺ មគ្គនោះ រមែងឈ្មោះថា កើតក្នុងខ្លួន ព្រោះអាស្រ័យការធ្វើតាមតម្រាប់អ្នកប្រាជ្ញទើបបាន ។ បទថា **ព្រហ្មយានដ៏កំពូល (ព្រហ្មយានំ អនុត្តរំ)**

បានដល់ យានដ៏ប្រសើ មិនមានយានដទៃក្រៃលែងជាង ។ បទថា **ជាអ្នកប្រាជ្ញរមែងចេញចាកលោក** (និយ្យន្តិ ធីរា លោកម្ហា) សេចក្តីថា យាននោះ រមែងមានដល់ជនពួកណា ជនពួកនោះជាអ្នកប្រាជ្ញ គឺ ជាពួកបណ្ឌិត រមែងចេញ គឺ រមែងទៅអំពីលោក ។ បទថា **ដោយពិត** (**អញ្ញទត្ថុ**) បានដល់ ដោយចំណែកមួយ ។ បទថា **មានជ័យជំនះ** (ជយំ ជយំ) សេចក្តីថា ឈ្នះហើយ នូវសត្រូវទាំងឡាយ មានរាគៈជាដើម ។

ចប់អដ្ឋកថា ព្រាហ្មណសូត្រទី ៤

# អ ដ្ឋ ក ថា

## កិមត្ថិយសូត្រទី ៥

*គប្បីជ្រាបវិនិច្ឆ័យក្នុង កិមត្ថិយសូត្រទី ៥*

*[២៨] ឯវ ស័ព្ទក្នុងបទថា **អយមេវ** មានអត្ថពិតប្រាកដ ។ រមែង មគ្គដទៃ ដោយ ឯវ ស័ព្ទនោះ ។ ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគជាម្ចាស់ ត្រាស់ទុក្ខក្នុងវដ្តៈ និងមគ្គលាយគ្នា ។*

ចប់អដ្ឋកថា កិមត្ថិយសូត្រទី ៥

---

*សូត្រទី ៦ មិនមានអដ្ឋកថា ។*

# អ ដ្ឋ ក ថា

## ទុតិយភិក្ខុសូត្រទី ៧

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយភិក្ខុសូត្រទី ៧*

*[៣១] បទថា **ម្នាលភិក្ខុ នុ៎ះជាឈ្មោះនៃនិព្វានធាតុ (និព្វានធាតុយា ខោ ឯតំ ភិក្ខុ អធិវចនំ)** សេចក្តីថា នោះជាឈ្មោះនៃព្រះនិព្វានធាតុ ដែលបច្ច័យតាក់តែងមិនបាន ជាអមតៈ ។ បទថា **លោកពោលថា ធម៌ជាទីអស់ទៅនៃអាសវៈ (អាសវានំ ខយោ តេន វុច្ចតិ)** លោកសម្តែងថាម្យ៉ាងទៀត ហៅថា ធម៌ជាទីអស់អាសវៈ ព្រោះការកម្ចាត់រាគៈជាដើមនោះចេញបាន ។ ព្រះអរហត្ត ឈ្មោះថា ការអស់ទៅនៃអាសវៈ ។ បទថា **ការកម្ចាត់រាគៈ (រាគវិនយោ)** ជាដើមនោះ ជាឈ្មោះរបស់ព្រះអរហត្តប៉ុណ្ណោះ ។ បទថា **បានក្រាបទូលរឿងនោះថា (ឯតទវោច)** សេចក្តីថា ព្រោះភិក្ខុនោះជាអ្នកឈ្លាសក្នុងអនុសន្ធិ ពេលទូលសួរ ទើបបានក្រាបទូលយ៉ាងនេះថា ព្រះសាស្តាពេលត្រាស់ថា ធាតុ ក៏ត្រាស់ព្រះនិព្វានដល់យើងហើយ ចំណែកផ្លូវនៃព្រះនិព្វាននោះ ព្រះអង្គទ្រង់មិនបានត្រាស់ យើងនឹងទូលឲ្យព្រះអង្គត្រាស់ផ្លូវនៃព្រះនិព្វាននោះ ទើបទូលសួរដូច្នេះ ។*

ចប់អដ្ឋកថា ទុតិយភិក្ខុសូត្រទី ៧

---

# អ ដ្ឋ ក ថា

## វិភង្គសូត្រទី ៨

*គប្បីជ្រាបវិនិច្ឆ័យក្នុង វិភង្គសូត្រទី ៨*

[៣៤] *បទថា* ***ម្នាលភិក្ខុទាំងឡាយ សម្មាទិដ្ឋិដូចម្តេច (កតមា ច ភិក្ខវេ សម្មាទិដ្ឋិ)*** *សេចក្តីថា ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ចែកមគ្គដែលប្រកបដោយអង្គ ៨ ដោយបរិយាយនោះហើយ ទ្រង់ផ្តើមទេសនានេះ ដូចទ្រង់បំណងចែកដោយបរិយាយដទៃទៀត ។*

*ក្នុងបទទាំងនោះ បទថា* ***ការដឹងក្នុងទុក្ខ (ទុក្ខេ ញាណំ)*** *សេចក្តីថា ញាណដែលកើតឡើងដោយអាការ ៤ គឺ ការស្តាប់ ១ ការពិចារណា ១ ការចាក់ធ្លុះ ១ ការត្រិះរិះ ១ ។ សូម្បីក្នុងសមុទយ ក៏មានន័យនេះដូចគ្នា ចំណែកក្នុងពីរបទដ៏សេស (និរោធ និងមគ្គ) ញាណ ៣ យ៉ាង ប៉ុណ្ណោះ រមែងគួរ ព្រោះការពិចារណាមិនមាន ។ កម្មដ្ឋានក្នុងសច្ចៈ ៤ នេះ ព្រះអង្គទ្រង់សម្តែងហើយដោយបទថា* ***ទុក្ខេ ញាណំ*** *ជាដើមដោយអាការយ៉ាងនេះ ។*

*ក្នុងបទទាំងនោះ សច្ចៈ ២ ខាងដើមជាវដ្តៈ ២ ខាងចុងជាវិវដ្តៈ ក្នុងវដ្តៈ និងវិវដ្តៈទាំងនោះ ការប្រកាន់មាំក្នុងកម្មដ្ឋានរបស់ភិក្ខុមានក្នុងវដ្តៈ*

ក្នុងវិវដ្ដៈការប្រកាន់មាំមិនមាន ។ ព្រះយោគាវចរពេលរៀនទូវសច្ចៈ ២ ខាងដើម ក្នុងសម្នាក់របស់អាចារ្យ សូត្រដោយវាចារឿយៗ ដោយសង្ខេបយ៉ាងនេះ **បញ្ចក្ខន្ធា ទុក្ខំ តណ្ហាសមុទយោ** និងដោយពិស្ដារ មានន័យជាដើមថា **កតមេ បញ្ចក្ខន្ធា រូបក្ខន្ធោ** ហើយទើបធ្វើកម្ម ។ ចំណែកក្នុងសច្ចៈ ២ ក្រៅនេះ លោករមែងធ្វើកម្មដោយការស្ដាប់យ៉ាងនេះថា និរោធ-សច្ចៈគួរប្រាថ្នា គួរស្រឡាញ់ គួរពេញចិត្ត , មគ្គសច្ចៈ គួរប្រាថ្នា គួរស្រឡាញ់ គួរពេញចិត្ត ។ កាលលោកធ្វើយ៉ាងនេះ រមែងចាក់ធ្លុះនូវសច្ចៈ ៤ ដោយបដិវេធតែម្យ៉ាង រមែងត្រាស់ដឹងដោយការត្រាស់ដឹងតែម្យ៉ាង រមែងចាក់ធ្លុះទុក្ខបានដោយការកំណត់ដឹង នូវសមុទយបានដោយការលះបង់ នូវនិរោធបានដោយការធ្វើឲ្យជាក់ច្បាស់ រមែងចាក់ធ្លុះមគ្គបានដោយការចម្រើន ។ រមែងត្រាស់ដឹងទុក្ខបានដោយការកំណត់ដឹង ។ល។ រមែងត្រាស់ដឹងមគ្គបានដោយការចម្រើន ។

ការរៀន ការសួរ ការស្ដាប់ ការទ្រទ្រង់ទុក ការពិចារណា និងការចាក់ធ្លុះ រមែងមានក្នុងសច្ចៈ ២ (ទុក្ខ សមុទយ) ក្នុងចំណែកខាងដើមនៃសច្ចៈ ៤ ដោយប្រការយ៉ាងនេះ ។ ការស្ដាប់ និងការចាក់ធ្លុះទាំងនោះ រមែងមានក្នុងសច្ចៈ ២ (និរោធ មគ្គ) ក្នុងកាលតមក ។ ពោលដោយកិច្ច

បដិវេធធម៌ រមែងមានក្នុងសច្ចៈ ៣ (ទុក្ខ សមុទយ មគ្គ) ។ ក្នុងនិរោធ មានបដិវេធជាអារម្មណ៍ ។ ចំណែកបដិវេធ រមែងមានដល់សច្ចៈ ៤ ដោយការពិចារណា ។ តែការកំណត់ក្នុងខាងដើម រមែងមិនមាន ។ ការកន្សល់ ការរួបរួម ការធ្វើទុកក្នុងចិត្ត និងការពិចារណា រមែងមិនមានដល់ភិក្ខុអ្នកកំណត់ហើយក្នុងខាងដើមថា យើងរមែងកំណត់ដឹងទុក្ខ រមែងលះសមុទយ រមែងធ្វើឲ្យជាក់ច្បាស់នូវនិរោធ យើងរមែងញ៉ាំងមគ្គឲ្យកើត ។ សេចក្ដីកន្សល់ជាដើមរមែងមាន ផ្ដើមអំពីការកំណត់ ។ តែក្នុងកាលតមក ទុក្ខលោកបានកំណត់ដឹងហើយ ។ល។ មគ្គ លោកធ្វើឲ្យកើតហើយ ។

ក្នុងសច្ចៈទាំង ៤ នោះ សច្ចៈ ២ ឈ្មោះថា ជាធម៌ជ្រាលជ្រៅ ព្រោះឃើញបានលំបាក ។ សច្ចៈ ២ ឈ្មោះថា ឃើញបានលំបាក ព្រោះជាធម៌ជ្រាលជ្រៅ ។ ពិតណាស់ ទុក្ខសច្ចៈក៏ប្រាកដបាន ព្រោះការកើតឡើង រមែងដល់សូម្បីនូវសភាពដែលខ្ជួនគប្បីពោលថា ទុក្ខហ្ន៎ ក្នុងការប៉ះដន្គត់ និងបន្ទាជាដើម ។ សូម្បីសមុទយក៏ប្រាកដបាន ព្រោះការកើតឡើង ដោយអំណាចសេចក្ដីប្រាថ្នាដើម្បីទឹងទំពារស៊ី និងបរិភោគជាដើម ។ តែថា ដោយការចាក់ធ្លុះដល់លក្ខណៈទុក្ខ និងសមុទយសច្ច សូម្បីទាំងពីរ ជាធម៌ជ្រាលជ្រៅ ។ សច្ចៈទាំងនោះ ឈ្មោះថា ជាធម៌ដែលជ្រាលជ្រៅ ព្រោះ

ឃើញបានលំបាក ដោយប្រការដូច្នេះ ។ សេចក្ដីព្យាយាម ដើម្បីត្រូវការ ឃើញសច្ចៈទាំងពីរក្រៅពីនេះ (និរោធ មគ្គ) រមែងដូចការលូកដៃទៅដើម្បី ចាប់ភវគ្គព្រហ្ម ដូចការសណ្ដូកជើងទៅដើម្បីពាល់ត្រូវអវិចី និងដូចការ ញ៉ាំងចុងនៃរោមសត្វដែលជា ៧ ចំណែក ឲ្យមករួមគ្នា ។ សច្ចៈទាំងនោះ ឈ្មោះថា ជាធម៌ជ្រាលជ្រៅ ព្រោះឃើញបានលំបាកដោយប្រការដូច្នេះ ។ បទជាដើមថា **ទុក្ខេ ញាណំ** នេះ ព្រះមានព្រះភាគជាម្ចាស់ ត្រាស់ហើយ ដោយអំណាចការរៀនជាដើម ក្នុងសច្ចៈ ៤ ឈ្មោះថា ជាធម៌ជ្រាលជ្រៅ ព្រោះឃើញបានលំបាក និងឈ្មោះថា ជាធម៌ឃើញបានលំបាក ព្រោះជា ធម៌ជ្រាលជ្រៅ ដោយប្រការដូច្នេះ ។ ចំណែកញាណនោះ រមែងមានយ៉ាង នេះឯង ក្នុងលក្ខណៈនៃបដិវេធ ។

[៣៥] គប្បីជ្រាបក្នុងបទ **នេក្ខម្មសង្កប្បៈ** ជាដើម ឈ្មោះថា ការ ត្រិះរិះក្នុងការចេញចាកកាម ព្រោះភាវៈដែលចេលចាកកាម ព្រោះអត្ថថា ជាសត្រូវដល់កាមខ្លះ ព្រោះកើតឡើងហើយដល់អ្នកពិចារណាកាមដូច្នេះខ្លះ ព្រោះកាលធ្វើការកម្ចាត់កាម ឲ្យកាមស្ងប់ ក៏កើតឡើងដូច្នេះខ្លះ ព្រោះកាល ស្ងាត់អំពីកាម ក៏កើតឡើងដូច្នេះខ្លះ ។ សូម្បីក្នុងពីរបទដ៏សេស ក៏មានន័យ នេះដូចគ្នា ចំណែកធម៌មាននេក្ខម្មសង្កប្បៈជាដើមទាំងអស់នោះ ឈ្មោះថា

ផ្សេងគ្នាក្នុងចំណែកខាងដើម ព្រោះន័យក្នុងការវៀរចាកកាម ចាកព្យាបាទ និងចាកវិហឹង្សា មានសភាពផ្សេងគ្នា ។ ចំណែកក្នុងខណៈនៃមគ្គ ការត្រិះរិះក្នុងកុសលតែម្យ៉ាងប៉ុណ្ណោះ រមែងកើតឡើង ញុំាងអង្គនៃមគ្គឲ្យបរិបូណ៌ ដោយអំណាចឲ្យសម្រេចការមិនកើតឡើង ព្រោះខុសគ្នានឹងបទនៃការត្រិះរិះក្នុងអកុសល ដែលកើតហើយក្នុងឋានៈទាំង ៣ នេះ នេះឈ្មោះថា **សម្មា-សង្កប្បៈ** ។

[៣៦] ធម៌មានចេតនា ជាគ្រឿងវៀរចាកការនិយាយកុហកជាដើម ឈ្មោះថា ផ្សេងគ្នាក្នុងចំណែកខាងដើម ព្រោះន័យក្នុងការវៀរចាកការនិយាយកុហកជាដើម មានសភាពផ្សេងគ្នា ។ ចំណែកក្នុងខណៈនៃមគ្គ ចេតនាជាគ្រឿងវៀរ ជាកុសលតែម្យ៉ាងប៉ុណ្ណោះ រមែងកើតឡើង ញុំាងអង្គមគ្គឲ្យបរិបូណ៌ ដោយអំណាចឲ្យសម្រេចការមិនកើតឡើង ព្រោះផ្ទុយគ្នានឹងបទចេតនាជាគ្រឿងទ្រុស្តសីល ដែលជាកុសល ដែលកើតឡើងក្នុងឋានៈទាំង ៤ នេះ នេះឈ្មោះថា **សម្មាវាចា** ។

[៣៧] ធម៌សូម្បីមានចេតនាជាគ្រឿងវៀរចាកបាណាតិបាតជាដើម ឈ្មោះថា ផ្សេងគ្នាក្នុងចំណែកខាងដើម ព្រោះន័យក្នុងការវៀរចាកបាណា-តិបាតជាដើម មានសភាពផ្សេងគ្នា ។ ចំណែកក្នុងខណៈនៃមគ្គ ចេតនាជា

គ្រឿងវៀរជាកុសលតែម្យ៉ាង រមែងកើតឡើង ញុំាងអង្គនៃមគ្គឲ្យបរិបូណ៌ ដោយអំណាចឲ្យសម្រេចការមិនកើតឡើង ព្រោះផ្ទុយគ្នាជាមួយបទដោយមិនធ្វើចេតនាជាគ្រឿងទ្រុស្តសីលជាអកុសល ដែលកើតឡើងក្នុងឋានៈទាំង ៣ ដូច្នេះ នេះឈ្មោះថា **សម្មាកម្មន្តៈ** ។

[៣៨] បទថា **ការចិញ្ចឹមជីវិតខុស (មិច្ឆាអាជីវំ)** បានដល់ ទុច្ចរិតផ្លូវកាយ និងផ្លូវវាចា ដែលខ្លួនឲ្យប្រព្រឹត្តទៅហើយ ដើម្បីត្រូវការរបស់គួរទំពារ និងរបស់គួរបរិភោគជាដើម ។ បទថា **លះ (បហាយ)** គឺ វៀរ ។ បទថា **ចិញ្ចឹមជីវិតត្រូវ (សម្មាអាជីវេន)** បានដល់ ដោយការចិញ្ចឹមជីវិតដែលព្រះពុទ្ធជាម្ចាស់សរសើរហើយ ។ បទថា **សម្រេចនូវការចិញ្ចឹមជីវិត (ជីវិតំ កប្បេតិ)** សេចក្តីថា រមែងញុំាងជីវិតឲ្យប្រព្រឹត្តទៅ សូម្បីសម្មាអាជីវៈឈ្មោះថា ផ្សេងគ្នាក្នុងខាងដើម ព្រោះន័យក្នុងការវៀរចាកការបោកបញ្ឆោតជាដើមមានប្រការផ្សេងគ្នា ។ ចំណែកក្នុងខណៈនៃមគ្គ ចេតនាជាគ្រឿងវៀរចាក ជាកុសលតែម្យ៉ាង រមែងកើតឡើង ញុំាងអង្គនៃមគ្គឲ្យបរិបូណ៌ ដោយអំណាចឲ្យសម្រេចការមិនកើតឡើង ព្រោះផ្ទុយគ្នាជាមួយបទចេតនាជាគ្រឿងទ្រុស្តសីលជាមិច្ឆាជីវៈ ដែលកើតឡើងក្នុងឋានៈទាំង ៧ នេះឯង នេះឈ្មោះថា **សម្មាអាជីវៈ** ។

[៣៩] បទថា **ដែលមិនទាន់កើតឡើង (អនុប្បន្នានំ)** សេចក្តីថា ឃើញអារម្មណ៍ទាំងឡាយបែបនោះក្នុងផ្ទះមួយ រមែងញុំាងឆន្ទៈឲ្យកើត ដើម្បីការមិនកើតឡើងនៃអកុសលធម៌ដែលជាបាប ដែលមិនទាន់កើតឡើងដល់ខ្លួន ឬថា ឃើញអារម្មណ៍ទាំងឡាយ ដែលកំពុងកើតឡើងដល់អ្នកដទៃ រមែងញុំាងឆន្ទៈឲ្យកើត ដើម្បីការមិនកើតឡើងនៃអកុសលធម៌ដែលជាបាប ដែលមិនទាន់កើតឡើង យ៉ាងនេះថា ឱហ្ន៎ ធម៌ដែលជាបាបបែបនេះ មិនគប្បីកើតឡើងដល់យើង ដូច្នេះ ។ បទថា **សេចក្តីពេញចិត្ត (ឆន្ទំ)** សេចក្តីថា រមែងញុំាងវីរិយឆន្ទៈជាហេតុឲ្យសម្រេចនៃការបដិបត្តិ មិនឲ្យអកុសលធម៌ទាំងនោះកើតឡើង ឲ្យកើតឡើង ។ បទថា **ព្យាយាម (វាយមតិ)** បានដល់ រមែងធ្វើការព្យាយាម ។ បទថា **ប្រារព្ធសេចក្តីព្យាយាម (វីរិយអារភតិ)** បានដល់ រមែងញុំាងការព្យាយាមឲ្យប្រព្រឹត្ត ។ បទថា **ផ្គងចិត្ត (ចិត្តំ បគ្គណ្ហាតិ)** សេចក្តីថា រមែងធ្វើចិត្តដែលសេចក្តីព្យាយាមផ្គងទុកហើយ ។ បទថា **តាំងចិត្ត (បទហតិ)** សេចក្តីថា រមែងញុំាងសេចក្តីព្យាយាមឲ្យប្រព្រឹត្តទៅថា ស្បែក សសៃ និងឆ្អឹងរីងស្ងួតទៅក៏ដោយចុះ ។ បទថា **ដែលកើតឡើង (ឧប្បន្នានំ)** សេចក្តីថា ធ្លាប់កើតឡើងហើយដល់ខ្លួន ដោយអំណាចសេចក្តីរាយមាយ រមែងញុំាងឆន្ទៈឲ្យកើត ដើម្បីលះបង់

អកុសលធម៌ទាំងនោះ ដោយគិតថា ឥឡូវនេះ យើងនឹងមិនឲ្យអកុសល-ធម៌ទាំងឡាយដូច្នោះកើតឡើង ។

បទថា **កុសលដែលនៅមិនទាន់កើតឡើង (អនុប្បន្នានំ កុសលានំ)** សេចក្តីថា កុសលធម៌ មានបឋមជ្ឈានជាដើម ដែលមិនទាន់បាន ។ បទថា **ដែលកើតឡើង (ឧប្បន្នានំ)** បានដល់ កុសលធម៌ទាំងនោះឯង ដែលខ្លួនបានហើយ ។ បទថា **តាំងមាំ (ឋិតិយា)** សេចក្តីថា ដើម្បីសេចក្តីតាំងមាំ ដោយអំណាចការកើតឡើងជាប់តគ្នារឿយៗ ។ បទថា **មិនភ្លេចភ្លាំង (អ-សម្មោសាយ)** បានដល់ ដើម្បីការមិនសាបសូន្យ ។ បទថា **ដើម្បីចម្រើន (ភិយ្យោភាវាយ)** បានដល់ ដើម្បីខ្ពស់ឡើងទៅ ។ បទថា **ធំទូលាយ (វេបុល្លាយ)** បានដល់ ដើម្បីភាពធំទូលាយ ។ បទថា **បរិបូរ (បារិបូរិយា)** បានដល់ ដើម្បីឲ្យការនៅបរិបូណ៌ ។ សម្មាវាយាមៈនេះ ឈ្មោះថា ផ្សេងគ្នាក្នុងចំណែកខាងដើម ព្រោះអកុសលធម៌ញុំាងដែលមិនទាន់កើត គិតមិនឲ្យកើតជាដើម មានសភាពផ្សេងគ្នា ។ ចំណែកក្នុងខណៈនៃមគ្គ ការព្យាយាមជាកុសលតែម្យ៉ាងនោះឯង រមែងកើតឡើង ញុំាងអង្គមគ្គឲ្យបរិបូណ៌ ដោយអំណាចឲ្យសម្រេចកិច្ចក្នុងឋានៈទាំង ៤ នេះឈ្មោះថា **សម្មាវាយាមៈ** ។

[៤០] សូម្បីសម្មាសតិ ឈ្មោះថា ផ្សេងគ្នាក្នុងចំណែកខាងដើម ព្រោះ

ការផ្សេងគ្នានៃចិត្តកំណត់កាយជាដើម ។ ចំណែកក្នុងខណៈនៃមគ្គ សតិតែម្យ៉ាង រមែងកើតឡើងញុំាងអង្គនៃមគ្គឲ្យបរិបូណ៌ហើយ ដោយអំណាចឲ្យសម្រេចកិច្ចក្នុងឋានៈ ៤ ទាំងនេះ នេះឈ្មោះថា **សម្មាសតិ** ។

[៤១] គប្បីជ្រាបក្នុងឈានជាដើម ក្នុងចំណែកខាងដើម **សម្មាសមាធិ** ផ្សេងគ្នាដោយអំណាចសមាបត្តិ ក្នុងខណៈនៃមគ្គ ដោយអំណាចមគ្គដែលផ្សេងគ្នា ។ ពិតហើយ បឋមមគ្គរបស់ឈានមួយយ៉ាង រមែងមានបឋមឈានជាចំណែកប្រកប សូម្បីទុតិយមគ្គជាដើម មានបឋមឈាន ឬមានឈានណាមួយក្នុងទុតិយឈានជាដើមជាចំណែកប្រកប បឋមមគ្គរបស់ឈានមួយយ៉ាង រមែងមានឈានណាមួយនៃទុតិយឈានជាដើម ។ សូម្បីទុតិយមគ្គជាដើម មានឈានណាមួយនៃទុតិយឈានជាដើម ឬមានបឋមឈានជាចំណែកប្រកប ។ មគ្គទាំង ៤ នឹងដូចគ្នា មិនដូចគ្នា ឬដូចគ្នាខ្លះ រមែងមានដោយអំណាចនៃឈានយ៉ាងនេះឯង ។

ចំណែកការផ្សេងគ្នានៃមគ្គនេះ រមែងមានដោយការកំណត់ឈានដែលជាបាទ ។ ពិតណាស់ មគ្គដែលកើតឡើងដល់អ្នកបានបឋមឈានចេញចាកបឋមឈានហើយ ឃើញច្បាស់ រមែងមានបឋមឈានដោយការកំណត់ឈានដែលជាបាទ ។ ចំណែកក្នុងឈាននេះ រមែងមានអង្គនៃមគ្គ

ពោជ្ឈង្គ: និងឈានបរិបូណ៌ហើយ ។ មគ្គដែលកើតឡើងដល់អ្នកចេញចាកទុតិយឈាន ហើយឃើញច្បាស់ រមែងមានទុតិយឈានជាបាទ ។ ចំណែកក្នុងឈាននេះ អង្គមគ្គមាន ៧ ។ មគ្គដែលកើតឡើងដល់អ្នកចេញចាកតតិយឈាន ឃើញច្បាស់ហើយ រមែងមានតតិយឈានជាបាទ ក៏ក្នុងឈាននេះ មានអង្គមគ្គ ៧ ពោជ្ឈង្គ:មាន ៦ ។ តាំងពីចតុត្ថឈានរហូតដល់នេវសញ្ញានាសញ្ញាយតន: ក៏មានន័យនេះ ។

ចតុក្កជ្ឈាន និងបញ្ចមកជ្ឈានក្នុងអរូបឈានរមែងកើតឡើង និងឈាននោះ លោកពោលថា ជាលោកុត្តរ: មិនមែនជាលោកិយ: ដូច្នេះ ។

សួរថា ក្នុងសេចក្តីនោះដូចម្តេច?

ឆ្លើយថា មគ្គនោះកើតឡើងហើយក្នុងអរូបជ្ឈាន ព្រោះចេញចាកឈានណា ក្នុងបឋមជ្ឈានជាដើម បានសោតាបត្តិមគ្គ ចម្រើនអរូបសមាបត្តិ ។ មគ្គ ៣ មានឈាននោះៗ ជាបាទ រមែងកើតឡើងក្នុងអរូបជ្ឈាននោះ ។ ឈានដែលជាបាទ រមែងកំណត់យ៉ាងនេះឯង ។ ចំណែកព្រះថេរ: ពួកខ្លះរមែងពោលថា កំណត់ខន្ធជារម្មណ៍របស់វិបស្សនា ។ ពួកខ្លះពោលថា កំណត់អធ្យាស្រ័យរបស់បុគ្គលជាអារម្មណ៍របស់វិបស្សនា ។ ពួកខ្លះរមែងពោលថា វុដ្ឋានគាមិនីវិបស្សនាជាគ្រឿងកំណត់ ។ ការវិនិច្ឆ័យក្នុង

*វាទៈរបស់ព្រះថេរៈទាំងនោះ គប្បីជ្រាប ដោយន័យដែលពោលទុកហើយក្នុងអធិការពោលដោយវុដ្ឋានគាមិនីវិបស្សនា ក្នុងវិសុទ្ធិមគ្គ ។ បទថា **ភិក្ខុទាំងឡាយ នេះហៅថា សម្មាសមាធិ (អយំ វុច្ចតិ ភិក្ខវេ សម្មាសមាធិ)** ដូច្នេះ នេះជាលោកិយៈក្នុងចំណែកខាងដើម ក្នុងចំណែកខាងចុងជាលោកុត្តរៈ លោកហៅថា **សម្មាសមាធិ** ។*

ចប់អដ្ឋកថា វិភង្គសូត្រទី ៨

# អ ដ្ឋ ក ថា

## សុកសូត្រទី ៩

*គប្បីជ្រាបវិនិច្ឆ័យក្នុង សុកសូត្រទី ៩*

[៤២] *បទថា* ***ដែលបុគ្គលតម្កល់ទុកខុស (មិច្ឆាបណិហិតំ)*** *សេចក្តីថា ឈ្មោះថា ខ្នាយ គេតាំងចុងឡើងលើ រមែងមុតដៃ ឬជើង តែមិនតាំងទុកយ៉ាងនោះ ឈ្មោះថា តាំងទុកខុស ។ បទថា* ***ដោយការឃើញដែលជាទីតម្កល់ទុកខុស (មិច្ឆាបណិហិតាយ ទិដ្ឋិយា)*** *បានដល់ ដោយកម្មស្សកតប្បញ្ញាដែលតាំងទុកខុស ។ បទថា* ***នឹងទម្លាយអវិជ្ជា (អវិជ្ជំ ភេច្ឆតិ)***[១] *សេចក្តីថា នឹងទម្លាយអវិជ្ជាដែលបិទបាំងសច្ចៈ ៤ ។ បទថា* ***ធ្វើវិជ្ជាឲ្យកើតឡើង (វិជ្ជំ ឧប្បាទេស្សតិ)*** *សេចក្តីថា នឹងញ៉ាំងវិជ្ជា គឺ អរហត្តមគ្គឲ្យកើតឡើង ។ បទថា* ***ម្នាលភិក្ខុទាំងឡាយ ព្រោះការឃើញដែលតម្កល់ទុកខុស (មិច្ឆាបណិហិតត្តា ភិក្ខវេ ទិដ្ឋិយា)*** *សេចក្តីថា ព្រោះកម្មស្សកតប្បញ្ញា និងមគ្គភាវនាដែលតម្កល់ទុកខុស គឺ ព្រោះមិនប្រព្រឹត្តតាមកម្មស្សកតប្បញ្ញា និងមគ្គភាវនា ។ ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគជាម្ចាស់*

---

*១-បាលីបិដក អវិជ្ជំ ភិន្ទិស្សតិ ។*

*ទ្រង់ធ្វើកម្មស្សកតាញាណឲ្យអាស្រ័យមគ្គហើយ ទើបត្រាស់មគ្គលាយគ្នា ។*

ចប់អដ្ឋកថា សុកសូត្រទី ៩

# អ ដ្ឋ ក ថា

## នន្ទិយសូត្រទី ១០

*គប្បីជ្រាបវិនិច្ឆ័យក្នុង នន្ទិយសូត្រទី ១០*

*[៤៥] បទថា បរិព្វាជកោ បានដល់ បរិព្វាជកអ្នកស្លៀកសំពត់ ។ ពាក្យដ៏សេសក្នុងនន្ទិយសូត្រនេះ ងាយទាំងអស់នោះឯង ។*

ចប់អដ្ឋកថា នន្ទិយសូត្រទី ១០

## ចប់អវិជ្ជាវគ្គទី ១

## រួមអដ្ឋកថាក្នុងវគ្គនេះ គឺ

១ អដ្ឋកថា អវិជ្ជាសូត្រ
២ អដ្ឋកថា ឧបឌ្ឍសូត្រ
៣ អដ្ឋកថា សារីបុត្តសូត្រ
៤ អដ្ឋកថា ព្រាហ្មណសូត្រ
៥ អដ្ឋកថា កិមត្ថិយសូត្រ
៦ អដ្ឋកថា ទុតិយភិក្ខុសូត្រ
៧ អដ្ឋកថា វិភង្គសូត្រ
២ អដ្ឋកថា សុកសូត្រ
៩ អដ្ឋកថា នន្ទិយសូត្រ

# វិហារវគ្គទី ២

## អ ដ្ឋ ក ថា

### បឋមវិហារសូត្រទី ១

*គប្បីជ្រាបវិនិច្ឆ័យក្នុង វិហារសូត្រទី ១ នៃ វិហារវគ្គទី ២*

[៤៧] *បទថា ម្នាលភិក្ខុទាំងឡាយ តថាគតប្រាថ្នាដើម្បីសម្ងំនៅក្នុងទីស្ងាត់កន្លះខែ (ឥច្ឆាមហំ ភិក្ខវេ អឌ្ឍមាសំ បដិសល្លីយិតុំ) សេចក្តីថា ម្នាលភិក្ខុទាំងឡាយ តថាគតប្រាថ្នានឹងពួនសម្ងំនៅក្នុងកន្លែងស្ងាត់អស់កន្លះខែ ។ បទថា នរណាៗ កុំគប្បីចូលទៅរកតថាគត ក្រៅពីភិក្ខុអ្នកនាំបិណ្ឌ-បាតមួយរូប (នម្ហិ កេនចិ ឧបសង្កមិតព្វោ អញ្ញត្រ ឯកេន បិណ្ឌបាតនី-ហារកេន) សេចក្តីថា ភិក្ខុណាមិនធ្វើវាចាដែលខ្វល់ខ្វាយដើម្បីខ្លួន គប្បីនាំបិណ្ឌបាតដែលតាក់តែងក្នុងត្រកូលទាំងឡាយ ដែលមានសទ្ធាទៅដើម្បីប្រយោជន៍ដល់តថាគត គប្បីបង្អោនទៅដើម្បីតថាគត នរណាៗ ដទៃ នឹងជាភិក្ខុ ឬគ្រហស្ថ មិនគប្បីចូលទៅរកតថាគត ក្រៅពីភិក្ខុអ្នកនាំបិណ្ឌបាតទៅឲ្យតែមួយរូប ។*

សួរថា "ក៏ព្រោះហេតុអ្វី? ព្រះមានព្រះភាគជាម្ចាស់ទើបត្រាស់យ៉ាងនេះ?" ។

ឆ្លើយថា "បានឮថា ក្នុងកន្លះខែនោះ សត្វដែលព្រះអង្គគប្បីណែនាំមិនមាន" ។ ព្រោះដូច្នោះ ព្រះសាស្ដាទ្រង់ត្រិះរិះថា តថាគតនឹងញ៉ាំងកន្លះខែនេះឲ្យកន្លងទៅដោយសុខដែលកើតពីផលសមាបត្តិ ការនៅជាសុខនឹងមានដល់តថាគតដោយអាការយ៉ាងនេះ និងក្នុងអនាគត ជនជំនាន់ក្រោយនឹងដឹងថា សូម្បីព្រះសាស្ដាក៏ទ្រង់លះបង់ពួកគណៈទៅ ប្រថាប់នៅតែមួយព្រះអង្គ នឹងពោលថ្វីដល់ពួកយើង ប្រការនោះ នឹងមានដើម្បីប្រយោជន៍ដើម្បីសេចក្ដីសុខដល់បច្ឆិមជននោះ អស់កាលយូរ ដូច្នេះ ទើបត្រាស់យ៉ាងនេះ ដោយហេតុនេះ ។ សូម្បីភិក្ខុសង្ឃទូលទទួលតម្រាស់របស់ព្រះសាស្ដាហើយ ទើបបានថ្វាយភិក្ខុមួយរូប ភិក្ខុរូបនោះធ្វើកិច្ចទាំងពួង មានការបោសសម្អាតបរិវេណព្រះគន្ធកុដិ ថ្វាយទឹកស្រង់ព្រះភ័ក្ត្រ និងឈើជម្រះព្រះទន្តជាដើមតាំងពីព្រឹកស្រេចហើយ ក៏ចៀសចេញទៅក្នុងខណៈនោះ ។

[៤៨] បទថា **យេន ស្វាហំ** កាត់បទជា **យេន សុ អហំ** ។ បទថា **ត្រាស់ដឹងដំបូង (បឋមាភិសម្ពុទ្ធោ)** សេចក្ដីថា តថាគតបានត្រាស់ដឹង គ្រាដំបូង នៅដោយវិហារធម៌ក្នុងខាងក្នុង ៤៩ ថ្ងៃ ។ បទថា **រមែងនៅ (វិហរាមិ)**

នេះ ជាពាក្យបច្ចុប្បន្នចុះក្នុងអត្ថរបស់អតីត ។ បទថា **ដោយចំណែកនៃវិហារធម៌នោះ (តស្ស បទេសេន)** សេចក្ដីថា ដោយចំណែកនៃវិហារធម៌ត្រាស់ដឹងដំបូងនោះ ។ ចំណែកនៃខន្ធ ចំណែកនៃអាយតនៈ ធាតុ សច្ចៈ ឥន្ទ្រិយ៍ បច្ចយាការ សតិប្បដ្ឋាន ឈាន និងនាមរូប ចំណែកនៃធម៌មានផ្សេងៗ គ្នា ឈ្មោះថា ចំណែកក្នុងវិហារធម៌នោះ ។ ព្រះអង្គទ្រង់សំដៅដល់ចំណែកនៃធម៌សូម្បីទាំងអស់នោះ ទើបត្រាស់ថា **តស្ស បទេសេន វិហាសី** ដូច្នេះ ។

ក៏ក្នុងបឋមពោធិកាល ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ពិចារណាខន្ធ ៥ គ្រប់ចំណែកក្នុងខាងក្នុង ៤៩ ថ្ងៃ ដូចព្រះរាជាទ្រង់គ្រប់គ្រងរាជសម្បត្តិហើយ ទ្រង់ត្រាស់ឲ្យបើកឃ្លាំងនោះៗ ដើម្បីទតសម្បត្តិដែលមានខ្លឹមសាររបស់ព្រះអង្គ គប្បីពិចារណានូវរតនៈទាំងឡាយ មានមាស ប្រាក់ កែវមុក្តា និងកែវមណីជាដើម ដូច្នោះ ។ ចំណែកក្នុងកន្លះខែនេះ ទ្រង់ពិចារណានូវវេទនាខន្ធប៉ុណ្ណោះ ដែលជាចំណែកនៃខន្ធទាំងនោះ ។ កាលព្រះអង្គទ្រង់ប្រមើលមើលសត្វទាំងឡាយនេះ រមែងសោយនូវសុខបែបនេះ សោយនូវទុក្ខបែបនេះ ដូច្នេះ សុខវេទនាប្រព្រឹត្តទៅហើយរហូតដល់ភវគ្គព្រហ្ម ទុក្ខ-វេទនាប្រព្រឹត្តទៅហើយរហូតដល់អវិចី ទាំងអស់ប្រាកដហើយដោយអាការ

ទាំងពួង ។ តមក ទ្រង់នៅកំណត់វេទនានោះ ដោយន័យជាដើមថា វេទនារមែងមាន ព្រោះការឃើញខុសជាប្បច្ច័យខ្លះដូច្នេះ ។ ក្នុងបឋមពោធិកាល ទ្រង់ធ្វើអាយតនៈ ១២ ឲ្យអស់គ្រប់ចំណែកយ៉ាងនោះ ។ ក៏ក្នុងកន្លះខែនេះ ព្រះអង្គទ្រង់ពិចារណានូវចំណែកមួយនៃធម្មាយតនៈ ដោយអំណាចវេទនាដែលជាចំណែកនៃអាយតនៈប៉ុណ្ណោះ ។ នូវចំណែកមួយនៃធម្មធាតុ ដោយអំណាចវេទនា ដែលជាចំណែកនៃធាតុទាំងឡាយ ។ នូវចំណែកមួយនៃទុក្ខសច្ចៈ ដោយអំណាចវេទនាខន្ធប៉ុណ្ណោះ ដែលជាចំណែកនៃសច្ចៈទាំងឡាយ ។ នូវចំណែកមួយនៃបច្ច័យដោយអំណាចវេទនាប៉ុណ្ណោះ ព្រោះមានផស្សៈជាបច្ច័យ ដែលជាចំណែកនៃបច្ច័យទាំងឡាយ ។ នូវចំណែកមួយនៃអង្គឈានដោយអំណាចវេទនាប៉ុណ្ណោះ ដែលជាចំណែកនៃឈានទាំងឡាយ ទ្រង់ពិចារណានូវចំណែកមួយនៃនាម ដោយអំណាចវេទនាប៉ុណ្ណោះ ដែលជាចំណែកនៃនាម និងរូប ។

ម្យ៉ាងទៀត ក្នុងបឋមពោធិកាល ទ្រង់ធ្វើធម៌ មានកុសលជាដើម ឲ្យអស់គ្រប់ចំណែកក្នុងខាងក្នុង ៤៩ ថ្ងៃ ស្រេចហើយ ទ្រង់ពិចារណានូវបករណ៍ ៧ ដែលជានន្តនន័យ ។ តែក្នុងកន្លះខែនេះ ព្រះអង្គទ្រង់ពិចារណានូវពួក ៣ នៃវេទនាតែម្យ៉ាងដែលជាចំណែកនៃធម៌ទាំងពួង ។ វិហារសមា-

បត្តិនោះៗ ក្នុងទីនោះៗ កើតហើយដោយអានុភាពនៃវេទនា ។

ឥឡូវនេះ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់នៅហើយដោយអាការណា កាលនឹងទ្រង់សម្ដែងអាការនោះ ទើបត្រាស់ពាក្យថា **មិច្ឆាទិដ្ឋិប្បច្ចយាបិ** ជាដើម ។ ក្នុងបទទាំងនោះ បទថា **ព្រោះការឃើញខុសជាបច្ច័យខ្លះ (មិច្ឆាទិដ្ឋិបច្ចយាបិ)** សេចក្ដីថា សូម្បីវេទនាសម្បយុត្តដោយទិដ្ឋិ រមែងគួរ ។ វេទនាដែលជាកុសល និងអកុសលខ្លះ វេទនាដែលជាវិបាកខ្លះ កើតឡើងព្រោះធ្វើទិដ្ឋិឲ្យជាឧបនិស្ស័យ រមែងគួរ ។ ក្នុងបទនោះ វេទនាសម្បយុត្តដោយមិច្ឆាទិដ្ឋិ រមែងជាអកុសលតែម្យ៉ាង ។ ចំណែកវេទនាជាកុសលខ្លះ អកុសលខ្លះ រមែងកើតឡើង ព្រោះអាស្រ័យទិដ្ឋិ ។ ព្រោះពួកមិច្ឆាទិដ្ឋិអាស្រ័យទិដ្ឋិហើយ រមែងឲ្យបបរ និងកត្តជាដើមក្នុងថ្ងៃបក្ខ រមែងតាំងវត្តបដិបត្តិសម្រាប់មនុស្សដើរផ្លូវឆ្ងាយជាដើម រមែងសាងសាលាលើផ្លូវធំបែក ៤ រមែងនាំគ្នាជីកស្រះបោក្ខរណី រមែងដាំដើមផ្កាក្នុងសាលាជាដើម រមែងសាងស្ពានឆ្លងស្ទឹង និងផ្លូវលំបាកជាដើម រមែងធ្វើទីមិនស្មើឲ្យស្មើ វេទនាដែលជាកុសល រមែងកើតឡើងដល់បុគ្គលទាំងនោះ ដោយប្រការដូច្នេះ ។ ចំណែកបុគ្គលទាំងនោះ អាស្រ័យការឃើញខុស រមែងជេរ បរិភាស ពួកសម្មាទិដ្ឋិដោយខ្លួនឯង រមែងធ្វើកម្ម មានការសម្លាប់ និងការចាប់ចងជាដើម

សម្លាប់សត្វហើយនាំចូលទៅសែនព្រេនដល់ទេវតាទាំងឡាយ វេទនាដែលជាកុសល រមែងកើតឡើងដល់បុគ្គលទាំងនោះ ដោយប្រការដូច្នេះ ។ ចំណែកវេទនាដែលជាវិបាក រមែងមានដល់បុគ្គលនៅក្នុងវង់ភព ។

សូម្បីវេទនាសម្បយុត្តដោយសម្មាទិដ្ឋិ វេទនាដែលជាកុសល និងអកុសលខ្លះ វេទនាដែលជាវិបាកខ្លះ ដែលកើតឡើង ព្រោះធ្វើសម្មាទិដ្ឋិឲ្យជាឧបនិស្ស័យ រមែងគួរ សូម្បីក្នុងបទថា **សម្មាទិដ្ឋិប្បច្ចយា** នេះ ។ ក្នុងបទនោះ វេទនាដែលសម្បយុត្តដោយសម្មាទិដ្ឋិ រមែងជាកុសលតែម្យ៉ាង ។ ចំណែកបុគ្គលទាំងនោះ អាស្រ័យការឃើញត្រូវហើយ ទើបនាំគ្នាធ្វើបុណ្យទាំងឡាយជាដើម យ៉ាងនេះថា ការបូជាព្រះពុទ្ធជាម្ចាស់ (ដោយ) ប្រទីបផ្កាឈើ ការស្តាប់ធម៌ ការឲ្យប្រតិស្ឋានព្រះចេតិយ៍ក្នុងទិសាភាគ ដែលនៅមិនទាន់ប្រតិស្ឋាន ។ វេទនាដែលជាកុសល រមែងកើតឡើងដល់បុគ្គលទាំងនោះ ដោយប្រការដូច្នេះ ។ បុគ្គលទាំងនោះ អាស្រ័យការឃើញត្រូវទាំងនោះហើយ ទើបជេរបរិភាសពួកមិច្ឆាទិដ្ឋិ រមែងលើកខ្លួន គ្របសង្កត់បុគ្គលដទៃ វេទនាដែលជាអកុសល រមែងកើតឡើងដល់បុគ្គលទាំងនោះដោយប្រការដូច្នេះ ។ ចំណែកវេទនាដែលជាវិបាក រមែងមានដល់បុគ្គលទាំងឡាយដែលនៅក្នុងវង់ភពទាំងនោះ ។ សូម្បីក្នុងបទជាដើមថា ព្រោះ

**ការត្រិះរិះខុសជាបច្ច័យ (មិច្ឆាសង្កប្បបច្ចយា)** ក៏មានន័យនេះឯង ។ ចំណែក ក្នុងបទជាដើមថា **ព្រោះឆន្ទៈជាបច្ច័យ (ឆន្ទប្បច្ចយា)** គប្បីជ្រាប វេទនាដែលសម្បយុត្តដោយចិត្តប្រកបដោយលោភៈ ៨ ដួង ព្រោះមានឆន្ទៈជាបច្ច័យ ។ វេទនាក្នុងបឋមជ្ឈានរមែងមាន ព្រោះវិតក្កៈជាបច្ច័យ វេទនាក្នុងសញ្ញាសមាបត្តិ ៦ ដ៏សេស វៀរបឋមជ្ឈាន រមែងមាន ព្រោះសញ្ញាជាបច្ច័យ ។

ក្នុងបទជាដើមថា **ឆន្ទៈមិនស្ងប់ (ឆន្ទោ ច អវូបសន្តោ)** សេចក្តីថា វេទនាដែលសម្បយុត្តដោយចិត្តប្រកបដោយលោភៈ ៨ ដួង រមែងមានព្រោះការមិនស្ងប់នៃឆន្ទៈ វិតក្កៈ និងសញ្ញាទាំង ៣ តែពេលឆន្ទៈស្ងប់ វេទនាក្នុងបឋមជ្ឈានក៏រមែងមាន វេទនាមានទុតិយជ្ឈានជាដើម លោកសង្គ្រោះហើយព្រោះការស្ងប់ឆន្ទៈ និងវិតក្កៈ ។ វេទនា ក្នុងនេវសញ្ញានាសញ្ញាយតនៈរមែងមាន ព្រោះការស្ងប់ឆន្ទៈ វិតក្កៈ និងសញ្ញា ទាំង ៣ បាន ។ បទថា **ដើម្បីសម្រេចធម៌ដែលមិនទាន់បានសម្រេច (អប្បត្តស្ស បត្តិយា)** បានដល់ ដើម្បីសម្រេចអរហត្តផល ។ បទថា **មានសេចក្តីព្យាយាម (អត្ថិ វាយាមំ)** បានដល់ មានការព្យាយាម ។ បទថា **ដើម្បីដល់ឋានៈនោះហើយជាបច្ច័យខ្លះ (តស្មឹបិ ឋានេ អនុប្បត្តេ)** សេចក្តីថា កាលដល់ហេតុនៃព្រះអរហត្តផល

*ដោយអំណាចនៃការប្រារព្ធសេចក្តីព្យាយាមនោះ ៗ បទថា* ***ព្រោះឋានៈនោះជាបច្ច័យ (តប្បច្ចយាបិ វេទយិតំ)*** *សេចក្តីថា ការសោយអារម្មណ៍រមែងមាន ព្រោះឋានៈជាបច្ច័យនៃព្រះអរហត្ត វេទនាដែលជាលោកុត្តរៈកើតព្រមជាមួយមគ្គ ៤ លោកកាន់យកហើយដោយបទនោះឯង ៗ*

ចប់អដ្ឋកថា បឋមវិហារសូត្រទី ១

# អ ដ្ឋ ក ថា

## ទុតិយវិហារសូត្រទី ២

*គប្បីជ្រាបវិនិច្ឆ័យ ទុតិយវិហារសូត្រទី ២*

*ហេតុនៃការគេចចេញ គប្បីជ្រាបដោយន័យ ដែលលោកពោលហើយនោះឯង ។*

[៥០] *បទថា* ***ព្រោះការឃើញខុសស្ងប់ ជាបច្ច័យ (មិច្ឆាទិដ្ឋិវូបសមប្បច្ចយា)*** *បានដល់ ការឃើញត្រូវ ឈ្មោះថា ចូលទៅស្ងប់នូវការឃើញខុស ។ ព្រោះដូច្នោះ ការសោយអារម្មណ៍ណាលោកពោលហើយ ព្រោះការឃើញត្រូវជាបច្ច័យ ការសោយអារម្មណ៍នោះឯង អ្នកគប្បីជ្រាប ព្រោះស្ងប់ការឃើញខុសជាបច្ច័យ ។ ចំណែកក្នុងសូត្រនេះ លោកពោលថា បុគ្គលសម្គាល់វេទនាដែលជាវិបាក រមែងមិនកាន់យកក្នុងទីឆ្ងាយពេក ។ ក្នុងបទគ្រប់បទ គប្បីជ្រាបសេចក្តីដោយន័យនេះ ។ ក៏ការសោយអារម្មណ៍ លោកហៅថា ព្រោះចូលទៅស្ងប់ធម៌ណាៗ ជាបច្ច័យ ។ ការសោយអារម្មណ៍នោះៗ លោកបំណងយកហើយ ព្រោះជាធម៌ដែលផ្ទុយគ្នានឹងធម៌នោះៗ ជាប្បច្ច័យ ។ ចំណែកក្នុងបទជាដើមថា* ***ព្រោះឆន្ទៈស្ងប់ជាបច្ច័យ (ឆន្ទវូបសម-***

*ប្បច្ចយា) គប្បីជ្រាបវេទនាក្នុងបឋមជ្ឈានមុន ព្រោះឆន្ទៈស្ងប់ជាប្បច្ច័យ ។ វេទនាក្នុងទុតិយជ្ឈាន ព្រោះវិតក្កៈស្ងប់ជាបច្ច័យ វេទនាក្នុងសញ្ញាសមាបត្តិ ៦ ព្រោះសញ្ញាជាបច្ច័យ វេទនាក្នុងនេវសញ្ញានាសញ្ញាយតនៈ ព្រោះសញ្ញាស្ងប់ជាបច្ច័យ ។ បទជាដើមថា* ***ឆន្ទៈស្ងប់ (ឆន្ទោ ច វូបសន្តោ)*** *មានន័យដូចពោលហើយនោះឯង ។*

ចប់អដ្ឋកថា វិហារសូត្រទី ២

# អ ដ្ឋ ក ថា

## សេក្ខសូត្រទី ៣

*គប្បីជ្រាបវិនិច្ឆ័យក្នុង សេក្ខសូត្រទី ៣*

*[៥១] បទថា ព្រះសេក្ខ (សេក្ខោ) ប្រែថា អ្នកត្រូវសិក្សា ។*

*សួរថា រមែងសិក្សាអ្វី ?*

*ឆ្លើយថា រមែងសិក្សាសិក្ខា ៣ ។*

*បទថា របស់ព្រះសេក្ខ (សេក្ខាយ) សេចក្តីថា កើតឡើងហើយព្រមដោយផល ៣ និងមគ្គ ៤ ។ ឈ្មោះថា សេក្ខៈ ព្រោះអត្ថថា លោកត្រូវសិក្សាកិច្ចរបស់ខ្លួន ព្រោះមានកិច្ចមិនទាន់សម្រេច ដូច្នេះ ។*

ចប់អដ្ឋកថា សេក្ខសូត្រទី ៣

*អ ដ្ឋ ក ថា*

*សូត្រទី ៤-៥-៦-៧ មានអត្ថងាយទាំងនោះឯង ។*

# អ ដ្ឋ ក ថា

## បឋមកុក្កុដារាមទី ៤

*គប្បីជ្រាបវិនិច្ឆ័យក្នុង កុក្កុដារាមសូត្រទី ៨*

[៩៦] *បទថា **ការស្វែងរកប្រស្នា (ឧម្មង្គោ)** បានដល់ ពិចារណាបញ្ញាដោយបញ្ញា គឺ ស្វែងរកបញ្ញា ។ បទថា **ក៏លោកសួរយ៉ាងនេះ (ឯវំ ហិ ត្វំ អាវុសោ)** នេះ ព្រះអានន្ទពោលហើយ ដើម្បីត្រូវការឲ្យព្រះកន្ទះតាំងពាក្យសួរ ។*

ចប់អដ្ឋកថា កុក្កុដារាមសូត្រទី ៨

# អ ដ្ឋ ក ថា

## សូត្រទី ៩-១០

*មានអត្ថងាយទាំងអស់នោះឯង ។*

## ចប់វិហារវគ្គទី ២

## រួមអដ្ឋកថាក្នុងវគ្គនេះ គឺ

១ អដ្ឋកថា វិហារសូត្រ ២ អដ្ឋកថា ទុតិយវិហារសូត្រ
៣ អដ្ឋកថា សេក្ខសូត្រ ៤ អដ្ឋកថា កុក្កុដារាមសូត្រ

# មិច្ឆត្តវគ្គទី ៣

## អ ដ្ឋ ក ថា

## មិច្ឆត្តសូត្រជាដើម

*គប្បីជ្រាបវិនិច្ឆ័យក្នុង មិច្ឆត្តសូត្រជាដើម នៃ មិច្ឆត្តវគ្គទី ៣*

[៥៩] *បទថា **សេចក្តីខុស (មិច្ឆត្តំ)** បានដល់ មានសេចក្តីខុសជាសភាវៈ ។ បទថា **សេចក្តីត្រូវ (សម្មត្តំ)** បានដល់ មានសេចក្តីត្រូវជាសភាវៈ ។*

[៦៨] *បទថា **មិច្ឆាបដិបត្តាធិករណហេតុ** ប្រែថា ព្រោះហេតុនៃការបដិបត្តិខុស ។ អធិប្បាយថា ព្រោះហេតុធ្វើការបដិបត្តិខុស ។ បទថា **រមែងមិនញុំាងញេយ្យធម៌ដែលជាកុសលឲ្យសម្រេច (នារាធកោ)** បានដល់ មិនដល់ព្រម ។ បទថា **ញាយធម៌ (ញាយំ ធម្មំ)** បានដល់ អរិយមគ្គ ។*

[៧៥] *បទថា **ដឹងខុស (មិច្ឆាញាណី)** សេចក្តីថា ដឹងខុស គឺពិចារណាខុស ។ បទថា **រួចផុតខុស (មិច្ឆាវិមុត្តិ)** សេចក្តីថា មិនរួចផុតតាមសេចក្តីពិត គឺ មិនឲ្យរួចផុតចាកទុក្ខ ។ វដ្តៈ និងវិវដ្តៈ ក្នុងមគ្គ ៤ ព្រះ*

អង្គត្រាស់ហើយ ក្នុងព្រះសូត្រទី ៣ ជាដើមនេះ ។ ចំណែកបុគ្គលដែលទ្រង់សួរ និងធម៌ដែលទ្រង់ចែក មានហើយក្នុងព្រះសូត្រទាំង ២ ចុងក្រោយក្នុងទីនោះ ។ ទ្រង់សម្ដែងបុគ្គលដោយធម៌ យ៉ាងនេះ ។

[៧៨] បទថា *តែងបង្វិលទៅបានងាយ (សុប្បវត្តិយោ)* ប្រែថា ជាទីតាំងនៃការប្រព្រឹត្តទៅបានងាយ ។ អធិប្បាយថា បុគ្គលរមែងញ៉ាំងចិត្តឲ្យស្ទុះទៅកាន់ទិសដែលខ្លួនប្រាថ្នា និងត្រូវការបាន យ៉ាងណា បុគ្គលក៏រមែងអាចឲ្យផ្ទាំងវិលទៅបាន ដូច្នោះ ។

[៨១] បទថា *ព្រមទាំងហេតុ ព្រមទាំងគ្រឿងប្រកប (សឧបនិសំសបរិក្ខារំ)* បានដល់ ព្រមទាំងបច្ច័យ ព្រមទាំងបរិវារ ពាក្យដ៏សេសក្នុងបទទាំងពួង ងាយទាំងអស់នោះឯង ។

ចប់អដ្ឋកថា មិច្ឆត្តវគ្គទី ៣

## ចប់មិច្ឆត្តវគ្គទី ៣

# បដិបត្តិវគ្គទី ៤

## អ ដ្ឋ ក ថា

## បដិបត្តិសូត្រជាដើម

*គប្បីជ្រាបវិនិច្ឆ័យក្នុង បដិបត្តិសូត្រជាដើម នៃ បដិបត្តិវគ្គទី ៤ ។*

*[៨៩] បទថា **ការបដិបត្តិខុស (មិច្ឆាបដិបត្តិ)** គឺ នូវមិនបដិបត្តិតាមសេចក្តីពិត ។*

*[៩២] បទថា **អ្នកបដិបត្តិខុស (មិច្ឆាបដិបន្នំ)** គឺ អ្នកមិនបដិបត្តិតាមសេចក្តីពិត ។ សូត្រមួយត្រាស់ដោយអំណាចធម៌ សូត្រមួយត្រាស់ដោយអំណាចបុគ្គល ។*

*[៩៧-៩៨] បទថា **ដល់ត្រើយពីទីដែលមិនមែនត្រើយ (អបារា បារំ)** បានដល់ ដល់ព្រះនិព្វានចាកវដ្ដៈ ជនពួកណា ដល់នូវត្រើយហើយក្តី កំពុងដល់ក្តី នឹងដល់ក្តី ជនពួកនោះ គប្បីជ្រាបថា ជាអ្នកដល់ត្រើយ ក្នុងបទថា **បារគាមិនោ** ។*

*[៩៨] បទថា **សសៀរទៅតាមច្រាំង (តីរមេវានុធាវតិ)** សេចក្តីថា*

រមែងរត់ទៅកាន់វដ្តៈនោះឯង គឺ រមែងត្រាច់ទៅក្នុងវដ្តៈ ។ បទថា **ខ្មៅ** (កណ្ហំ) គឺ អកុសលធម៌ ។ បទថា **ចេញចាកអាល័យ អាស្រ័យធម៌មិនមានអាល័យ** (ឱកា អនោកំ) បានដល់ ចេញចាកវដ្តៈ អាស្រ័យនិព្វាន ។ បទថា **អាស្រ័យ** (អាគម្ម) បានដល់ ប្រារព្ធសំដៅដល់ អាស្រ័យ ។ បទថា **ឲ្យផូរផង់** (បរិយោទបេយ្យ) បានដល់ គប្បីធ្វើឲ្យបរិសុទ្ធ ។ បទថា **គ្រឿងសៅហ្មងនៃចិត្ត** (ចិត្តក្លេសេហិ) បានដល់ ដោយនិវរណៈដែលធ្វើចិត្តឲ្យសៅហ្មង ។ បទថា **ក្នុងអង្គជាហេតុឲ្យត្រាស់ដឹង** (សម្ពោធិយង្គេសុ) បានដល់ ក្នុងពោជ្ឈង្គៈ ៧ ។

[១០២] បទថា **ប្រយោជន៍នៃភាពជាសមណៈ** (សាមញ្ញត្ថំ) បានដល់ ព្រះនិព្វាន ។ ពិតណាស់ ព្រះនិព្វាននោះ លោកពោលថា ប្រយោជន៍នៃសមណៈ ព្រោះគួរចូលដល់ដោយភាពជាសមណៈ ។

[១០៥] បទថា **ភាពជាព្រហ្ម** (ព្រហ្មញ្ញំ) គឺ ភាពជាអ្នកដ៏ប្រសើរបំផុត ។

[១០៨] បទថា **ប្រយោជន៍នៃភាពជាព្រហ្ម** (ព្រហ្មញ្ញត្ថំ) បានដល់ ព្រះព្រះនិព្វាន ព្រោះគួរចូលដល់ដោយភាពជាអ្នកប្រសើរបំផុត ។ គេចិ-អាចារ្យពោលថា ព្រះនិព្វានដែលមកហើយថា ជាទីអស់ទៅនៃរាគៈ ក្នុង

*ខាងក្រោយ និងក្នុង ៣ សូត្រនេះ ក្នុងទីណាៗ សូម្បីព្រះអរហត្ត ក៏គួរក្នុងទីនោះៗ ដូចគ្នា ។*

ចប់អដ្ឋកថា បដិបត្តិសូត្រជាដើម

## ចប់បដិបត្តិវគ្គទី ៤

# អញ្ញតិត្ថិយវគ្គទី ៥

## អ ដ្ឋ ក ថា

## អញ្ញតិត្ថិយបេយ្យាល

[១១៧] គប្បីជ្រាបវិនិច្ឆ័យក្នុង *អញ្ញតិត្ថិយបេយ្យាល*

[១២២] បទថា *កំណត់ដឹងសង្សារវដ្តដ៏វែងឆ្ងាយ (អទ្ធានបរិញ្ញត្ថំ)* បានដល់ សម្រេចនិព្វាន ឈ្មោះថា កំណត់ដឹងសង្សារវដ្តដែលវែងឆ្ងាយ ព្រោះដូច្នោះ ព្រះនិព្វាន ទើបពោលថា កំណត់ដឹងសង្សារវដ្តដ៏វែងឆ្ងាយ ។ អធិប្បាយថា ដើម្បប្រយោជន៍ដល់ព្រះនិព្វាននោះ ។

[១២៦] បទថា *ដើម្បីអនុបាទាបរិនិព្វាន (អនុបាទាបរិនិព្វានត្ថំ)* បានដល់ ដើម្បីនិព្វានដែលមិនមានបច្ច័យ ។ ម្យ៉ាងទៀត ក្នុងបេយ្យាលនេះ ត្រាស់ដល់ព្រះអរហត្តដោយផល គឺ វិជ្ជាវិមុត្តិ ត្រាស់ដល់ការពិចារណាដោយញាណទស្សនៈ ត្រាស់ដល់ព្រះនិព្វាន ដោយបទដ៏សេស ដោយប្រការដូច្នេះ ។

**ចប់អដ្ឋកថាអញ្ញតិត្ថិយវគ្គទី ៥**

# សុរិយបេយ្យាលទី ៦

## អ ដ្ឋ ក ថា

### សុរិយបេយ្យាល

[១២៩] គប្បីជ្រាបវិនិច្ឆ័យក្នុង សុរិយបេយ្យាល ។

គប្បីជ្រាបខ្លឹមសារក្នុងទីទាំងពួង យ៉ាងនេះថា ការមានមិត្តល្អ ដូចការឡើងនៃអរុណ អរិយមគ្គព្រមដោយវិបស្សនាដែលតាំងនៅ ព្រោះភាពជាអ្នកមានមិត្តល្អធ្វើឲ្យកើតឡើង ដូចការប្រាកដនៃព្រះអាទិត្យ ។

[១៣១] បទថា ការដល់ព្រមដោយសីល (សីលសម្បទា) បានដល់ចតុបារិសុទ្ធសីល ។

[១៣២] បទថា ការដល់ព្រមដោយឆន្ទៈ (ឆន្ទសម្បទា) បានដល់កត្តុកាម្យតាឆន្ទៈ ដែលជាកុសល ។

[១៣៣] បទថា ការដល់ព្រមនៃខ្លួន (អត្តសម្បទា) គឺ ភាពជាអ្នកមានចិត្តបរិបូណ៌ហើយ ។

[១៣៤] បទថា ការដល់ព្រមដោយទិដ្ឋិ (ទិដ្ឋិសម្បទា) បានដល់ ការ

ដល់ព្រមនៃញាណ ។

[១៣៥] បទថា **ការដល់ព្រមដោយសេចក្ដីមិនប្រមាទ (អប្បមាទ-សម្បទា)** បានដល់ ការដល់ព្រមនៃការមិនប្រមាទដែលជាតួហេតុ ។

[១៣៦] បទថា **ការដល់ព្រមដោយការធ្វើទុកក្នុងចិត្តដោយប្រពៃ (យោនិសោមនសិការសម្បទា)** បានដល់ ការដល់ព្រមនៃការធ្វើទុកក្នុងចិត្តដោយឧបាយដ៏ប្រពៃ ។

[១៣៨] ទ្រង់ត្រាស់បទថា **កល្យាណមិត្តតា** ជាដើមទៀត ដើម្បីទ្រង់សម្ដែងការៈដោយអាការស្មើដទៃនៃសម្មាទិដ្ឋិជាដើម ។ ព្រះសូត្រទាំងអស់នេះ ទ្រង់ត្រាស់ដោយអំណាចនៃអជ្ឈាស្រ័យរបស់បុគ្គលដោយចំពោះ ។

ចប់អដ្ឋកថា សុរិយបេយ្យាលទី ៦

# អ ដ្ឋ ក ថា

## ឯកធម្មបេយ្យាលទី ៧ និងគង្គាបេយ្យាលទី ៩

[១៦៥-១៨៣] *ឯកធម្មបេយ្យាលក្តី គង្គាបេយ្យាលក្តី ក្នុងព្រះសូត្រដែលទ្រង់ត្រាស់ទុកនោះៗ ត្រាស់ទុកតាមអធ្យាស្រ័យរបស់បុគ្គល ដោយចំពោះ និងត្រាស់តាមអធ្យាស្រ័យរបស់បណ្ឌិតទាំងឡាយ ។*

# អប្បមាទវគ្គទី ១០

## អ ដ្ឋ ក ថា

## នៃអប្បមាទបេយ្យាល

គប្បីជ្រាបវិនិច្ឆ័យក្នុង អប្បមាទបេយ្យាល ។

[២៨៥] ក្នុងបទថា ដូច្នោះនោះឯង (ឯវមេវ ខោ) នេះ គប្បីឃើញថា ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ប្រសើរជាងសត្វទាំងពួង យ៉ាងណា ការមិនប្រមាទដែលជាតួហេតុ ជាធម៌ប្រសើរជាងកុសលធម៌ទាំងឡាយ ដូច្នោះ ។

សួរថា ក៏សេចក្ដីមិនប្រមាទនេះជាលោកិយៈមិនមែនឬ តែកុសលធម៌ជាលោកុត្តរៈក៏មាន ម្យ៉ាងទៀត សេចក្ដីមិនប្រមាទនេះជាកាមាវចរៈ តែកុសលធម៌ទាំងឡាយប្រព្រឹត្តទៅក្នុងភូមិ ៤ សេចក្ដីមិនប្រមាទនេះ នឹងជាធម៌ដ៏ប្រសើរជាងធម៌ទាំងនោះបានយ៉ាងណា? ។

ឆ្លើយថា ព្រោះអត្ថថា ជាហេតុនៃការបាន ។ ពិតណាស់ កុសលធម៌ទាំងនោះ ដែលបុគ្គលអ្នកបាន រមែងបានដោយការមិនប្រមាទ ព្រោះដូច្នោះ សេចក្ដីមិនប្រមាទនោះ ទើបជាធម៌ដ៏ប្រសើរជាងធម៌ទាំងនោះ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ទើបត្រាស់ថា ធម៌ទាំងអស់នោះ

មានសេចក្តីមិនប្រមាទជាមូល ដូច្នេះជាដើម ។

[២៥៣] បទថា **អ្នកសញ្ចរនៅលើផែនដី (ជង្គលានំ)** បានដល់សត្វអ្នកត្រាច់លើផែនដី ។ បទថា **សត្វទាំងឡាយ (បាណានំ)** បានដល់ពួកសត្វមានជើង ។ បទថា **ស្នាមជើងទាំងឡាយ (បទជាតានិ)** បានដល់ជើងទាំងឡាយ ។ បទថា **រមែងរួមចុះ (សមោធានំ គច្ឆន្តិ)** បានដល់ ដល់ការរួបរួម គឺ លើកឡើង ។ បទថា **បណ្ឌិត ពោលថាប្រសើរ (អគ្គមក្ខាយតិ)** បានដល់ រមែងពោលថា ប្រសើរជាទីបំផុត ។ បទថា **ព្រោះជាស្នាមជើងធំ (យទិទំ មហន្តត្តេន)** បានដល់ រមែងពោលថា ប្រសើរព្រោះជាស្នាមជើងធំក្រៃលែង ។ អធិប្បាយថា មិនមែនពោលថាប្រសើរ ដោយអំណាចនៃគុណ ។

[២៥៨] បទថា **វស្សិកំ** បានដល់ ផ្កាម្លិះលា ។

មានរឿងដំណាលថា **ព្រះភាតិយមហារាជ** ស្តាប់រឿងនេះហើយ ទ្រង់ត្រាស់បង្គាប់ឲ្យអប់ដោយក្លិនផ្កាឈើ ៤ ប្រភេទ ក្នុងបន្ទប់មួយ ដោយព្រះបំណងនិងសាកល្បង ឲ្យនាំផ្កាឈើមានក្លិនក្រអូប តាំងផ្កាម្លិះលាមួយក្តាប់ទុកកណ្តាលប្រអប់មួយ ចាត់ចែងផ្កាឈើដ៏សេស មួយក្តាប់ៗ តាំងទុកជុំវិញផ្កាម្លិះលានោះ ទ្រង់បិទទ្វារ ស្តេចចេញទៅខាងក្រៅ កាលព្រះអង្គ

វេនចាំពេលកន្លងទៅមួយស្របក់ ទើបបើកទ្វារស្តេចចូលទៅ ក្លិនផ្កាម្លិះលាប៉ះខ្ទប់ព្រះយានៈ មុនផ្កាឈើដទៃ ។ ព្រះអង្គស្តេចទ្រង់បែរព្រះភក្ត្រទៅកាន់មហាចេតិយ៍ ទ្រង់ក្រាបចុះនៅលើផែនដីនោះឯង ថ្វាយបង្គំព្រះចេតិយ៍ ទ្រង់ព្រះតម្រិះថា ព្រះសម្មាសម្ពុទ្ធជាម្ចាស់ត្រាស់ថា ផ្កាម្លិះជាផ្កាឈើដែលប្រសើរជាងផ្កាឈើទាំងឡាយ ព្រះអង្គត្រាស់ត្រឹមត្រូវហើយ ដូច្នេះ ។

[២៥៩] បទថា *ព្រះរាជាសាមន្ត* (*កុដ្ឋរាជានោ*) បានដល់ ព្រះរាជាតូច ។ បាលីថា *កុដរាជានោ* ដូច្នេះក៏មាន ។

[២៦២] បទថា *តន្តាវុតានំ* កាត់បទជា *តន្តេ អាវុតានំ* សេចក្តីថា លើកអំបោះឡើង គឺ ត្បាញ (សំពត់) ។ បទនេះជាឆដ្ឋីវិភត្តិចុះក្នុងអត្ថនៃបឋមាវិភត្តិ ។ ក៏ក្នុងបទនេះ មានខ្លឹមសារយ៉ាងនេះថា សំពត់ដែលត្បាញដោយអំបោះប្រភេទណាមួយ (*យានិ កានិចិ តន្តាវុតានិ វត្ថានិ*) ។ម្យ៉ាងទៀត គប្បីឃើញសេចក្តីក្នុងបទនេះ សូម្បីដោយន័យនៃបាឋៈដ៏សេសយ៉ាងនេះថា *តន្តាវុតានំ វត្ថានំ យានិ កានិចិ វត្ថានិ* ប្រែថា សំពត់ប្រភេទណាមួយ ក្នុងបណ្តាសំពត់ដែលត្បាញដោយអំបោះ ។ បទដ៏សេសក្នុងទីទាំងពួង ងាយទាំងអស់នោះឯង ។

**ចប់អប្បមាទវគ្គវណ្ណនាទី ១០**

# ពលករណីយវគ្គវណ្ណនាទី ១១

## អ ដ្ឋ ក ថា

## បឋមពលករណីយសុត្រទី ១

*គប្បីជ្រាបវិនិច្ឆ័យក្នុង ពលករណីយវគ្គ ។*

[២៦៤] *បទថា **ការងារដែលធ្វើដោយកម្លាំង** (ពលករណីយា) បានដល់ការងារមានការរត់ ការលោត ការឱន និងការសាបព្រោះជាដើម គប្បីធ្វើដោយកម្លាំងជើង និងកម្លាំងដៃ ។ បទថា **តាំងនៅក្នុងសីល** (សីលេ បតិដ្ឋាយ) បានដល់ តាំងនៅក្នុងចតុបារិសុទ្ធិសីល ។ បទថា **អរិយមគ្គដែលប្រកបដោយអង្គ ៨** (អដ្ឋង្គិកំ មគ្គំ) បានដល់ អរិយមគ្គជាមួយវិបស្សនា ។*

ចប់អដ្ឋកថា បឋមពលករណីយសុត្រទី ១

# អ ដ្ឋ ក ថា

## ពីជសូត្រទី ៥

[២៧២] ក្នុងបទថា *ពីជគាម និងភូតគាម (ពីជគាមភូតគាមា)* នេះ គប្បីជ្រាបថា ពូជ ៥ ប្រភេទ ឈ្មោះថា **ពីជគាម** ពូជនោះៗ ឯង សម្បូរណ៍ដោយស្លឹក ឈ្មោះថា **ភូតគាម** តាំងតែមានពណ៌ខៀវ ។

ចប់អដ្ឋកថា ពីជសូត្រទី ៥

# អ ដ្ឋ ក ថា

## នាគសូត្រទី ៦

[២៧៤] បទថា **មានកម្លាំង (ពលំ គាហេន្តិ)** បានដល់ ដល់ការចម្រើនលូតលាស់ គឺ មានរាងកាយរឹងមាំ ។ នេះជាកថាតាមលំដាប់ក្នុងបទថា **កុសុព្ភេ ឱតរន្តិ** ជាដើម ។

ពួកនាងនាគតាំងគភ៌ក្នុងឧតុសម័យ នាំគ្នាគិតថា ពួកយើងនឹងប្រសូតិក្នុងបឹងតូចនេះ ពួកកូនៗ របស់យើង មិនអាចទ្រាំនឹងកម្លាំងរបស់ក្រសែទឹករលក និងគ្រុឌដែលហោតលេងមកបាន ដូច្នេះ សូម្បីនាគទាំងនោះ ទើបនាំគ្នាជ្រមុជចុះក្នុងមហាសមុទ្រដល់ទ្វារផ្លូវរួមគ្នា នាំគ្នាចូលទៅទន្លេធំ ៥ ខ្សែ ហើយទៅកាន់ព្រៃហិមពាន្ត ។ នៅទីនោះ ពួកនាងនាគអាស្រ័យនៅត្រង់គុហាមាស គុហាប្រាក់ និងល្អាងកែវមណី ដែលពួកគ្រុឌចូលទៅមិនបាន ទើបប្រសូត ហើយបង្រៀនឲ្យកូននាគចុះកាន់ក្នុងទឹក ប្រមាណត្រឹម.កជើងជាដើម អាចឆ្លងទឹកទៅបាន ។ តអំពីនោះ កាលពួកនាគទាំងនោះ ឆ្លងកាត់ទន្លេគង្គាជាដើមបានដោយលំដាប់ អាចឆ្លងទៅមកបាន គឺ ឆ្លងពីត្រើយនេះទៅត្រើយឯណោះ ឆ្លងពីត្រើយឯណោះមកត្រើយនេះបាន កាលនោះ សូម្បី

នាគទាំងឡាយដឹងថា ឥឡូវនេះ កូនៗ របស់យើងអាចអត់ទ្រាំនឹងក្រសែទឹករលក និងកម្លាំងគ្រុឌបានហើយ ទើបឲ្យពពកធំតាំងឡើងដោយអានុភាពរបស់ខ្លួន ឲ្យភ្លៀងធ្លាក់ដូចធ្វើព្រៃហិមពាន្តទាំងអស់ ឲ្យមានទឹកជាក្រសែតែមួយ និម្មិតទូកសម្រេចដោយមាស និងប្រាក់ជាដើម លាតពិតានសំពត់មានកម្រងផ្កាឈើដែលមានក្លិនក្រអូប វិចិត្រដោយផ្កាយមាសអំពីខាងលើ កាន់យកសុភអាហារ និងផ្កាឈើមានក្លិនក្រអូបជាដើម ស្ទុះទៅកាន់មហានទីទាំង ៥ ដោយទូកទាំងនោះ ដល់មហាសមុទ្រដោយលំដាប់ ។ ក៏ពួកនាគអាស្រ័យនៅទីនោះ ធំធាត់ឡើងប្រមាណមួយរយព្យាម មួយពាន់ព្យាម មួយសែនព្យាម ឈ្មោះថា ដល់ភាពជាអ្នកចម្រើនធំធាត់បរិបូណ៌ ។

ក្នុងបទថា **ឯវមេវ ខោ** នេះ គប្បីឃើញថា ភ្នំហិមពាន្ត គឺ ចតុបារិសុទ្ធិសីល ។ ព្រះយោគាវចរដូចកូននាគ ។ អរិយមគ្គដូចបឹងជាដើម ។ ព្រះនិព្វានដូចមហាសមុទ្រ ។ កូននាគទាំងឡាយ ស្ថិតនៅក្នុងព្រៃហិមពាន្ត ដល់មហាសមុទ្រដោយបឹងជាដើម ដល់ភាពជាអ្នកមានរាងកាយធំធាត់ យ៉ាងណា ព្រះយោគីទាំងឡាយអាស្រ័យសីល តាំងនៅក្នុងសីល សម្រេចព្រះនិព្វានដោយអរិយមគ្គ ជាអ្នកមានសរីរៈ គឺ គុណធម៌ដ៏ធំក្នុងអភិញ្ញាធម៌ទាំងឡាយដែលមកដល់ហើយ ដោយអរហត្តមគ្គ ដូច្នោះឯង ។

ចប់អដ្ឋកថា នាគសូត្រទី ៦

# អ ដ្ឋ ក ថា

## កុម្ភសូត្រទី ៨

[២៧៨] *បទថា* ***កុម្ភោ*** *បានដល់ ក្អមទឹក ។ បទថា* ***មិនហូរត្រឡប់ (នោ បច្ចាវមតិ)*** *គឺ ទឹកមិនត្រឡប់ចូលទៅ ។ អធិប្បាយថា មិនហូរចូលខាងក្នុង ។*

ចប់អដ្ឋកថា កុម្ភសូត្រទី ៨

# អ ដ្ឋ ក ថា

## អាកាសសូត្រទី ១០

[២៨២] បទថា ទិសខាងកើត (បុរត្ថិមា) បានដល់ ខ្យល់មកពីទិសខាងកើត ។ សូម្បីក្នុងទិសខាងលិចជាដើម ក៏មានន័យនេះដូចគ្នា ។ បទថា សតិប្បដ្ឋាន ៤ (ចត្តារោបិ សតិប្បដ្ឋានា) សេចក្តីថា ការរួមប្រភេទរបស់ខ្យល់ មានខ្យល់ទិសខាងកើតជាដើមទាំងនោះ សម្រេចបានពីក្នុងអាកាសយ៉ាងណា ពោធិបក្ខិយធម៌ដែលត្រាស់ទុកដោយន័យមានជាដើមថា ចត្តារោ សតិប្បដ្ឋានា ដូច្នេះ សូម្បីក្នុងទីនេះក៏ដូច្នោះ រមែងសម្រេចបានដោយការចម្រើនអរិយមគ្គ ដែលជាមហាវិបស្សនា ។ ដោយហេតុនោះ ទើបត្រាស់ពាក្យនេះទុក ។

ចប់អដ្ឋកថា អាកាសសូត្រទី ១០

# អ ដ្ឋ ក ថា

## បឋមមេឃសូត្រទី ១១

[២៨៤] *បទថា* ***ខាងចុងខែនៃរដូវក្តៅ*** *(គិម្ហានំ បច្ឆិមេ មាសេ) បានដល់ ក្នុងខែ ៨ ។ បទថា* ***តាំងឡើងហើយ*** *(ឧហតំ) បានដល់ ផង់ធូលីត្រូវសត្វជើងពីរ ជើងបួនឈូសឆាយផែនដី បង្កើតជាផង់ធូលីហុយទៅក្នុងអាកាស ។ បទថា* ***រជោជល្លំ*** *បានដល់ ផង់ធូលី ។*

ចប់អដ្ឋកថា បឋមមេឃសូត្រទី ១១

# អ ដ្ឋ ក ថា

## នាវាសូត្រទី ១៣

[២៨៨] បទថា ទូកដើរសមុទ្ទ (សាមុទ្ទិកាយ នាវាយ) ជាដើម ពិស្តារហើយ ក្នុងវាណិជកោបមសូត្រជាដើម ។

ចប់អដ្ឋកថា នាវាសូត្រទី ១៣

# អ ដ្ឋ ក ថា

## អាគន្តុកាគារសូត្រទី ១៤

[២៨៤] បទថា ផ្ទះសម្រាប់ទទួលភ្ញៀវ (អាគន្តុកាគារំ) បានដល់ ផ្ទះទទួលភ្ញៀវ ដែលអ្នកត្រូវការបុណ្យសាងទុកកណ្តាលក្រុង សូម្បីព្រះរាជា និងមហាមាត្យរបស់ព្រះរា ក៏អាចចូលទៅស្នាក់អាស្រ័យបាន ។ បទថា គប្បីកំណត់ដឹងដោយបញ្ញាដ៏ក្រៃលែង (អភិញ្ញា បរិញ្ញេយ្យា) សេចក្តីថា

ដូចជា ការនៅរបស់ក្សត្រិយ៍ជាដើមដែលមកអំពីទិស មានទិសខាងកើតជាដើម រមែងសម្រេចបានក្នុងផ្ទះទទួលភ្ញៀវ យ៉ាងណា ភិក្ខុទាំងឡាយរមែងសម្រេចដោយការចម្រើនអរិយមគ្គ ដែលមានសមាធិ វិបស្សនា ក្នុងការកំណត់ដឹងដោយបញ្ញាដ៏ក្រៃលែងជាដើម នៃធម៌ទាំងឡាយ មានជាដើមថា **អភិញ្ញា បរិញ្ញេយ្យ** សូម្បីទាំងនេះក៏ដូច្នោះ ដោយហេតុនោះ ទើបទ្រង់ត្រាស់ពាក្យនេះទុក ។

ចប់អដ្ឋកថា អាគន្តុកាគារសូត្រទី ១៤

## ចប់ពលករណិយវគ្គទី ១១

## រួមក្នុងវគ្គនេះមាន ៨ អដ្ឋកថា


| | |
|---|---|
| ១ អដ្ឋកថា ពលករណីយសូត្រ | ២ អដ្ឋកថា ពីជសូត្រ |
| ៣ អដ្ឋកថា នាគសូត្រ | ៤ អដ្ឋកថា កុម្ភសូត្រ |
| ៥ អដ្ឋកថា អាកាសសូត្រ | ៦ អដ្ឋកថា បឋមមេឃសូត្រ |
| ៧ អដ្ឋកថា នាវាសូត្រ | ៨ អដ្ឋកថា អាគន្តុកាគារសូត្រ |

# ឯសនាវគ្គទី ១២

## អ ដ្ឋ ក ថា

## បឋមឯសនាសូត្រទី ១

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឯសនាវគ្គ (បឋមឯសនាសូត្រទី ១)*

*[២៩៨] បទថា **ការស្វែងរកកាម (កាមេសនា)** បានដល់ ការស្វែងរក ស្វែងរក ត្រាច់រក ប្រាថ្នាកាមទាំងឡាយ ។ បទថា **ការស្វែងរកភព (ភវេសនា)** បានដល់ ការស្វែងរកភពទាំងឡាយ ។ បទថា **ការស្វែងរកព្រហ្មចារ្យ (ព្រហ្មចរិយេសនា)** បានដល់ ការស្វែងរកព្រហ្មចារ្យ ពោលគឺ មិច្ឆាទិដ្ឋិ ។*

ចប់អដ្ឋកថា បឋមឯសនាសូត្រទី ១

# អ ដ្ឋ ក ថា

## វិធាសូត្រទី ៩

[៣១៣] បទថា *សេចក្តីប្រកាន់ (វិធា)* បានដល់ ចំណែកនៃមានះ ឬការតាំងទុកនូវមានះ ។ បទថា *សេចក្តីប្រកាន់ថា យើងប្រសើរជាងគេ (សេយ្យោហមស្មីតិ វិធា)* បានដល់ ចំណែកនៃមានះ ឬការតាំងទុកនូវមានះយ៉ាងនេះថា យើងជាអ្នកប្រសើរជាងគេ ។

ចប់អដ្ឋកថា វិធាសូត្រទី ៩

# អ ដ្ឋ ក ថា

## និយសុត្រទី ១៥

[៣២៥] *បទថា* ***នីយា*** *ប្រែថា ទុក្ខ ។ ក៏ក្នុងបទនេះ មានពាក្យអធិប្បាយថា ទុក្ខទាំងឡាយកើតដល់បុរសណា រមែងទម្លាយបុរសនោះ ព្រោះដូច្នោះ ទើបឈ្មោះថា* ***នីយា*** *។ សូត្រដ៏សេសក្នុងវគ្គនេះងាយទាំងអស់ ។*

ចប់អដ្ឋកថា និយសូត្រទី ១៥

## ចប់ឯសនាវគ្គទី ១២

## រួមក្នុងវគ្គនេះមាន ៣ អដ្ឋកថា

១ អដ្ឋកថា បឋមឯសនាសូត្រ ២ អដ្ឋកថា វិធាសូត្រ

៣ អដ្ឋកថា និយសូត្រ

# ឱឃវគ្គទី ១៣

## អដ្ឋកថាវគ្គនេះងាយក្រែមគ្គា

*គប្បីជ្រាបវិនិច្ឆ័យក្នុង **ឱឃវគ្គ** ។*

*[៣៣៣] បទថា **ឱឃៈគឺកាម** (កាមោឃោ) បានដល់ សេចក្តីប្រាថ្នាដោយសេចក្តីពេញចិត្តក្នុងកាមគុណ ៥ ។*

*បទថា **ឱឃៈគឺភព** (ភវោឃោ) បានដល់ សេចក្តីប្រាថ្នាដោយសេចក្តីពេញចិត្ត ក្នុងរូបភព និងអរូបភព ។*

*បទថា **ឱឃៈគឺទិដ្ឋិ** (ទិដ្ឋោឃោ) បានដល់ ទិដ្ឋិ ៦២ ។*

*បទថា **ឱឃៈគឺអវិជ្ជា** (អវិជ្ជោឃោ) បានដល់ សេចក្តីមិនដឹងក្នុងអរិយសច្ចៈ ៤ ។ សូម្បីក្នុងកាមយោគៈជាដើម ក៏មានន័យនេះឯង ។*

*[៣៣៧] បទថា **កាមុបាទានំ** បានដល់ ការប្រកាន់ គឺ កាម ។ សូម្បីក្នុងបទមានជាដើមថា **ទិដ្ឋុបាទាន** ក៏មានន័យនេះឯង ។*

*[៣៣៩] បទថា **គន្ថា** បានដល់ គ្រឿងរួបរឹត គឺ ជាប់ណែន ។ បទថា **កាយគន្ថោ** បានដល់ គ្រឿងរួបរឹតនៃនាមកាយ គឺ កិលេសជាគ្រឿង*

រួបរឹតជាប់ណែន ។

បទថា *ឥទំសច្ចាភិនិវេសោ* បានដល់ ការប្រកាន់មាំ យ៉ាងនេះថា នេះឯងពិត កើតឡើងដោយអំណាចអន្តគ្គាហិកទិដ្ឋិ ។

[៣៨១] បទថា *អនុស័យគឺកាមរាគៈ (កាមរាគានុសយោ)* សេចក្ដីថា ឈ្មោះថា កាមរាគានុស័យ ព្រោះអត្ថថា ទៅដោយកម្លាំង សូម្បីក្នុងសូត្រដ៏សេស ក៏មានន័យនេះឯង ។

[៣៨៩] បទថា *ជាចំណែកខាងក្រោម (ឱរម្ភាគិយានិ)* គឺ សំយោជនៈដែលជាចំណែកខាងក្រោម ។ បទថា *សញ្ញោជនានិ* បានដល់ គ្រឿងចង ។ បទថា *ជាចំណែកខាងលើ (ឧទ្ធម្ភាគិយានិ)* បានដល់ សំយោជនៈដែលជាចំណែកខាងលើ ។ សូត្រដ៏សេសក្នុងទីទាំងពួង មានសេចក្ដីងាយទាំងអស់ ដោយប្រការដូច្នេះ ។

**ចប់ឱឃវគ្គទី ១៣**

## ចប់អដ្ឋកថាមគ្គសំយុត្ត

### រួមក្នុងវគ្គនេះមាន ១ អដ្ឋកថា

ព្រះអដ្ឋកថា កែសេចក្ដីរួមគ្នាទាំងអស់

# ពោជ្ឈង្គសំយុត្ត

## បព្វតវគ្គវណ្ណនាទី ១

## អ ដ្ឋ ក ថា

### ហិមវន្តសូត្រទី ១

*គប្បីជ្រាបវិនិច្ឆ័យក្នុង ហិមវន្តសូត្រទី ១ នៃ ពោជ្ឈង្គសំយុត្ត ។*

[៣៥៥] *បទថា នាគ (នាគា) សេចក្តីថា នាគសូម្បីទាំងនេះ នៅរវាងលើទឹករលកនៃមហាសមុទ្រ មិននៅក្នុងវិមានទេ ។ នាគទាំងនោះមានកាយធំធាត់ជាដើម ព្រោះអាស្រ័យភ្នំហិមវន្ត ទាំងអស់គប្បីជ្រាបដោយន័យដែលពោលហើយក្នុងខាងក្រោយ ។ ក្នុងបទថា* ***ពោជ្ឈង្គ*** *នេះ ឈ្មោះថាពោជ្ឈង្គៈ ព្រោះជាអង្គនៃការត្រាស់ដឹង ឬអង្គរបស់អ្នកត្រាស់ដឹង ។ មានពាក្យដែលលោកអធិប្បាយទុកយ៉ាងណា? ធម្មសាមគ្គីនេះ លោកហៅថា* ***ពោធិ*** *ព្រោះអធិប្បាយទុកថា កាលធម្មសាមគ្គីកើតឡើងហើយ ក្នុងខណៈនៃមគ្គដែលជាលោកិយៈ និងលោកុត្តរៈ ព្រះអរិយសាវករមែងត្រាស់ដឹង*

ដោយធម្មសាមគ្គី ពោលគឺ សតិ ធម្មវិចយៈ វីរិយៈ បីតិ បស្សទ្ធិ សមាធិ ឧបេក្ខា ដែលជាបដិបក្ខដល់ឧបទ្វវៈច្រើនយ៉ាង មាន **លីនៈ** (ការស្ដុតចិត្ត) **ឧទ្ធច្ចៈ** (ការរាមាយ) **បតិដ្ឋានៈ** (ការតាំងនៅ) **អាយូហនៈ** (ការរួបរួម) **កាមសុខល្លិកានុយោគ** (ធ្វើការព្យាយាមក្នុងកាមសុខ) **អត្តកិលមថានុ-យោគ** (ការព្យាយាមក្នុងការធ្វើខ្លួនឲ្យលំបាក) **ឧច្ឆេទទិដ្ឋិ** (ការឃើញថាដាច់សូន្យ) **សស្សតទិដ្ឋិ** (ការឃើញថាទៀង) និង **អភិនិវេសៈ** (ការប្រកាន់មាំជាដើម) ដូច្នេះ ។

បទថា **ត្រាស់ដឹង (ពុជ្ឈតិ)** មានអធិប្បាយថា ព្រះអរិយសាវក រមែងក្រោកឡើងអំពីការដេក គឺ កិលេសសន្តាន គឺ ត្រាស់ដឹងអរិយសច្ចៈ ៤ ឬរមែងធ្វើព្រះនិព្វានឲ្យជាក់ច្បាស់ ។ សមដូចដែលលោកពោលថា ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ចម្រើនពោជ្ឈង្គៈ ៧ ត្រាស់ដឹងហើយនូវអនុ-ត្តរសម្មាសម្ពោធិញ្ញាណ ។ ឈ្មោះថា ពោជ្ឈង្គៈ ព្រោះជាអង្គនៃការត្រាស់ដឹង ពោលគឺ ធម្មសាមគ្គីនោះ ដូចអង្គនៃឈាន និងអង្គនៃមគ្គជាដើម ។ ចំណែកព្រះអរិយសាវក ហៅថា **ពោធិ** ព្រោះអធិប្បាយថា រមែងត្រាស់ដឹងដោយធម្មសាមគ្គីនេះ មានប្រការតាមដែលពោលហើយ ដោយប្រការដូច្នេះ ។ ឈ្មោះថា **ពោជ្ឈង្គ** ព្រោះជាអង្គរបស់អ្នកត្រាស់ដឹងនោះខ្លះ ដូច

អង្គនៃសេនា និងអង្គនៃរថជាដើម ។ ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោលថា ម្យ៉ាងទៀត ឈ្មោះថា **ពោជ្ឈង្គ** ព្រោះជាអង្គរបស់បុគ្គលអ្នកត្រាស់ដឹង ។

សួរថា ឈ្មោះថា **ពោជ្ឈង្គ** ព្រោះអត្ថដូចម្តេច?

ឆ្លើយថា ឈ្មោះថា **ពោជ្ឈង្គ** ព្រោះអត្ថថា រមែងប្រព្រឹត្តដើម្បីការត្រាស់ដឹង ព្រោះអត្ថថា **ត្រាស់ដឹង** ព្រោះអត្ថថា **ត្រាស់ដឹងតាម** ព្រោះអត្ថថា **ត្រាស់ដឹងចំពោះ** ព្រោះអត្ថថា **ត្រាស់ដឹងដោយល្អ** ។ គប្បីជ្រាបអត្ថនៃពោជ្ឈង្គៈ សូម្បីដោយន័យនៃបដិសម្ភិទាជាដើម ដោយប្រការដូច្នេះឯង ។

[៣៥៦] ចំណែកក្នុងបទជាដើមថា **សតិសម្ពោជ្ឈង្គៈ (សតិសម្ពោជ្ឈង្គំ)** គប្បី ជ្រាបអត្ថក្នុងបទទាំងពួងយ៉ាងនេះថា ឈ្មោះថា សម្ពោជ្ឈង្គៈ ព្រោះជាអង្គ នៃការត្រាស់ដឹងដ៏ប្រសើរ និងល្អ ។ សម្ពោជ្ឈង្គៈ គឺ សតិ ឈ្មោះថា សតិសម្ពោជ្ឈង្គៈ ដែលជាសតិសម្ពោជ្ឈង្គនោះ ។

បទថា **ភាវេតិ** គឺ ឲ្យចម្រើន អធិប្បាយថា រមែងឲ្យកើត គឺ រមែងឲ្យកើតរឿយៗ ក្នុងចិត្តសន្តានរបស់ខ្លួន ។ បទទាំងឡាយមានដើមថា **ដែលអាស្រ័យវិវេក (វិវេកនិស្សិតំ)** គប្បីជ្រាបដោយន័យដែលពោលហើយក្នុង

បទនេះថា ភិក្ខុរមែងចម្រើនសម្មាទិដ្ឋិអាស្រ័យវិវេក ដូច្នេះ ក្នុងកោសលសំយុត្ត ។

ចំណែកការផ្សេងគ្នាដូច្នេះ ក្នុងកោសលសំយុត្តនោះ លោកពោលវិវេកទុក ៣ យ៉ាង គឺ អាស្រ័យតទង្គវិវេក សមុច្ឆេទវិវេក និស្សរណវិវេក ។ ចំណែកអាចារ្យពួកខ្លះ ពោលដល់អ្នកចម្រើនពោជ្ឈង្គៈអាស្រ័យវិវេក ៥ យ៉ាង ក៏មាន ។ ក៏អាចារ្យទាំងនោះ រមែងលើកយកពោជ្ឈង្គៈឡើងសម្តែងយ៉ាងនេះ ក្នុងខណៈនៃពលវវិបស្សនា មគ្គ និងផលតែម្យ៉ាងក៏ទេដែរ រមែងលើកឡើងសម្តែងសូម្បីក្នុងកសិណឈាន អានាបានស្សតិ អសុភកម្មដ្ឋាន និងព្រហ្មវិហារឈាន ដែលជាបាទរបស់វិបស្សនា ។ អាចារ្យពួកខ្លះទាំងនោះ ទើបមិនសម្រេចតាមព្រះអដ្ឋកថាចារ្យ ព្រោះដូច្នោះ តាមមតិរបស់លោកទាំងនោះ ក្នុងខណៈការប្រព្រឹត្តទៅនៃឈានទាំងនោះ ពោលដោយកិច្ច ឈានក៏ត្រូវអាស្រ័យវិក្ខម្ភនវិវេក ។ ក្នុងខណៈនៃវិបស្សនា លោកពោលថា ដោយអជ្ឈាស្រ័យ ភិក្ខុរមែងចម្រើនវិបស្សនា អាស្រ័យនិស្សរណវិវេក យ៉ាងណា ។ ក៏គួរនឹងពោលថា ភិក្ខុរមែងចម្រើនពោជ្ឈង្គៈអាស្រ័យបដិបស្សទ្ធិវិវេក ដូច្នោះ ។ ពាក្យដ៏សេសក្នុងសូត្រនេះ មានន័យតាមដែលពោលហើយក្នុងខាងក្រោយ ។

ចប់អដ្ឋកថា ហិមវន្តសូត្រទី ១

# អ ដ្ឋ ក ថា

## កាយសូត្រទី ២

គប្បីជ្រាបវិនិច្ឆ័យក្នុង កាយសូត្រទី ២ ។

[៣៥៧] បទថា **មានអាហារជាទីតាំង (អាហារដ្ឋិតិកោ)** គឺ កាយនេះតាំងនៅបានព្រោះបច្ច័យ ។ បទថា **អាស្រ័យអាហារ (អាហារំ បដិច្ច)** បានដល់ អាស្រ័យបច្ច័យ ។

[៣៥៨] បទថា **សុភនិមិត្ត (សុភនិមិត្តំ)** បានដល់ សូម្បីវត្ថុដែលស្អាត ក៏ជាសុភនិមិត្ត សូម្បីអារម្មណ៍របស់វត្ថុដែលស្អាត ក៏ជាសុភនិមិត្ត ។ បទថា **អយោនិសោមនសិការ (អយោនិសោមនសិការោ)** បានដល់ មិនធ្វើទុកក្នុងចិត្តដោយឧបាយ គឺ ធ្វើទុកក្នុងចិត្តខាងក្រៅផ្លូវ បានដល់ ធ្វើទុកក្នុងចិត្តក្នុងសេចក្តីមិនទៀង ថាទៀង ឬក្នុងសេចក្តីទុក្ខ ថាសុខ ក្នុងវត្ថុដែលមិនមែនខ្លួន ថាខ្លួន ឬក្នុងវត្ថុដែលមិនស្អាត ថាស្អាត កាមច្ឆន្ទៈរមែងកើតឡើងដល់អ្នកញ៉ាំងមនសិការនោះ ឲ្យប្រព្រឹត្តនៅក្នុងសុភារម្មណ៍នោះ ដោយច្រើន ។ ព្រោះហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ ទើបត្រាស់ពាក្យថា **ម្នាលភិក្ខុទាំងឡាយ សុភនិមិត្តមានហើយ (អត្ថិ ភិក្ខវេ សុភនិមិត្តំ)** ដូច្នេះជាដើម ។

គប្បីជ្រាបវាចាប្រកបក្នុងនិវរណៈក្នុងទីទាំងពួង ដោយប្រការដូច្នេះ ។

[៣៥៩] ចំណែកក្នុងបទថា **បដិឃនិមិត្ត** ((**បដិឃនិមិត្តំ**) ជាដើម បដិឃៈក្តី អារម្មណ៍របស់បដិឃៈក្តី ចាត់ជាបដិឃនិមិត្ត ។

[៣៦០] បទថា **ការមិនត្រេកអរ (អរតិ)** ប្រែថា ការធុញទ្រាន់ ។ ដូចព្រះអង្គទ្រង់ព្រះបំណងត្រាស់ទុកថា "ក្នុងបទទាំងនោះ **ការធុញទ្រាន់ ដូចម្តេច** គឺ ការមិនត្រេកអរ ការមិនត្រេកអរខ្លាំង ការមិនអភិរម្យ ការមិនសប្បាយ ការភ័យខ្លាចក្នុងសេនាសនៈទាំងឡាយដែលស្ងាត់ ឬក្នុងធម៌ទាំងឡាយដែលជាអធិកុសលយ៉ាងណាមួយ នេះហៅថា **ការធុញទ្រាន់**" ។

បទថា **សេចក្តីខ្ជិលច្រអូស (តន្ទិ)** បានដល់ ការច្រអូសកាយដែលត្រាច់ចរមក កើតឡើង ព្រោះមានភាពរងាររពេកជាដើមជាបច្ច័យ ពេលវាកើតឡើង គេនឹងពោលថា រងារណាស់ ក្តៅណាស់ យើងស្រេកណាស់ ឃ្លានណាស់ យើងដើរផ្លូវឆ្ងាយណាស់ ។ ដូចព្រះអង្គទ្រង់ព្រះបំណងត្រាស់ទុកថា "ក្នុងបទទាំងនោះ **ការខ្ជិលច្រអូសដូចម្តេច** គឺ កិរិយាដែលខ្ជិលច្រអូស ការមានចិត្តខ្ជិលច្រអូស សេចក្តីខ្ជិល កិរិយាដែលខ្ជិល ភាពជាអ្នកមានសេចក្តីខ្ជិលច្រអូសឯណា នេះហៅថា **សេចក្តីខ្ជិលច្រអូស**" ។

បទថា **ការមិតពត់កាយ (វិជម្ភិតា)** បានដល់ ការមិតពត់កាយដោយ

អំណាចកិលេស ។ ដូចព្រះអង្គទ្រង់ព្រះបំណាន់ត្រាស់ទុកថា “ក្នុងបទទាំងនោះ **ការមិតពត់កាយ ដូចម្តេច** គឺ ការមិតពត់កាយ ការពត់ ការផ្អៀងមក ការផ្អៀងទៅ ការឱនចុះ ការងងុយងោកងក់ ការគ្រុនក្តៅមិនស្រួលខ្លួនរបស់កាយឯណា នេះហៅថា **ការមិតពត់កាយ**” ។

បទថា **ពុលបាយ (ភត្តសម្មទោ)** បានដល់ ការហល់ក្នុងអាហារ ។ ដូចព្រះអង្គទ្រង់បំណាន់ត្រាស់ទុកថា “ក្នុងបទទាំងនោះ **ការពុលបាយ ដូចម្តេច** ការទន់ទៅក្នុងអាហារ លំបាកក្នុងអាហារ ការហល់ក្នុងអាហារ ការធំធាត់នៃកាយរបស់អ្នកបរិភោគណា ទាំងនេះហៅថា **ការពុលបាយ** ។

បទថា **ការរួញរានៃចិត្ត (ចេតសោ លីនត្តំ)** បានដល់ អាការរួញរារបស់ចិត្ត ។ ដូចព្រះអង្គទ្រង់ព្រះបំណាន់ត្រាស់ទុកថា “ក្នុងបទទាំងនោះ **ការរួញរានៃចិត្តដូចម្តេច** គឺ ភាពមិនស្អាត ភាពមិនគួរដល់ការងារ ភាពរួញរានៃចិត្ត កិរិយារួញរា ការរួញរារបស់ចិត្ត ភាពអស់សង្ឃឹម កិរិយាអស់សង្ឃឹម ភាពអស់សង្ឃឹមរបស់ចិត្តណា នេះហៅថា **ការរួញរានៃចិត្ត**” ។

[៣៦១] បទថា **ការមិនស្ងប់ចិត្ត (ចេតសោ អវូបសមោ)** សេចក្តីថា អាការមិនស្ងប់របស់ចិត្ត ដូចបុគ្គលអង្គុយបង្កាត់ភ្លើង មានតែច្បងប្រាសចាកអណ្តាតភ្លើង និងដូចបុគ្គលអង្គុយមិនបង្កាត់ភ្លើងក្នុងទីជុតបាត្រ ដូច្នោះ

តែដោយសេចក្តីប្រការនោះ ជាសេចក្តីរំខានដោយពិត ។

[៣៦២] បទថា **ធម៌ទាំងឡាយដែលជាទីតាំងនៃវិចិកិច្ឆា (វិចិកិច្ឆាឋានិយា ធម្មា)** បានដល់ ធម៌ជាអារម្មណ៍របស់វិចិកិច្ឆា ។ អយោនិសោមនសិការ មានន័យដូចបានពោលទុកក្នុងបទទាំងពួងនោះឯង ។ ក្នុងប្រការនេះ ធម៌ ២ យ៉ាងនេះ គឺ កាមឆន្ទៈ វិចិកិច្ឆា លោកពោលទុកយ៉ាងនេះដោយអារម្មណ៍ ។ ព្យាបាទ ពោលទុកដោយអារម្មណ៍ និងឧបនិស្សយប្បច្ច័យ ធម៌ដ៏សេស ពោលទុកដោយសហជាតប្បច្ច័យ និងឧបនិស្សយប្បច្ច័យដោយប្រការដូច្នេះ ។

[៣៦៥] បទថា **ធម៌ទាំងឡាយជាទីតាំងនៃសតិសម្ពោជ្ឈង្គៈ (សតិសម្ពោជ្ឈង្គដ្ឋានិយា)** បានដល់ ធម៌ជាអារម្មណ៍របស់សតិ គឺ ពោធិបក្ខិយធម៌ ៣៧ និងលោកុត្តរធម៌ ៩ ។ បទថា **ការធ្វើឲ្យច្រើននូវយោនិសោមនសិការ (តត្ថ យោនិសោមនសិការពហុលីការោ)** បានដល់ ការធ្វើរឿយៗនូវមនសិការដោយឧបាយក្នុងធម៌នោះ ។

[៣៦៦] បទថា **ធម៌ជាកុសល (កុសលា)** ក្នុងបទជាដើមថា **កុសលាកុសលា ធម្មា** បានដល់ ធម៌កើតពីសេចក្តីឆ្លាត មិនមានទោស មានផលជាសុខ ។ បទថា **អកុសលា** បានដល់ ធម៌ដែលកើតពីសេចក្តីមិនឆ្លាត

មានទោស មានផលជាទុក្ខ ។ បទថា **មានទោស (សាវជ្ជា)** បានដល់ ធម៌ជាអកុសល ។ បទថា **មិនមានទោស (អនវជ្ជា)** បានដល់ ធម៌ជាកុសល ។ សូម្បីក្នុងធម៌លាមក ប្រណីត ខ្មៅ និងស ក៏មានន័យនេះដូចគ្នា ។ បទថា **ចំណែកប្រៀប (សប្បដិភាគា)** បានដល់ កណ្ហធម៌ និងសុក្កធម៌ប៉ុណ្ណោះ ព្រោះថា កណ្ហធម៌ ឈ្មោះថា មានចំណែកប្រៀប ព្រោះឲ្យផលខ្មៅ និងសុក្កធម៌ ឈ្មោះថា មានចំណែកប្រៀប ព្រោះឲ្យផលស អធិប្បាយថា មានចំណែកនៃវិបាកដូចគ្នា ។ ម្យ៉ាងទៀត ឈ្មោះថា មានចំណែកប្រៀប ព្រោះមានចំណែកផ្ទុយគ្នា ។ គឺមានចំណែកប្រៀបដូច្នេះថា ចំណែកសុក្កធម៌ ផ្ទុយគ្នាជាមួយកណ្ហធម៌ និងកណ្ហធម៌ផ្ទុយគ្នាជាមួយសុក្កធម៌ ។ ម្យ៉ាងទៀត ឈ្មោះថា មានចំណែកប្រៀប ព្រោះអត្ថថា នឹងនាំមកជំនួសគ្នាមិនបាន ។ គឺ កណ្ហធម៌ និងសុក្កធម៌ មានចំណែកប្រៀបគ្នាបានយ៉ាងនេះថា ចំណែកអកុសលហាមកុសលហើយ ទើបឲ្យវិបាករបស់ខ្លួន , ចំណែកកុសលហាមអកុសលហើយ ទើបឲ្យវិបាករបស់ខ្លួន ដូច្នេះ ។

[៣៦៧] បទថា **ការផ្ដួចផ្ដើម (អារព្ភធាតុ)** បានដល់ ការព្យាយាមគ្រាដំបូង ។ បទថា **សេចក្ដីព្យាយាម (និក្កមធាតុ)** បានដល់ ការព្យាយាមមានកម្លាំងជាងនោះ ព្រោះចេញចាកការខ្ជិលច្រអូស ។ បទថា **សេចក្ដីប្រឹង**

ប្រែថា (បរក្កមធាតុ) បានដល់ ការព្យាយាមមានកម្លាំងជាងនោះ ព្រោះជាហេតុឈានទៅកាន់ឋានៈខាងមុខៗ ព្រោះដូច្នោះ សេចក្ដីព្យាយាម លោកទើបពោលដោយបទទាំង ៣ ។

[៣៦៨] បទថា **ជាទីតាំងនៃបីតិសម្ពោជ្ឈង្គៈ (បីតិសម្ពោជ្ឈង្គដ្ឋានិយា)** បានដល់ ធម៌ជាអារម្មណ៍របស់បីតិ ។

[៣៦៩] បទថា **សេចក្ដីស្ងប់កាយ (កាយបស្សទ្ធិ)** បានដល់ ការស្ងប់នៃខន្ធ ៣[១] ។ បទថា **ចិត្តបស្សទ្ធិ** បានដល់ ការស្ងប់នៃវិញ្ញាណក្ខន្ធ ។

[៣៧០] បទថា **សមាធិនិមិត្ត (សមាធិនិមិត្តំ)** បានដល់ សមថៈខ្លះ អារម្មណ៍របស់សមថៈខ្លះ ។ បទថា **អព្យគ្គនិមិត្ត (អព្យគ្គនិមិត្តំ)** ជាវេចនៈរបស់បទថា **សមាធិនិមិត្តំ** នោះ ។

[៣៧១] បទថា **ជាទីតាំងនៃឧបេក្ខាសម្ពោជ្ឈង្គៈ (ឧបេក្ខាសម្ពោជ្ឈង្គដ្ឋានិយា)** បានដល់ ធម៌ជាអារម្មណ៍របស់ឧបេក្ខា ។ តែដោយសេចក្ដីគប្បីជ្រាបអាការដែលជាកណ្ដាលថា ធម៌ទាំងឡាយជាទីតាំងនៃឧបេក្ខា ក្នុងសេចក្ដីនេះ សតិ ធម្មវិចយៈ និងឧបេក្ខាសម្ពោជ្ឈង្គៈ លោកពោលទុកដោយភាពជាអារម្មណ៍យ៉ាងនេះ ។ ធម៌ទាំងឡាយដ៏សេស លោកពោលទុកដោយភាពជាអារម្មណ៍ខ្លះ ដោយភាពជាឧបនិស្ស័យខ្លះ ។

ចប់អដ្ឋកថា កាយសូត្រទី ២

---

១ គឺ វេទនាខន្ធ សញ្ញាក្ខន្ធ និងសង្ខារក្ខន្ធ ។

# អ ដ្ឋ ក ថា

## សីលសូត្រទី ៣

*គប្បីជ្រាបវិនិច្ឆ័យក្នុង សីលសូត្រទី ៣ ។*

*[៣៧៣] ក្នុងបទថា ដល់ព្រមដោយសីល (សីលសម្បន្នា) លោកកាន់យកលោកិយសីល និងលោកុត្តរសីលរបស់ភិក្ខុអ្នកមានអាសវៈអស់ហើយ ។ អធិប្បាយថា ពួកភិក្ខុជាអ្នកដល់ព្រមដោយសីលនោះ ។ សូម្បីក្នុងសមាធិ និងបញ្ញា ក៏មានន័យនេះដូចគ្នា ។ ចំណែកការរួចផុត ជាផលវិមុត្តិនោះឯង ។ វិមុត្តិញាណទស្សនៈ ជាបច្ចវេក្ខណញាណ ។ ក្នុងប្រការនេះ ធម៌ មានសីលជាដើម មានទាំងលោកិយៈ និងលោកុត្តរៈ , វិមុត្តិជាលោកុត្តរៈ , វិមុត្តិញាណទស្សនៈ ជាលោកិយៈ ។*

*បទថា **ទស្សនម្បហំ** កាត់បទជា **ទស្សនំបិ អហំ** ក៏ការបានឃើញនោះមាន ២ យ៉ាង គឺ ការឃើញដោយចក្ខុ ១ ឃើញដោយញាណ ១ ។ ក្នុងការបានឃើញ ២ យ៉ាងនោះ ការបានឃើញ គឺ ការបានឃើញព្រះអរិយៈទាំងឡាយដោយចក្ខុ ហើយជ្រះថ្លា ឈ្មោះថា **ការបានឃើញដោយចក្ខុ** ។ ចំណែកការបានឃើញលក្ខណៈ ដែលព្រះអរិយៈឃើញហើយ និងការចាក់*

ផ្ទុះដល់លក្ខណៈ ដែលព្រះអរិយៈចាក់ផ្ទុះហើយ ដោយឈាន ដោយវិបស្សនា ឬដោយមគ្គ និងផល ឈ្មោះថា **ការបានឃើញដោយញាណ** ។ តែក្នុងការបានឃើញ ២ យ៉ាងនេះ ការបានឃើញដោយចក្ខុ បំណងយកក្នុងទីនេះ ។ ព្រោះថា សូម្បីការបានឃើញព្រះអរិយៈដោយចក្ខុហើយជ្រះថ្លា មានឧបការៈច្រើនយ៉ាង ។ បទថា **ការស្តាប់ (សវនំ)** បានដល់ ការបានស្តាប់ដោយត្រចៀក ពីបុគ្គលទាំងឡាយដែលពោលថា ព្រះខីណាស្រពឈ្មោះឯណោះរមែងនៅក្នុងដែន ជនបទ ស្រុក និគម វិហារ ឬក្នុងល្អាងឈ្មោះឯណោះ ការបានស្តាប់នោះ ក៏មានឧបការៈច្រើនដូចគ្នា ។ បទថា **ការចូលទៅរក (ឧបសង្កមនំ)** បានដល់ ការចូលទៅរកព្រះអរិយៈដោយចិត្ត យ៉ាងនេះថា យើងនឹងថ្វាយទាន ឬនឹងសួរបញ្ហា យើងនឹងស្តាប់ធម៌ ឬយើងនឹងធ្វើសក្ការៈ ។ បទថា **ការចូលទៅអង្គុយជិត (បយិរុបាសនំ)** បានដល់ ការចូលទៅអង្គុយជិតដើម្បីនឹងសួរ ។ អធិប្បាយថា ការស្តាប់គុណរបស់ព្រះអរិយៈ ចូលទៅរកព្រះអរិយៈទាំងនោះ និមន្ត ថ្វាយទាន សួរបញ្ហា ដោយន័យជាដើមថា លោកម្ចាស់ដ៏ចម្រើន អ្វីជាកុសល ដូច្នេះ ។

បទថា **ការរឭកដល់ (អនុស្សតិ)** បានដល់ ការរឭកដល់ភិក្ខុអ្នកអង្គុយនៅក្នុងពាក់កណ្តាលយប់ និងពាក់កណ្តាលថ្ងៃថា ឥឡូវនេះ ព្រះអរិយៈ

ទាំងឡាយ ឲ្យវលោកនូវទៅហើយដោយភាពជាសុខកើតពីឈាន វិបស្សនា មគ្គ និងផលក្នុងទី មានផ្ទះស្ងាត់ ល្អាងភ្នំ និងមណ្ឌបជាដើម ។ មួយទៀត ឱវាទណា ដែលយើងបានហើយក្នុងសម្នាក់របស់ព្រះអរិយៈទាំងនោះ ការចែកឱវាទនោះ ហើយរឭកដល់យ៉ាងនេះថា ក្នុងទីនេះលោកពោលដល់សីល ក្នុងទីនេះលោកពោលដល់សមាធិ ក្នុងទីនេះលោកពោលដល់វិបស្សនា ក្នុងទីនេះលោកពោលដល់មគ្គ ក្នុងទីនេះលោកពោលដល់ផល ។ បទថា **ការបួសតាម (អនុបព្វជ្ជំ)** បានដល់ ការញ៉ាំងចិត្តឲ្យជ្រះថ្លាក្នុងព្រះអរិយៈ ហើយចេញចាកផ្ទះ បួសក្នុងសម្នាក់របស់ព្រះអរិយៈទាំងនោះ ។ មួយទៀត ការបួសរបស់បុគ្គលដែលញ៉ាំងចិត្តឲ្យជ្រះថ្លាក្នុងសម្នាក់របស់ព្រះអរិយៈ បួសក្នុងសម្នាក់របស់លោកទាំងនោះ បំណងប្រព្រឹត្តតាមឱវាទានុសាសនីរបស់លោក ឈ្មោះថា ការបួសតាម ។ ការបួសរបស់បុគ្គលបំណងប្រព្រឹត្តតាមឱវាទានុសាសនីក្នុងសម្នាក់បុគ្គលដទៃក្តី របស់បុគ្គលដែលបួសក្នុងទីដទៃដោយការជ្រះថ្លាក្នុងព្រះអរិយៈ បំណងប្រព្រឹត្តតាមឱវាទានុសាសនី ក្នុងសម្នាក់របស់ព្រះអរិយៈក្តី ឈ្មោះថា ការបួសតាម ។ ចំណែកការបួសរបស់បុគ្គលដែលបួសក្នុងសម្នាក់នៃម្ចាស់លទ្ធិដទៃ ដោយការជ្រះថ្លាក្នុងម្ចាស់លទ្ធិដទៃ បំណងប្រព្រឹត្តតាមឱវាទានុសាសនីរបស់ម្ចាស់លទ្ធិដទៃ មិនឈ្មោះថា

បួសតាម ។

ក៏ក្នុងបព្វជិតទាំងឡាយ បព្វជិតដែលបួសតាមព្រះមហាកស្សបត្ថេរ យ៉ាងនេះ គ្រាដំបូងមានប្រមាណមួយសែនរូប ។ ដែលបួសតាមព្រះចន្ទ-គុត្តត្ថេរ ភិក្ខុជាសទ្ធិវិហារិករបស់ព្រះថេរៈនោះ ក៏មានប្រមាណប៉ុណ្ណោះដូចគ្នា ។ ព្រះសុរិយគុត្តត្ថេរ ជាសទ្ធិវិហារិករបស់ព្រះចន្ទគុត្តត្ថេរនោះក្តី ព្រះអស្សគុត្តត្ថេរ ជាសទ្ធិវិហារិករបស់ព្រះសុរិយគុត្តត្ថេរនោះក្តី ព្រះយោ-នកធម្មរក្ខិតត្ថេរ ជាសទ្ធិវិហារិករបស់ព្រះអស្សគុត្តត្ថេរនោះក្តី ក៏មានប្រមាណប៉ុណ្ណោះដូចគ្នា ។ ចំណែកព្រះអនុជរបស់ **ព្រះបាទអសោក** ជាសទ្ធិវិហារិករបស់ព្រះយោនកធម្មរក្ខិតត្ថេរ ឈ្មោះថា **តិស្សត្ថេរ** បព្វជិតបួសតាមព្រះ-តិស្សត្ថេរនោះ រាប់បាន ២ កោដិកន្លះ ។ ភិក្ខុអ្នកបួសតាមព្រះមហិន្ទត្ថេរ កំណត់រាប់មិនបាន ។ កាលបុគ្គលបួសដោយសទ្ធាក្នុងព្រះសាស្តា ក្នុងកោះលង្ការហូតដល់ថ្ងៃនេះ ក៏ឈ្មោះថា បួសតាមព្រះមហិន្ទត្ថេរដូចគ្នា ។

បទថា **ធម៌នោះ (តំ ធម្មំ)** បានដល់ ធម៌ គឺ ឱវាទានុសាសនីរបស់លោកទាំងនោះ ។ បទថា **អនុស្សរតិ** ប្រែថា រមែងរឭក ។ បទថា **រមែងត្រិះរិះ (អនុវិតក្កេតិ)** បានដល់ ធ្វើឲ្យវិតក្កៈនាំទៅ ។

[៣៧៤] បទថា **ប្រារព្ធហើយ (អារទ្ធោ ហោតិ)** បានដល់ បរិបូណ៌ ។

បទជាដើមថា **ជ្រើសរើស (បវិចិនតិ)** ទាំងអស់ លោកពោលដោយអំណាចការត្រាច់ទៅដោយញាណក្នុងធម៌នោះ ។ មា្យ៉ាងទៀត បទថា **បវិចិនតិ** បានដល់ ជ្រើសរើសលក្ខណៈនៃធម៌នោះៗ ។ បទថា **ពិចារណា (បវិចរតិ)** បានដល់ ញុំាងញាណឲ្យត្រាច់ទៅក្នុងធម៌នោះ ។ បទថា **សូម្បីការពិនិត្យពិចារណា (បរិវីមំសមាបជ្ជតិ)** បានដល់ រមែងដល់ការពិចារណា ពិនិត្យមើល ស្រាវជ្រាវ ។

[៣៨១] បទថា **មានផលានិសង្ស ៧ ប្រការ (សត្ត ផលា សត្តានិសំសា)** នោះ បទទាំងពីរនោះ ដោយអត្ថតែម្យ៉ាងដូចគ្នា ។

[៣៨២] បទថា **ក្នុងបច្ចុប្បន្ននឹងបានសម្រេចព្រះអរហន្តដោយឆាប់ (ទិដ្ឋេវ ធម្មេ បដិច្ច អញ្ញំ អារាធេតិ)** បានដល់ កាលសម្រេចអរហត្តផលក៏បានសម្រេចក្នុងអត្តភាពនេះឯង ។ មួយទៀត រមែងសម្រេចអរហត្តផលនោះឯងមុន អធិប្បាយថា កាលសម្រេចមិនបាន ក៏នឹងសម្រេចក្នុងមរណកាល ។ បទថា **ទីនោះ ក្នុងវេលាជិតស្លាប់ (អថ មរណកាលេ)** បានដល់ រមែងសម្រេចអរហត្តផលក្នុងវេលាជិតនឹងស្លាប់ ។

បទថា **ព្រះអនាគាមីដែលជាអន្តរបរិនិព្វាយី (អន្តរាបរិនិព្វាយី)** សេចក្តីថា អន្តរាបរិនិព្វាយីណា អាយុនៅមិនទាន់ដល់ពាក់កណ្តាល បរិនិព្វានមុន

អន្តរាបរិនិព្វាយីនោះ មាន ៣ យ៉ាង គឺ លោកកើតក្នុងជាន់អវិហា មានអាយុមួយពាន់កប្ប នឹងសម្រេចព្រះអរហត្តផល គ្រាដំបូងក្នុងថ្ងៃដែលខ្លួនកើតនោះឯង ។ បើមិនសម្រេចក្នុងថ្ងៃដែលខ្លួនកើត ក៏នឹងសម្រេចក្នុងទីបំផុតនៃមួយរយកប្ប នេះជាអន្តរាបរិនិព្វាយីទីមួយ ។ មួយទៀត កាលមិនអាចយ៉ាងនេះ នឹងសម្រេចក្នុងទីបំផុតនៃ ២ រយកប្ប នេះជាអន្តរាបរិនិព្វាយីទីពីរ ។ មួយទៀត កាលមិនអាចយ៉ាងនេះ នឹងសម្រេចក្នុងទីបំផុតនៃ ៤ រយកប្ប នេះជាអន្តរាបរិនិព្វាយី ទី ៣ ។ ក៏កន្លងផុតកប្បទី ៥០០ ទើបសម្រេចអរហត្តផល ឈ្មោះថា **ឧបហច្ចបរិនិព្វាយី** ។ សូម្បីក្នុងជាន់អតប្បាក៏មានន័យនេះដូចគ្នា ។ ក៏លោកកើតក្នុងទីណាមួយ សម្រេចអរហត្តផលហើយ ដោយការប្រកបប្រឹងប្រែងមាន (?) មានបច្ច័យតាក់តែង ឈ្មោះថា **សសង្ខារបរិនិព្វាយី** ។ សម្រេចអរហត្តផលហើយ ដោយការមិនប្រកប ទាំងមិនមានបច្ច័យតាក់តែង ឈ្មោះថា **អសង្ខារបរិនិព្វាយី** ។ លោកកើត សូម្បីក្នុងជាន់អវិហាជាដើម ស្ថិតនៅក្នុងជាន់នោះរហូតអស់អាយុ ហើយកើតក្នុងជាន់ខ្ពស់ៗ ឡើងទៅ រហូតដល់អកនិដ្ឋព្រហ្ម ឈ្មោះថា **ឧទ្ធំសោតោអកនិដ្ឋគាមី** ។

ព្រះអនាគាមី ៤៨ គួរពោលទុកក្នុងទីនេះផង ក៏ក្នុងជាន់អវិហា អន្ត-

រាបរិនិព្វាយីមាន ៣ ឧបហច្ចបរិនិព្វាយីមាន ១ ឧទ្ធំសោតោអកនិដ្ឋគាមីមាន ១ រួមជា ៥ ។ អសង្ខារបរិនិព្វាយីទាំងនោះ ៥ សសង្ខារបរិនិព្វាយី ៥ រួមជា ១០ ។ ក្នុងជាន់អតប្បាជាដើមក៏យ៉ាងនោះ ចំណែកក្នុងជាន់អកនិដ្ឋព្រហ្ម មិនមានឧទ្ធំសោតោ ។ ព្រោះដូច្នោះ ក្នុងជាន់អកនិដ្ឋព្រហ្មនោះ មានសសង្ខារបរិនិព្វាយី ៤ មានអសង្ខារបរិនិព្វាយី ៤ រួមជា ៨ ។ ទើបបានព្រះអនាគាមីបាន ៤៨ ដោយប្រការដូច្នេះ ។ បណ្តាព្រះអនាគាមីទាំងនោះ **ឧទ្ធំសោតោអកនិដ្ឋគាមី** រមែងជាធំជាងគេទាំងអស់ និងមានតិចជាងគេ ។

សួរថា ហេតុអ្វី?

ឆ្លើយថា ក៏លោកឈ្មោះថា ធំជាងព្រះអនាគាមីទាំងពួង ដោយអាយុ ព្រោះមានអាយុ ១ ម៉ឺន ៦ ពាន់កប្ប ។ ឈ្មោះថា មានតិចជាងព្រះអនាគាមីទាំងពួង ព្រោះសម្រេចអរហត្តផលក្រោយគេបង្អស់ ។ ក្នុងសូត្រនេះ លោកពោលពោជ្ឈង្គៈដែលជាបុព្វភាគវិបស្សនានៃអរហត្តមគ្គ ដែលមានលក្ខណៈផ្សេងៗ ប្រព្រឹត្តក្នុងខណៈនៃចិត្តមួយដួង មិនមុន មិនក្រោយ ។

ចប់អដ្ឋកថា សីលសូត្រទី ៣

# អ ដ្ឋ ក ថា

## វត្ថសូត្រទី ៤

គប្បីជ្រាបវិនិច្ឆ័យក្នុង វត្ថសូត្រទី ៤ ។

[៣៨៥] បទថា **បើសតិសម្ពោជ្ឈង្គៈមានហើយដល់ខ្ញុំ ដូចពណ៌នាមកនេះ (សតិសម្ពោជ្ឈង្គោ ឥតិ ចេ មេ ហោតិ)** សេចក្ដីថា បើសតិសម្ពោជ្ឈង្គៈ រមែងមានដល់ខ្ញុំដូចពណ៌នាមកនេះ ។ បទថា **ខ្ញុំក៏ដឹងថាសតិសម្ពោជ្ឈង្គៈកើតមានដល់ខ្ញុំរកប្រមាណមិនបាន (អប្បមាណោតិ មេ ហោតិ)** សេចក្ដីថា ខ្ញុំដឹងថា សតិសម្ពោជ្ឈង្គៈរបស់ខ្ញុំរកប្រមាណមិនបានយ៉ាងនេះ ។ បទថា **ដែលខ្ញុំប្រារព្ធល្អហើយ (សុសមារទ្ធោ)** បានដល់ បរិបូណ៌ល្អហើយ ។ ក្នុងបទថា **តាំងនៅ (តិដ្ឋតិ)** នេះ សតិសម្ពោជ្ឈង្គៈរមែងតាំងនៅ ដោយអាការ ៨ ។ គឺ ព្រះថេរៈរមែងដឹងថា សតិសម្ពោជ្ឈង្គៈ ឈ្មោះថា តាំងនៅ ព្រោះមិនរឭកដល់ការកើត ព្រោះរឭកដល់ការមិនកើត ព្រោះមិនរឭកដល់ការប្រព្រឹត្តទៅ ព្រោះរឭកដល់ការមិនប្រព្រឹត្តទៅ ព្រោះមិនរឭកដល់និមិត្ត ព្រោះរឭកដល់ការមិនមាននិមិត្ត ។ សតិសម្ពោជ្ឈង្គៈ ឈ្មោះថា តាំងនៅ ព្រោះមិនរឭកដល់សង្ខារ ព្រោះរឭកដល់អសង្ខារ ដូច្នោះ សតិសម្ពោជ្ឈង្គៈ

ទើបតាំងនៅដោយអាការទាំង ៨ នេះឯង ។ ព្រះថេរៈរមែងដឹងច្បាស់ដល់សតិសម្ពោជ្ឈង្គៈ កាលប្រព្រឹត្ត[១] រមែងប្រព្រឹត្តដោយអាការ ៨ ផ្ទុយគ្នានឹងអាការដែលពោលហើយនោះឯង ។ សូម្បីក្នុងពោជ្ឈង្គៈដ៏សេស ក៏មានន័យនេះឯង សូត្រនេះ លោកពោលពោជ្ឈង្គៈដែលទាក់ទងជាមួយផលសមាបត្តិ[២] របស់ព្រះថេរៈ ។

ក៏កាលណាព្រះថេរៈធ្វើសតិសម្ពោជ្ឈង្គៈឲ្យជាគោល រមែងចូលផលសមាបត្តិ កាលនោះពោជ្ឈង្គៈ ៦ ក្រៅនេះ រមែងទៅតាមសតិសម្ពោជ្ឈង្គៈនោះ ។ កាលណា ព្រះថេរៈធ្វើពោជ្ឈង្គៈណាមួយឲ្យជាគោល ក្នុងបណ្តាពោជ្ឈង្គៈ មានធម្មវិចយៈជាដើម ពេលនោះ ពោជ្ឈង្គៈដ៏សេសរមែងទៅតាមពោជ្ឈង្គៈនោះឯង ។ ព្រះថេរៈ កាលសម្តែងភាពជំនាញដែលប្រព្រឹត្តមករបស់ខ្លួន ក្នុងផលសមាបត្តិយ៉ាងនេះ ទើបពោលសូត្រនេះ ដោយប្រការដូច្នេះ ។

ចប់អដ្ឋកថា វត្ថសូត្រទី ៤

---

១-បាលីជា ចវតិ (កម្រើកទៅ)

២-ដីកាជា ផលពោជ្ឈង្គា ប្រែតាមដីកា

# អ ដ្ឋ ក ថា

## ភិក្ខុសូត្រទី ៥

[៣៩០] គប្បីជ្រាបវិនិច្ឆ័យក្នុង ភិក្ខុសូត្រទី ៥ ។

[៣៩៣] បទថា ប្រព្រឹត្តទៅដើម្បីត្រាស់ដឹង (ពោធាយ សំវត្តន្តិ) សេចក្តីថា រមែងប្រព្រឹត្តទៅដើម្បីសេចក្តីត្រាស់ដឹង ។

សួរថា ដើម្បីត្រាស់ដឹងអ្វី?

ឆ្លើយថា ត្រាស់ដឹងព្រះនិព្វាន ដែលបច្ច័យតាក់តែងមិនបាន ដោយមគ្គ ត្រាស់ដឹងកិច្ចដែលខ្លួនធ្វើហើយ ដោយបច្ចវេក្ខណញ្ញាណ ។ មានអធិប្បាយថា ម្យ៉ាងទៀត ពោជ្ឈង្គៈរមែងប្រព្រឹត្តទៅដើម្បីត្រាស់ដឹង ព្រោះការលះបង់កិលេសបានដោយមគ្គ ដើម្បីភាពជាពុទ្ធៈដោយផល ដូច្នេះ ក៏មាន ។ ដោយហេតុនោះឯង ក្នុងទីនេះ លោកទើបសម្តែងទុកទាំងអស់ថា ការធ្វើព្រះនិព្វានឲ្យជាក់ច្បាស់ ការលះបង់កិលេស ការពិចារណា ។

ចប់អដ្ឋកថា ភិក្ខុសូត្រទី ៥

# អ ដ្ឋ ក ថា

## កុណ្ឌលិយសូត្រទី ៦

គប្បីជ្រាបវិនិច្ឆ័យក្នុង កុណ្ឌលិយសូត្រទី ៦ ។

[៣៩៤] បទថា ពេញចិត្តត្រាច់ទៅក្នុងសួនច្បារ[១] (អារាមនិយាទិ) បានដល់ ឈ្មោះថា ត្រាច់ទៅក្នុងសួនច្បារ ព្រោះអាស្រ័យសួនច្បារជាទីទៅ ។ បទថា ពេញចិត្តចូលទៅកាន់ទីជំនុំជន (បរិសាវចរោ) បានដល់ ត្រាច់ទៅក្នុងបរិស័ទ ។ បុគ្គលពាលខ្លះ បណ្ឌិតខ្លះ មករួមគ្នាហើយ ឈ្មោះថា បរិស័ទ ។ ចំណែកបុគ្គលណាអាចញាំញីវាទៈរបស់បុគ្គលដទៃ ទើបសម្តែងវាទៈរបស់ខ្លួនបាន បុគ្គលនេះឈ្មោះថា ត្រាច់ទៅក្នុងបរិស័ទ ។ បទថា ចេញពីសួនច្បារទៅកាន់សួនច្បារ (អារាមេន អារាមំ) សេចក្តីថា ខ្ញុំម្ចាស់ដើរទៅរឿយៗ ពីសួនច្បារមួយទៅសួនច្បារមួយ អធិប្បាយថា មិនបានដើរទៅខាងក្រៅ សូម្បីក្នុងឧទ្យាន ក៏មានន័យនេះដូចគ្នា ។ ក្នុងប្រការនេះ មានសេចក្តីដូច្នេះថា ចេញពីសួនច្បារមួយទៅកាន់សួនច្បារមួយ ចេញពីឧទ្យានមួយទៅកាន់ឧទ្យានមួយ ។ បទថា មានវាទៈ និងដោះស្រាយនូវ

---

១-ប្រែសេចក្តីតាមបិដក ។

វាទៈ នេះជាអានិសង្ស (ឥតិ វាទប្បមោក្ខានិសំសំ) សេចក្តីថា វាទៈដូច្នេះ ការដោះវាទៈដូច្នេះ ដោយន័យនេះថា ការសួរមានយ៉ាងនេះ ការឆ្លើយមានយ៉ាងនេះ ការកាន់យកសេចក្តីយ៉ាងនេះ កែសេចក្តីយ៉ាងនេះ ដូច្នេះ នោះជាអានិសង្ស ។ បទថា **មានការជំទាស់ជាអានិសង្ស (ឧបារម្ភានិសំសំ)** បានដល់ មានទោសក្នុងវាទៈជាអានិសង្ស យ៉ាងនេះថា នេះជាទោសក្នុងការសួរ នេះជាទោសក្នុងការឆ្លើយ ដូច្នេះ ។

[៣៩៦] បទថា **កុណ្ឌលិយ ឥន្ទ្រិយសំវរៈដែលបុគ្គលចម្រើនហើយដូចម្តេច (កថំ ភាវិតោ កុណ្ឌលិយ ឥន្ទ្រិយសំវរោ)** សេចក្តីថា ព្រះសាស្តាទ្រង់ជ្រាបថា ក៏បរិព្វាជកសួរឋានៈមានប្រមាណប៉ុណ្ណេះហើយ ពេលនេះគេមិនអាចនឹងសួរទៀត កាលទ្រង់សួរ ទើបទ្រង់ផ្តើមទេសនានេះដោយព្រះអង្គដោយទ្រង់ព្រះតម្រិះថា គ្រាដំបូង ទេសនានេះមិនប្រព្រឹត្តទៅតជាប់គ្នា ឥឡូវនេះ តថាគតនឹងឲ្យទេសនានេះជាប់តគ្នា ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **មិនត្រេកអរនឹងអារម្មណ៍ដែលគួរពេញចិត្ត (មនាបំ នាភិជ្ឈាយតិ)** បានដល់ រមែងមិនសម្លឹងអារម្មណ៍ដែលគួរប្រាថ្នា ។ បទថា **មិនទាស់ចិត្ត (នាភិហំសតិ)** បានដល់ រមែងមិនទាស់ចិត្តព្រោះសេចក្តីត្រេកអរល្អដែលមានអាមិស ។ បទថា **កាយរបស់អ្នកតាំងមាំក្នុងខាងក្នុង**

(តស្ស ឋិតោ ច កាយោ ហោតិ ឋិតំ ចិត្តំ អជ្ឈត្តំ) សេចក្តីថា នាមកាយ និងចិត្តរបស់អ្នកតម្កល់នៅក្នុងអារម្មណ៍ ។ បទថា **តាំងនៅដោយល្អ** (សុស-ណ្ឋិតំ) បានដល់ តាំងមាំដោយល្អដោយអំណាចកម្មដ្ឋាន ។ បទថា **រួចផុតល្អហើយ** (សុវិមុត្តំ) បានដល់ រួចផុតល្អហើយដោយកម្មដ្ឋាន ។ បទថា **មិនពេញចិត្ត** (អមនាបំ) បានដល់ អារម្មណ៍ដែលមិនគួរប្រាថ្នា ។ បទថា **មិនមានមុខជ្រប់** (ន មង្កុ ហោតិ) បានដល់ រមែងមិនមានមុខជ្រប់ក្នុងរូបនោះ ។ បទថា **មានចិត្តមិនតាំងខ្ជាប់ដោយអំណាចកិលេស** (អប្បតិដ្ឋិត-ចិត្តោ) បានដល់ មានចិត្តមិនតាំងនៅដោយអំណាចកិលេស ។ បទថា **មិនទាស់ចិត្ត** (អាទិន្នមានសោ) បានដល់ មានចិត្តដែលកិលេសប្រកាន់ដោយអំណាចទោមនស្សមិនបាន ។ បទថា **មានចិត្តមិនព្យាបាទ** (អព្យាបន្ន-ចេតសោ) បានដល់ មានចិត្តមិនតាំងនៅដោយអំណាចទោសៈ ។

ក្នុងបទថា កុណ្ឌលិយៈ ឥន្ទ្រិយសំវរៈដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយយ៉ាងនេះ រមែងញុំាងសុចរិត ៣ ឲ្យ បរិបូណ៌ (ឯវំ ភាវិតោ ខោ កុណ្ឌលិយ ឥន្ទ្រិយសំវរោ ឯវំ ពហុលីកតោ តីណិ សុចរិតានិ បរិបូរេតិ) នេះ គប្បីជ្រាបការញុំាងសុចរិតឲ្យបរិបូណ៌យ៉ាងនេះ ទុចរិតទាំងឡាយមាន ១៨ ក្នុងទ្វារទាំង ៦ នេះមុន ។

សួរថា កើតមានដូចម្ដេច?

ឆ្លើយថា កាលមិនឲ្យចំណែកកាយ និងវាចាកម្រើក ក្នុងអារម្មណ៍ដែលគួរប្រាថ្នា មកកាន់គន្លងនៃចក្ខុទ្វារគ្រាដំបូង តែញ៉ាំងសេចក្ដីលោភឲ្យកើតឡើងក្នុងអារម្មណ៍នោះ ចាត់ជា**មនោទុច្ចរិត** ។ កាលនិយាយដោយចិត្តប្រកបដោយលោភៈថា ឱហ្ន៎ វត្ថុនេះគួរប្រាថ្នា គួរស្រឡាញ់ គួរពេញចិត្ត ដូច្នេះ ចាត់ជា**វចីទុច្ចរិត** ។ កាលយកដៃប៉ះពាល់វត្ថុនោះប៉ុណ្ណោះ ចាត់ជា**កាយទុច្ចរិត** ។ សូម្បីក្នុងទ្វារដ៏សេស ក៏មានន័យនេះដូចគ្នា ។

ចំណែកការផ្សេងគ្នា ដូច្នេះ ព្រោះថា ពេលប៉ះពាល់គ្រឿងតន្ត្រី មានស័ង្ខ និងស្គរតូចជាដើម ដែលជាអនាមាសៈ ដែលជាទីតាំងនៃសទ្ទារម្មណ៍ក្នុងសោតទ្វារ ប៉ះពាល់របស់ក្រអូប និងផ្កាឈើជាដើម ដែលជាទីតាំងនៃគន្ធារម្មណ៍ក្នុងឃានទ្វារ ។ ប៉ះពាល់ត្រី និងសាច់ជាដើម ដែលជាទីតាំងនៃរសារម្មណ៍ក្នុងជិវ្ហាទ្វារ ។ ប៉ះពាល់ចីវរជាដើម ដែលជាទីតាំងនៃផោដ្ឋព្វារម្មណ៍ ក្នុងកាយទ្វារ កាលប៉ះពាល់ ទឹកដោះថ្លា ប្រេង ទឹកឃ្មុំ និងទឹកអំពៅជាដើម ដែលជាធម្មារម្មណ៍ ដោយអំណាចនៃបញ្ញត្តិក្នុងមនោទ្វារ គប្បីជ្រាបថា ជាកាយទុច្ចរិត ។ ប៉ុន្តែបើពោលដោយសង្ខេបក្នុងប្រការនេះ មានទុច្ចរិត ៣ ប៉ុណ្ណោះ គឺ ការល្មើសផ្លូវកាយក្នុងទ្វារ ៦ ចាត់ជាកាយទុច្ចរិត

ការល្មើសផ្លូវវាចា ចាត់ជាវចីទុច្ចរិត ការល្មើសផ្លូវចិត្ត ចាត់ជាមនោទុច្ចរិត ។

ចំណែកភិក្ខុនេះ តាំងមាំនៅក្នុងការពិចារណាការនារបស់ខ្លួន រមែងប្រព្រឹត្តសុចរិតទាំងនេះឲ្យជាសុចរិតធម៌ ។

សួរថា ប្រព្រឹត្តដូចម្តេច?

ឆ្លើយថា កាលមិនញ៉ាំងចំណែកកាយ និងវាចាឲ្យកម្រើក ពេលអារម្មណ៍ដែលគួរប្រាថ្នា មកកាន់គន្លងនៃចក្ខុទ្វារគ្រាដំបូង ប្រាថ្នាហើយនូវវិបស្សនាដែលមានរូបជាអារម្មណ៍ ចាត់ជា **មនោសុចរិត** ។ កាលនិយាយដោយចិត្តដែលប្រកបដោយវិបស្សនាថា មានការអស់ទៅជាធម្មតា មានការសូន្យទៅជាធម្មតា ចាត់ជា **វចីសុចរិត** ។ ពេលមិនប៉ះពាល់ ដោយគិតថាវត្ថុនេះជាអនាមាសៈ ចាត់ជាកាយសុរិត ។ សូម្បីក្នុងទ្វារដ៏សេស ក៏មានន័យនេះដូចគ្នា ។ ពោលដោយពិស្តារ សុចរិតមាន ១៨ ដោយទ្វារដ៏សេសដោយប្រការដូច្នេះ ។ តែដោយសង្ខេប ក្នុងប្រការនេះ មានសុចរិត ៣ ប៉ុណ្ណោះ គឺ ការសង្រួមផ្លូវកាយក្នុងទ្វារ ៦ ចាត់ជាកាយសុចរិត ការសង្រួមផ្លូវវាចាចាត់ជាវចីសុរិត ។ ការសង្រួមផ្លូវចិត្ត ចាត់ជាមនោសុចរិត ។ ការសង្រួមឥន្ទ្រិយយ៉ាងនេះ គប្បីជ្រាបថា រមែងញ៉ាំងសុចរិត ៣ ឲ្យបរិបូណ៌ ។ លោកពោលដល់ឥន្ទ្រិយសំវរៈសីល ដែលសីលតាមរក្សាហើយ ដោយហេតុ

មានប្រមាណប៉ុណ្ណេះ ។

[៣៩៧] ក្នុងបទជាដើមថា *លះបង់កាយទុច្ចរិត (កាយទុច្ចរិតំ បហាយ)* បានដល់ កាយទុច្ចរិត ៣ យ៉ាង វចីទុច្ចរិត ៤ យ៉ាង មនោទុច្ចរិត ៣ យ៉ាង ។ គប្បីជ្រាបកាយសុចរិតជាដើម ដោយអំណាចផ្ទុយគ្នាជាមួយកាយទុច្ចរិតជាដើមនោះ ដោយពាក្យប្រមាណប៉ុណ្ណេះ ជាការដែលលោកពោលដល់បាតិមោក្ខសីល ដោយការសង្រួមផ្លូវកាយ និងផ្លូវវាចា ។ សីល ៣ ដោយការសង្រួមផ្លូវចិត្ត ដូច្នោះ ទើបរមែងជាការដែលលោកពោលហើយដល់ចតុប្បារិសុទ្ធិសីល ។ ចំណែកក្នុងសូត្រនេះ គប្បីជ្រាបថា លោកពោលសតិប្បដ្ឋាន មានសុចរិតជាមូល ថា លាយគ្នាដោយលោកុត្តរៈ ។ សតិប្បដ្ឋានជាមូលនៃពោជ្ឈង្គៈ ៧ ថាជាបុព្វភាគ ។ ពោជ្ឈង្គៈ មានសតិប្បដ្ឋានជាមូល សូម្បីទាំងនោះថា ជាបុព្វភាគ ។ ចំណែកពោជ្ឈង្គៈដែលជាមូលនៃវិជ្ជា និងវិមុត្តិ គប្បីជ្រាបថា លោកពោលថា ជាលោកុត្តរៈតែម្យ៉ាង ។

ចប់អដ្ឋកថា កុណ្ឌលិយសូត្រទី ៦

# អ ដ្ឋ ក ថា

## កូដសូត្រទី ៧

*ចំណែកអដ្ឋកថាកូដសូត្រទី ៧ មានសេចក្តីងាយទាំងនោះឯង ។*

# អ ដ្ឋ ក ថា

## ឧបវាណសូត្រទី ៨

គប្បីជ្រាបវិនិច្ឆ័យក្នុង ឧបវាណសូត្រទី ៨

[៤០៣] បទថា **បច្ចត្តំ** គឺ ចំពោះខ្លួន ។ បទថា **យោនិសោមនសិការា** បានដល់ ការធ្វើទុកក្នុងចិត្តដោយឧបាយត្រូវទំនង ។

[៤០៤] បទថា **ប្រារព្ធ (អារទ្ធមានោ)** បានដល់ ធ្វើហើយ ។ បទថា **រួចផុតល្អហើយ (សុវិមុត្តំ)** បានដល់ រួចផុតដោយកម្មដ្ឋាន ។ បទថា **ពិតប្រាកដ (អដ្ឋិកត្វា)** បានដល់ ធ្វើឲ្យជាប្រយោជន៍ អធិប្បាយថា មានសេចក្តីត្រូវការ ។

ចប់អដ្ឋកថា ឧបវាណសូត្រទី ៨

# អ ដ្ឋ ក ថា

## បឋមឧប្បាទសូត្រទី ៩

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមឧប្បាទសូត្រទី ៩*

[៤០៧] *បទថា ក្រៅពីការប្រាកដនៃព្រះតថាគត ។បេ។ រមែងមិនកើត (នាញ្ញត្រ តថាគតស្ស បាតុភាវា) សេចក្តីថា វៀរការប្រាកដនៃព្រះតថាគត ពោជ្ឈង្គៈរមែងមិនកើតឡើងក្នុងកាលដទៃ ។*

ចប់អដ្ឋកថា បឋមឧប្បាទសូត្រទី៩

# អ ដ្ឋ ក ថា

## ទុតិយឧប្បាទសូត្រទី ១០

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយឧប្បាទសូត្រទី ១០ ។*

[៤០៨] *បទថា ក្រៅពីវិន័យរបស់ព្រះសុគត រមែងមិនកើត (នាញ្ញត្រ សុគតវិនយា) សេចក្ដីថា វៀរព្រះឱវាទរបស់ព្រះសុគតជាម្ចាស់ចេញហើយ ពោជ្ឈង្គៈរមែងមិនកើតឡើង ដូច្នេះ ។*

ចប់អដ្ឋកថា ទុតិយឧប្បាទសូត្រទី ១០

## ចប់បព្វតវគ្គវណ្ណនាទី ១

## រួមអដ្ឋកថាក្នុងវគ្គនេះ គឺ

១ អដ្ឋកថា ហេមវន្តសូត្រ ២ អដ្ឋកថា កាយសូត្រ
៣ អដ្ឋកថា សីលសូត្រ ៤ អដ្ឋកថា វត្ថសូត្រ
៥ អដ្ឋកថា ភិក្ខុសូត្រ ៦ អដ្ឋកថា កុណ្ឌលិយសូត្រ
៧ អដ្ឋកថា ឧបវាណសូត្រ ៨ អដ្ឋកថា បឋមឧប្បាទសូត្រ
៩ អដ្ឋកថា ទុតិយឧប្បាទសូត្រ

# គិលានវគ្គទី ២

## អ ដ្ឋ ក ថា

### ចាណូបមសូត្រទី ១

*គប្បីជ្រាបវិនិច្ឆ័យក្នុង បាណូបមសូត្រទី ១ នៃ គិលានវគ្គទី ១ ។*

*[៤០៩] បទថា **សម្រេចឥរិយាបថ ៤ (ចត្តារោ ឥរិយាបថេ កប្បេន្តិ)** សេចក្តីថា ឥរិយាបថ ៤ របស់សត្វពួកណាមានហើយ ពាក្យនោះ លោកពោលដោយអំណាចនៃសត្វទាំងនោះប៉ុណ្ណោះ ។ បទថា **អាស្រ័យសីល (សីលំ និស្សាយ)** បានដល់ ធ្វើចតុប្បារិសុទ្ធិសីលឲ្យជាទីអាស្រ័យ ។ បទថា **ពោជ្ឈង្គៈ ៧ (សត្ត ពោជ្ឈង្គេ)** បានដល់ ពោជ្ឈង្គៈដែលជាមគ្គ ដែលឃើញច្បាស់រួមគ្នា ។*

ចប់អដ្ឋកថា ចាណូបមសូត្រ ទី ១

---

*សុរិយូបមសូត្រទី ២ និងទី ៣ មាន សេចក្តីងាយទាំងនោះឯង ។*

# អ ដ្ឋ ក ថា

## បឋមគិលានសូត្រទី ៤

[៤១៥] គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមគិលានសូត្រទី ៤ ។

[៤១៩] បទថា និងអាពាធនោះ ដែលព្រះមហាកស្សបលះបង់បានហើយ (តថា បហីនោ ចាយស្មតោ មហាកស្សបស្ស សោ អាពាធោ អហោសិ) សេចក្ដីថា បានឮថា កាលព្រះមហាកស្សបត្ថេរ តាំងចិត្តស្ដាប់ពោជ្ឈង្គភាវនានេះហើយ មានសេចក្ដីត្រិះរិះយ៉ាងនេះថា កាលយើងចាក់ធ្លុះនូវសច្ចៈទាំងឡាយក្នុងថ្ងៃទី ៧ ចាប់ពីថ្ងៃដែលយើងបួសហើយ ពោជ្ឈង្គៈទាំងនេះក៏ប្រាកដ ។ ក៏កាលលោកគិតថា ឱហ្ន៎! ពាក្យទូន្មានរបស់ព្រះសាស្ដានាំសត្វចេញអំពីទុក្ខ ដូច្នេះ លោហិតក៏ស្រស់ថ្លា ឧបាទាយរូប ក៏បរិសុទ្ធិ ។ រោគក៏វិនាសបាត់ទៅអំពីកាយ ដូចដំណក់ទឹកធ្លាក់ក្នុងស្លឹកឈូក ដូច្នោះ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ទើបត្រាស់ថា តថា បហីនោ ចាយ-ស្មតោ មហាកស្សបស្ស សោ អាពាធោ អហោសិ ដូច្នេះ ។

សូម្បីក្នុងគិលានសូត្រទី ៤ នឹងទី ៥ ក៏មានន័យនេះដូចគ្នា ។

អាពាធដែលកើតពីភាពត្រជាក់តិចៗ ដែលកើតឡើងដោយការពាល់

ត្រូវជាមួយខ្យល់អំពីដើមឈើ មានផ្កាជាពិសដែលរីកហើយ ត្រង់ដើងក្នុំ គប្បីជ្រាបថា ជាអាពាធរបស់ជនសូម្បីទាំង ៣ នេះ ។ ពាក្យដ៏សេសក្នុង បទទាំងពួង ងាយទាំងនោះឯង ។

ចប់អដ្ឋកថា បឋមគិលានសូត្រទី ៤

## ចប់គិលានវគ្គវណ្ណនាទី ២

## រួមអដ្ឋកថាក្នុងវគ្គនេះ គឺ

១ អដ្ឋកថា ចាណូបមសូត្រ ២ អដ្ឋកថា បឋមគិលានសូត្រ

# ឧទាយិវគ្គទី ៣

## អ ដ្ឋ ក ថា

## ពោធនសូត្រទី ១

គប្បីជ្រាបវិនិច្ឆ័យក្នុង ពោធនសូត្រទី ១ នៃ ឧទាយវគ្គទី ៣ ៖

[៤៣៥] បទថា បពិត្រព្រះអង្គដ៏ចម្រើន ដោយហេតុត្រឹមណាហ្ន៎ ទើបហៅថា ពោជ្ឈង្គៈ (កិត្តាវតា នុ ខោ ភន្តេ ពោជ្ឈង្គាតិ វុច្ចន្តិ) សេចក្តីថា ភិក្ខុទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ដែលហៅថា អង្គនៃសេចក្តីត្រាស់ដឹង ដោយហេតុត្រឹមណាហ្ន៎ ។ បទថា ប្រព្រឹត្តទៅដើម្បីត្រាស់ដឹង (ពោធាយ សំវត្តន្តិ) បានដល់ រមែងប្រព្រឹត្តដើម្បីការត្រាស់ដឹង ។ ក្នុងសូត្រនេះ លោកពោលពោជ្ឈង្គៈលាយចូលគ្នា ។

ចប់អដ្ឋកថា ពោធនសូត្រទី ១

# អ ដ្ឋ ក ថា

## ទេសនាសូត្រទី ២

[៤៣៧] *ការកំណត់ធម៌ លោកពោលទុកក្នុងទេសនាសូត្រទី ២ ។*

ចប់អដ្ឋកថា ទេសនាសូត្រទី ២

# អ ដ្ឋ ក ថា

## ឋានិយសូត្រទី ៣

គប្បីជ្រាបវិនិច្ឆ័យក្នុង ឋានិយសូត្រទី ៣ ៖

[៤៣៨] បទថា *ដែលជាទីតាំងនៃកាមរាគៈ (កាមរាគដ្ឋានិយានំ)* បានដល់ ធម៌ជាអារម្មណ៍ដែលជាហេតុនៃកាមរាគៈ ។ សូម្បីក្នុងធម៌ដែលជាទីតាំងនៃព្យាបាទជាដើម ក៏មានន័យនេះដូចគ្នា ។ ក៏សូត្រនេះទាំងអស់លោកពោលដោយអារម្មណ៍ប៉ុណ្ណោះ ។ សូម្បីការកំណត់ ដែលពោលក្នុងសូត្រទី ២ នៃវគ្គទី ១ អ្នកសិក្សារកបានក្នុងសូត្រនេះឯង ។

ក្នុង *អយោនិសោសូត្រទី ៤* លោកពោលពោជ្ឈង្គៈលាយគ្នា ។

ក្នុង *អបរិហានិយសូត្រទី ៥* បទថា *ធម៌ដែលមិនមែនជាទីតាំងនៃសេចក្តីវិនាស (អបរិហានិយេ ធម្មេ)* បានដល់ សភាវធម៌ដែលមិនធ្វើសេចក្តីវិនាស ។

ចប់អដ្ឋកថា ឋានិយសូត្រទី ៣

# អ ដ្ឋ ក ថា

## ខយសូត្រទី ៦

*គប្បីជ្រាបវិនិច្ឆ័យក្នុង **ខយសូត្រទី ៦** ។*

[៤៥០] *បទថា **បានទូលសួរថា (ឯតទវោច)** សេចក្ដីថា ព្រះឧទាយី កាលនឹងទូលសួរថា ខ្ញុំព្រះអង្គនឹងដឹងដល់ទេសនាដែលព្រះមានព្រះភាគជាម្ចាស់ទ្រង់ឲ្យចប់ហើយ ដោយព្រះតម្រិះថា ភិក្ខុអ្នកឆ្លាតក្នុងអនុសន្ធិ ឈ្មោះថា ឧទាយីថេរៈ អង្គុយនៅក្នុងបរិស័ទនេះឯង គេនឹងសួរតថាគត ដូច្នេះ ហើយបន្តអនុសន្ធិនៃទេសនា ទើបក្រាបទូលសួរដល់ប្រការនោះ ។ បទថា **ធំទូលាយ (វិបុលំ)** ជាដើម ត្រាស់សំដៅដល់សតិសម្ពោជ្ឈង្គៈ ដែលចម្រើនល្អហើយ ព្រោះថា សតិសម្ពោជ្ឈង្គៈដែលចម្រើនល្អហើយ ឈ្មោះថា ធំទូលាយ ជាមហគ្គតៈ រកប្រមាណមិនបាន និងមិនមានការបៀតបៀន ។ សតិសម្ពោជ្ឈង្គៈនោះឯង ឈ្មោះថា វិបុលៈ ព្រោះផ្សាយទៅ ។ ឈ្មោះថា មហគ្គតៈ ព្រោះដល់ភាពជាធំ ឈ្មោះថា អប្បមាណៈ ព្រោះមានសេចក្ដីចម្រើនរកប្រមាណមិនបាន ។ ឈ្មោះថា អព្យាបជ្ឈៈ ព្រោះវៀរការព្យាបាទ ដោយឃ្លាតឆ្ងាយពីនិវរណៈទាំងឡាយ ។ បទថា **ព្រោះលះតណ្ហាបាន ទើប***

លះកម្មបាន (តណ្ហាយ បហានា កម្មំ បហីយតិ) សេចក្ដីថា កម្មណាមាន តណ្ហាជាមូលគប្បីកើតឡើង រមែងលះកម្មនោះបាន ព្រោះការលះតណ្ហា ។ បទថា ព្រោះលះកម្មបាន ទើបលះទុក្ខបាន (កម្មស្ស បហានា ទុក្ខំ) សេចក្ដីថា វដ្ដទុក្ខឯណា មានកម្មជាមូលគប្បីកើតឡើង ព្រោះលះកម្មបាន ទើបលះវដ្ដទុក្ខនោះបាន ។ ឈ្មោះថា អស់តណ្ហាជាដើម ព្រោះអស់តណ្ហាជាដើមនោះឯង តែពោលដោយសភាវៈ គប្បីជ្រាបថា និព្វាន លោកពោលព្រោះការអស់ទៅនៃតណ្ហាទាំងនោះ ។

ចប់អដ្ឋកថា ១យស្សូត្រទី ៦

# អ ដ្ឋ ក ថា

## និរោធសូត្រទី ៧

*សូត្រទី ៧ មិនមានអដ្ឋកថាកែ ។*

# អ ដ្ឋ ក ថា

## និព្វេធសូត្រទី ៨

*គប្បីជ្រាបវិនិច្ឆ័យក្នុង និព្វេធសូត្រទី ៨ ។*

[៤៥៣] *បទថា ជាចំណែកនៃការចាក់ធ្លុះ (និព្វេធភាគិយំ) បានដល់ ចំណែកនៃការចាក់ធ្លុះ ។*

[៤៥៤] *បទថា ដែលសតិសម្ពោជ្ឈង្គៈអប់រំហើយ (សតិសម្ពោជ្ឈង្គភាវិតេន) សេចក្តីថា មានចិត្តដែលសតិសម្ពោជ្ឈង្គៈអប់រំហើយ ។ ឬថា ចិត្ត ដែលសតិសម្ពោជ្ឈង្គៈឲ្យចម្រើនហើយ តាំងមាំហើយ ក្នុងប្រការនេះ មានមគ្គ និងពោជ្ឈង្គៈលាយគ្នាយ៉ាងនេះ ចិត្តដែលចម្រើនមគ្គ និងសម្ពោជ្ឈង្គៈ ហើយតាំងមាំ ឈ្មោះថា ចិត្តដែលមគ្គ និងពោជ្ឈង្គៈឲ្យកើតហើយ ចាត់ជា លោកុត្តរៈ (ប៉ុណ្ណោះ) ក៏ការធ្វើពោជ្ឈង្គៈនោះឲ្យអាស្រ័យមគ្គហើយ ពោល ឲ្យលាយគ្នានោះឯង ទើបនឹងគួរ ។*

ចប់អដ្ឋកថា និព្វេធសូត្រទី ៨

# អ ដ្ឋ ក ថា

## ឯកធម្មសូត្រទី ៩

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឯកធម៌សូត្រទី ៩ ។*

[៤៥៧] *បទថា គ្រឿងចង គឺ សំយោជនៈ (សញ្ញោជនវិនិពន្ធា) បាន ដល់ គ្រឿងចង ពោលគឺ សំយោជនៈ ។ បទថា ការប្រកាន់មាំ (អជ្ឈោសានា) បានដល់ ឲ្យសម្រេចហើយនូវការប្រកាន់ ។*

ចប់អដ្ឋកថា ឯកធម្មសូត្រទី៩

# អ ដ្ឋ ក ថា

## ឧទាយិសូត្រទី ១០

គប្បីជ្រាបវិនិច្ឆ័យក្នុង ឧទាយិសូត្រទី ១០ ៖

[៤៥៩] បទថា អពហុកតោ ប្រែថា មិនធ្វើឲ្យច្រើន ។

[៤៦០] ក្នុងបទថា ការកើត និងការវិនាស (ឧក្កុជ្ជាវកុជ្ជំ) នេះ លោកសម្តែងថា ព្រះឧទាយីពិចារណាត្រឡប់ទៅត្រឡប់មក ដោយអំណាចការកើត និងការរលត់ ។ ការកើត ហៅថា ឧក្កុជ្ជៈ ។ ការរលត់ ហៅថា អវកុជ្ជៈ ។

[៤៦១] បទថា ធម៌ដែលខ្ញុំព្រះអង្គសម្រេចហើយ (ធម្មោ ច មេ ភន្តេ អភិសមេតោ) បានដល់ វិបស្សនាធម៌ ដែលខ្ញុំព្រះអង្គសម្រេចហើយ ។ បទថា មគ្គ (មគ្គោ) គឺ វិបស្សនាមគ្គ ។ ប្រសិនបើព្រះថេរៈជាសោតាបន្ន ក្នុងសម័យនោះ គប្បីជ្រាបវិបស្សនានេះ ដើម្បីប្រយោជន៍ដល់មគ្គទាំង ៣ ខាងលើ ។ បើជាអនាគាមី គប្បីជ្រាបវិបស្សនានេះ ដើម្បប្រយោជន៍ដល់អរហត្តមគ្គ ។ បទថា នៅដោយអាការនោះៗ (តថា តថា វិហរន្តំ) បានដល់ នៅដោយអាការៈនោះៗ ។ បទថា ដើម្បីភាពជាយ៉ាងនោះ (តថត្តាយ) បាន

*ដល់ ដើម្បីសភាពជាយ៉ាងនោះ ។ ដោយបទជាដើមថា* ***ជាតិអស់ហើយ (ខីណា ជាតិ)*** *ព្រះថេរៈសម្តែងសភាពជាយ៉ាងនោះ ដែលលោកបំណងថា ដើម្បីសភាពយ៉ាងនោះ ។ ក្នុងប្រការនេះ មានអធិប្បាយថា ព្រះថេរៈរមែងនាំយកធម៌នោះចូលមក ដើម្បីប្រយោជន៍ដល់ការពិចារណា កាលលោកសម្តែងធម៌នោះ ទើបពោលយ៉ាងនេះ ។ ពាក្យដ៏សេសក្នុងបទទាំងពួង មានសេចក្តីងាយទាំងនោះឯង ។*

ចប់អដ្ឋកថា ឧទាយិសូត្រទី ១០

## ចប់ឧទាយិវគ្គវណ្ណនាទី ៣

## រួមអដ្ឋកថាក្នុងវគ្គនេះ គឺ

១ អដ្ឋកថា ពោធនសូត្រ
២ អដ្ឋកថា ទេសនាសូត្រ
៣ អដ្ឋកថា ឋានិយសូត្រ
៤ អដ្ឋកថា ខយសូត្រ
៥ អដ្ឋកថា និព្វេធសូត្រ
៦ អដ្ឋកថា ឯកធម្មសូត្រ
៧ អដ្ឋកថា ឧទាយិសូត្រ

# នីវរណវគ្គទី ៤

## អ ដ្ឋ ក ថា

## ឧបក្កិលេសសូត្រទី ៣

គប្បីជ្រាបវិនិច្ឆ័យក្នុង ឧបក្កិលេសសូត្រទី ៣ នៃ នីវរណវគ្គទី ៤

[៤៦៧] បទថា មិនឲ្យមានពណ៌ល្អ (ន ច ឧភស្សរំ) បានដល់ មិនមានរស្មី ។ បទថា ឲ្យស្រួយ (បភង្គុ ច) បានដល់ មានការបែកធ្លាយជាសភាព ។

[៤៦៨] បទថា ដែក (អយោ) បានដល់ លោហៈមានពណ៌ខ្មៅ ។ អធិប្បាយថា វត្ថុរបស់ ៤ យ៉ាង ដែលពោលទុកក្នុងព្រះសូត្រនេះ ដ៏សេសឈ្មោះថា លោហៈ ។

[៤៧២] បទថា សជ្ឈុំ បានដល់ ប្រាក់ ។

[៤៧៤] បទថា ចិត្តស្ស បានដល់ កុសលចិត្តដែលប្រព្រឹត្តក្នុងភូមិ ៤ ។

សួរថា ឧបក្កិលេសរមែងមានដល់ចិត្តក្នុងភូមិ ៣ ចូរលើកទុកសិន

ឧបក្កិលេសរបស់លោកុត្តរចិត្ត មានបានយ៉ាងណា ។

ឆ្លើយថា ធម៌ពួកណា រមែងមិនឲ្យអារម្មណ៍ដ៏ប្រសើរកើតឡើង ធម៌ពួកនោះឯង ឈ្មោះថា ជាឧបក្កិលេស របស់លោកិយចិត្តខ្លះ របស់លោកុត្តរចិត្តខ្លះ រមែងមាន ។ បទថា **ឲ្យវិនាសទៅ (បភង្គុ ច)** សេចក្តីថា មានការបែកធ្លាយជាសភាវៈ ដោយចូលដល់ភាពជាចុណវិចុណៈទៅក្នុងអារម្មណ៍ ។

[៤៧៨] បទថា **មិនជាគ្រឿងរាំង (អនាវរណា)** បានដល់ ឈ្មោះថា **អនាវរណា** ព្រោះអត្ថថា មិនរាំងកុសលធម៌ ។ បទថា **មិនមែនជានីវរណៈ (អនីវរណា)** បានដល់ ឈ្មោះថា **អនីវរណា** ព្រោះអត្ថថា មិនបិទបាំង ។ បទថា **មិនមែនជាឧបក្កិលេសនៃចិត្ត (ចេតសោ អនុបក្កិលេសា)** បានដល់ មិនមែនជាឧបក្កិលេសរបស់ចិត្តក្នុងភូមិ ៤ ។

ចប់អដ្ឋកថា ឧបក្កិលេសសូត្រទី ៣

# អ ដ្ឋ ក ថា

## អាវរណានីវរណសូត្រទី ៧

គប្បីជ្រាបវិនិច្ឆ័យក្នុង អាវរណានីវរណសូត្រទី ៧ ។

[៤៩០] បទថា ធ្វើបញ្ញាឲ្យថោកទាប (បញ្ញាយ ទុព្វលីករណា) បាន ដល់ ធ្វើឲ្យអន់ថយបញ្ញា ។ ព្រោះថា កាលមាននីវរណធម៌ទាំងឡាយកើត ឡើងរឿយៗ បញ្ញា កាលកើតឡើងក្នុងចន្លោះៗ ជាបញ្ញាថោកទាប ទន់ខ្សោយ មិនល្អៀស ។

ចប់អដ្ឋកថា អាវរណានីវរណសូត្រទី ៧

# អ ដ្ឋ ក ថា

## និវរណាវរណសូត្រទី ៨

*គប្បីជ្រាបវិនិច្ឆ័យក្នុង និវរណាវរណសូត្រទី ៨ ។*

[៤៩២] *បទថា* ***សម័យនោះ និវរណៈ ៥ រមែងមិនមានដល់អ្នកពោជ្ឈង្គៈ ៧ រមែងដល់សេចក្តីចម្រើនបរិបូណ៌*** *(បញ្ចស្ស នីវរណា តស្មឹ សមយេ ន ហោន្តិ សត្ត ពោជ្ឈង្គា តស្មឹ សមយេ ភាវនាបារិបូរឹ គច្ឆន្តិ) សេចក្តីថា និវរណៈ ៥ យ៉ាង របស់ព្រះអរិយសាវកអ្នកស្តាប់នូវធម៌ជាទីសប្បាយ រមែងមានក្នុងទីឆ្ងាយ បើព្រះអរិយសាវកនោះ អាចញុំាងគុណ-វិសេសឲ្យកើតក្នុងទីនោះបាន ពោជ្ឈង្គៈ ៧ របស់ព្រះអរិយសាវកនោះ រមែងដល់ការចម្រើនបរិបូណ៌យ៉ាងនេះ ។ បើមិនអាច អំពីនោះលោកទៅកាន់ទីសម្រាកពេលយប់ និងពេលថ្ងៃ កាលមិនលះបង់បីតិនោះចេញ គ្របសង្កត់និវរណៈ ៥ បានហើយ និងញុំាងគុណវិសេសឲ្យកើតបាន ។ សេចក្តីនោះលោកពោលសំដៅដល់ប្រការនេះថា សូម្បីពេលមិនអំណាចនៅក្នុងទីនោះបាន កាលមិនទាន់លះបង់បីតិនោះ រហូតដល់ក្នុង ៧ ថ្ងៃ គ្រប់សង្កត់និវរណៈបាន និងញុំាងគុណវិសេសឲ្យកើតបាន ដូច្នេះ ។ ការពិត ពោជ្ឈង្គៈដែល*

លោកបានហើយ ដែលជាចំណែកបីតិ និងបាមោជ្ជៈក្នុងមួយគ្រា ព្រោះការស្តាប់ធម៌ រមែងសូន្យទៅ ព្រោះអាស្រ័យភាពជាអ្នកត្រេកអរក្នុងការងារជាដើម ។ តែកាលបានឧតុសប្បាយជាដើមបែបនោះ ក៏កើតឡើងទៀត រមែងដល់សេចក្តីចម្រើនបរិបូណ៌ក្នុងសម័យនោះ គេពោលទុកយ៉ាងនេះ ដោយប្រការដូច្នេះឯង ។

ចប់អដ្ឋកថា នីវរណាវរណាសូត្រទី ៨

# អ ដ្ឋ ក ថា

## រុក្ខសូត្រទី ៩

*គប្បីជ្រាបវិនិច្ឆ័យក្នុង រុក្ខសូត្រទី ៩ ។*

*[៤៩៦] បទថា អជ្ឈារុហា ប្រែថា ដុះឡើង ។*

*[៤៩៧] បទថា កច្ឆកោ ប្រែថា ដើមជ្រៃ ។ បទថា កបិត្ថនោ បានដល់ ដើមល្វៀប កើតឡើងហើយមានផ្លែដូចជាដោះស្វា ។*

ចប់អដ្ឋកថា រុក្ខសូត្រទី៩

# អ ដ្ឋ ក ថា

## នីវរណសូត្រទី ១០

*គប្បីជ្រាបវិនិច្ឆ័យក្នុង នីវរណសូត្រទី ១០*

*[៥០១] បទថា **អន្ធករណា** ប្រែថា ធ្វើឲ្យខ្វាក់ ។ បទថា **ធ្វើមិនឲ្យមានចក្ខុ** (អចក្ខុករណា) បានដល់ ធ្វើមិនឲ្យមានបញ្ញាចក្ខុ ។ បទថា **ជាហេតុឲ្យរលត់នៃបញ្ញា** (បញ្ញានិរោធិយា) បានដល់ រលត់បញ្ញា ។ បទថា **ប្រព្រឹត្តទៅក្នុងបក្ខពួកនៃសេចក្ដីចង្អៀតចង្អល់** (វិឃាតបក្ខិយា) ប្រែថា ជាចំណែកទុក្ខ ។ បទថា **មិនប្រព្រឹត្តទៅដើម្បីនិព្វាន** (អនិព្វានសំវត្តនិកា) បានដល់ មិនប្រព្រឹត្តដើម្បីព្រះនិព្វាន ។ ពាក្យដ៏សេសក្នុងបទទាំងពួង មានសេចក្ដីងាយទាំងនោះឯង ។ ក្នុងវគ្គទាំងអស់នេះ លោកពោលពោជ្ឈង្គៈលាយគ្នាដោយប្រការដូច្នេះ ។*

ចប់អដ្ឋកថា នីវរណសូត្រទី ១០

### ចប់នីវរណវគ្គវណ្ណនាទី ៤

### រួមអដ្ឋកថាក្នុងវគ្គនេះ គឺ

១ អដ្ឋកថា ឧបកិលេសសូត្រ ២ អដ្ឋកថា អាវរណានីវរណាសូត្រ

៣ អដ្ឋកថា នីវរណាវរណាសូត្រ ៤ អដ្ឋកថា រុក្ខសូត្រ

៥ អដ្ឋកថា នីវរណាសូត្រ

# ចក្កវត្តិវគ្គទី ៥

## អ ដ្ឋ ក ថា

## វិធាសូត្រទី ១

*គប្បីជ្រាបវិនិច្ឆ័យក្នុង វិធាសូត្រទី ១ នៃ ចក្កវត្តិវគ្គទី ៥*

[៥០៣] *បទថា មានះ ៣ យ៉ាង (តិស្សោ វិធា) បានដល់ ពួកនៃមានះ ៣ យ៉ាង ។ ម្យ៉ាងទៀត មានះតែម្យ៉ាង ។ ក៏ព្រោះលោកចាត់ទុកយ៉ាងនោះៗ ទើបពោលមានះថា វិធា ។*

ចប់អដ្ឋកថា វិធាសូត្រទី ១

# អ ដ្ឋ ក ថា

## ចក្កវត្តិសូត្រទី ២

*គប្បីជ្រាបវិនិច្ឆ័យក្នុង ចក្កវត្តិសូត្រទី ២ ៖*

[៥០៥] ក្នុងបទថា *ព្រះបាទចក្រពត្តិ (រញ្ញោ ភិក្ខវេ ចក្កវត្តិស្ស)* នេះ ឈ្មោះថា ព្រះរាជា ព្រោះអត្ថថា ទ្រង់ត្រេកអរក្នុងសិរិសម្បត្តិរបស់ព្រះអង្គ ឬទ្រង់ឲ្យពលរដ្ឋត្រេកអរដោយសង្គហវត្ថុ ៤ នៃព្រះរាជានោះ ។ ឈ្មោះថា ព្រះបាទចក្រពត្តិ ព្រោះអត្ថថា បង្គាប់ការដោយវាចាវាងវៃ ញ៉ាំងចក្កឲ្យប្រព្រឹត្តទៅដោយបុញ្ញានុភាពថា សូមចក្ករតនចូរត្រាច់ទៅដ៏រាបទីបំផុតភព នៃព្រះបាទចក្រពត្តិនោះ ដូច្នេះ ។ បទថា **បាតុភាវា** ប្រែថា ព្រោះប្រាកដ ។ បទថា **ប្រាំពីរ (សត្តន្នំ)** ប្រែថា កំណត់ដោយការរាប់ ។ បទថា **កែវ (រតនានំ)** បានដល់ សម្តែងរឿងដែលកំណត់ ។ ចំណែកន័យរបស់បទក្នុងបទនេះ (មានដូច្នេះ) ឈ្មោះថា **រតនៈ** ព្រោះអត្ថថា ឲ្យកើតសេចក្តីរីករាយ ។

មួយ៉ាងទៀតថា ៖

ដែលហៅថា រតនៈ ព្រោះធ្វើការគោរព មាន

តម្លៃច្រើន ថ្លឹងមិនបាន ឃើញបានលំបាក ជា

របស់ប្រើប្រាស់របស់សត្វ អ្នកមិនថោកថយ

ដូច្នេះ ។

ចាប់ផ្តើមពីរតនៈកើត ឈ្មោះថា ទេវស្ថានដទៃ រមែងមិនមាន ។ មនុស្សទាំងពួងធ្វើការបូជា និងអភិវាទជាដើម ដល់រតនៈនោះតែម្យ៉ាង ដោយរបស់ក្រអូប និងផ្កាឈើជាដើម ដូច្នោះ ទើបឈ្មោះថា **រតនៈ** ព្រោះអត្ថថា ធ្វើសេចក្តីគោរព ។ ចំណែកចក្ករតន៍នឹងប្រមាណតម្លៃជាទ្រព្យ មានតម្លៃប្រមាណប៉ុណ្ណេះមិនបាន ដូច្នោះ ទើបឈ្មោះថា **រតនៈ** ព្រោះអត្ថថា មានតម្លៃច្រើន ។ ចក្ករតន៍ មិនដូចរតនៈដែលមាននៅក្នុងលោកយ៉ាងដទៃ ដូច្នោះ ទើបឈ្មោះថា **រតនៈ** ព្រោះអត្ថថា ថ្លឹងមិនបាន ។ ក៏ព្រោះក្នុងកប្បដែលព្រះពុទ្ធជាម្ចាស់ទាំងឡាយមិនឧប្បត្តិ ស្តេចចក្រពត្តិ និងព្រះបច្ចេកពុទ្ធជាម្ចាស់ រមែងកើតក្នុងកាលខ្លះប៉ុណ្ណោះ ដូច្នោះ ទើបឈ្មោះថា **រតនៈ** ព្រោះអត្ថថា ឃើញបានលំបាក ។ រតនៈនេះ រមែងកើតឡើងដល់សត្វដែលរុងរឿង មិនថោកទាប ដោយជាតិ រូប ត្រកូល និងភាពជាធំជាដើម មិនកើតឡើងដល់សត្វដទៃ ដូច្នោះ ទើបឈ្មោះថា **រតនៈ** ព្រោះអត្ថថា ជាគ្រឿងប្រើប្រាសរបស់សត្វដែលមិនថោកថយ ។ រតនៈសូម្បីដ៏សេស ក៏ដូចចក្ក-រតន៍ដូច្នោះ ដោយប្រការដូច្នេះ ព្រោះហេតុនោះ លោកទើបពោលថា ៖

ដែលហៅថា រតនៈ ព្រោះធ្វើសេចក្ដីគោរព មាន
តម្លៃច្រើន ថ្លឹងមិនបាន ឃើញបានលំបាក ជា
របស់ប្រើប្រាស់នៃសត្វមិនថោកថយ ដូច្នេះ ។

បទថា ប្រាកដឡើង (បាតុភាវោ ហោតិ) បានដល់ ការបង្កើត ។ ក្នុងប្រការនេះ មានវាចាប្រកបសេចក្ដីដូច្នេះ សេចក្ដីថា ស្ដេចចក្រពត្តិប្រាកដ រតនៈ ៧ ទើបប្រាកដ ដូច្នេះក៏គួរ ។ សេចក្ដីថា ឈ្មោះថា ស្ដេចចក្រពត្តិនោះ រមែងញ៉ាំងចក្កដែលកើតហើយឲ្យវិលទៅ ដូច្នេះក៏គួរ ។

សួរថា ព្រោះហេតុ អ្វី ?

ឆ្លើយថា ព្រោះបំណងចំពោះដល់ស្ដេចចក្រពត្តិ ។ ក៏បុគ្គលណានឹងញ៉ាំងចក្កឲ្យវិលទៅតាមការនិយម បុគ្គលនោះ តាំងពីបដិសន្ធិរមែងដល់ភាពជាអ្នកគួរពោលថា ស្ដេចចក្រព័ត្តិប្រាកដ ដូច្នេះ ។ ពាក្យនោះ ក៏គួរដូចគ្នា ព្រោះពោលដល់ការកើតនៃបុរសដែលបានឈ្មោះយ៉ាងនោះ (ជាមូល) ក៏បុគ្គលណាជាសត្វវិសេស បានឈ្មោះថា ស្ដេចចក្រពត្តិ ការប្រាកដ ពោលគឺ បដិសន្ធិរបស់បុគ្គលនោះមានហើយ នេះជាអធិប្បាយក្នុងសេចក្ដី ។ ក៏ព្រោះស្ដេចចក្រពត្តិប្រាកដ រតនៈទាំងឡាយរមែងប្រាកដ ។ ស្ដេចចក្រពត្តិនោះ រមែងប្រកបដោយបុញ្ញសម្ភារ ដល់ភាពពេញលេញ ព្រមជាមួយរតនៈ

ទាំងនោះដែលប្រាកដហើយ ។ ក្នុងកាលនោះ មនុស្សលោកកើតការគិតប្រាកដក្នុងរតនៈទាំងនោះ ។ សេចក្តីនោះក៏គួរ ព្រោះនិយាយដល់គ្នាច្រើនក៏កាលណា សញ្ញាមានការប្រាកដក្នុងរតនៈទាំងនោះ កើតឡើងដល់មនុស្ស-លោក កាលនោះ ចក្ករតន៍តែម្យ៉ាងប៉ុណ្ណោះប្រាកដមុន ខាងក្រោយប្រាកដរតនៈក្រៅពីនេះ ៦ យ៉ាងទៀត ព្រោះដូច្នោះ ទើបដល់រតនៈដ៏សេសនោះយ៉ាងនេះ ព្រោះពោលដល់គ្នាច្រើន បើនឹងពោលដល់សេចក្តីផ្សេងនៃការប្រាកដ ប្រការនោះក៏គួរហើយ ការប្រាកដ មិនមែនប្រាកដត្រឹមតែមួយយ៉ាងឈ្មោះថា បាតុភាវៈ ព្រោះញ៉ាំងការប្រាកដឲ្យកើតឡើង នេះជាផ្សេងគ្នានៃការប្រាកដ ព្រោះការសន្សំបុណ្យឯណា ញ៉ាំងស្តេចចក្រពត្តិឲ្យប្រាកដដោយអំណាចបដិសន្ធិ ឈ្មោះថា បាតុភាវៈ នេះជាសេចក្តីផ្សេងគ្នានៃខ្លឹមសាររបស់ការប្រាកដ ។ ព្រោះការសន្សំបុណ្យឯណា ញ៉ាំងស្តេចចក្រពត្តិឲ្យប្រាកដដោយអំណាចបដិសន្ធិ ដូច្នោះ ការប្រាកដនៃស្តេចចក្រពត្តិ មិនមែនស្តេចចក្រពត្តិតែម្យ៉ាង សូម្បីរតនៈ ៧ ទាំងនេះ ក៏ប្រាកដផង ព្រោះដូច្នោះនេះជាអធិប្បាយក្នុងសេចក្តីនេះ ។ ដូចជា ការសន្សំបុណ្យនោះ ជាហេតុឲ្យកើតព្រះរាជា យ៉ាងណា ការសន្សំបុណ្យជាហេតុឧបនិស្ស័យសូម្បីនៃរតនៈដោយបរិយាយក៏ដូច្នោះ ព្រោះដូច្នោះ ប្រការនោះក៏គួរនោះឯង ព្រះ-

មានព្រះភាគជាម្ចាស់ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រោះការប្រាកដនៃស្តេចចក្រពត្តិ ទើបជាការប្រាកដនៃរតនៈ ៧ ផង ដូច្នេះ ។

ឥឡូវនេះ ព្រះមានព្រះភាគជាម្ចាស់ទើបត្រាស់ពាក្យជាដើមថា **រតនៈ ៧ យ៉ាងដូចម្តេច គឺ ចក្ករតន៍ (កតមេសំ សត្តន្នំ ចក្ករតនស្ស)** ដូច្នេះ ដើម្បីទ្រង់សម្តែងរតនៈទាំងនោះ ដោយអំណាចសរុប ។ ក្នុងបទទាំងនោះ ក្នុងបទជាដើមថា **ចក្ករតនស្ស** មានអធិប្បាយដោយសង្ខេបដូច្នេះ ចក្កកែវអាចទាញយកសិរិសម្បត្តិរបស់ទ្វីបធំ ៤ មានទ្វីបតូចពីរពាន់ជាបរិវារ ឲ្យបានប្រាកដ ។ **ដំរីកែវ** ទៅកាន់វេហាស៍ ដែលអាចជាប់តាមទៅកាន់ផែនដីមានសាគរជាទីបំផុត មកបានមុនកត្តយ៉ាងនោះ **សេះកែវ** ក៏ដូច្នោះដូចគ្នា ។ **កែវមណី** ដែលអាចកម្ចាត់កាពងងឹតប្រមាណមួយយោជន៍ក្នុងទីងងឹត សូម្បីប្រកបដោយអង្គ ៤ ហើយមើលឃើញច្បាស់បាន ។ **ស្ត្រីកែវ** មានប្រក្រតីវៀរចាកទោស ៦ យ៉ាងហើយ ប្រព្រឹត្តក្នុងវត្ថុដែលគួរពេញចិត្ត ។ **គហបតិកែវ** ដែលអាចឃើញរណ្តៅទ្រព្យ (កប់) នៅក្នុងផែនដី ក្នុងប្រទេសប្រមាណមួយយោជន៍ ។ **បរិនាយកែវ** ពោលគឺ បុត្តច្បងគេបង្អស់ ដែលកើតក្នុងផ្ទៃរបស់អគ្គមហេសី ជាអ្នកអាចគ្រប់គ្រងសម្បត្តិទាំងអស់ បានប្រាកដហើយដូច្នេះ នេះជាអធិប្បាយសង្ខេបក្នុងសេចក្តីនេះ ។ ចំណែកវិធីប្រាកដនៃ

ចក្កកែវជាដើមទាំងនោះ មកហើយក្នុងសូត្រ មានមហាសុទស្សនៈជាដើម ដោយពិស្តារ សូម្បីអធិប្បាយវិធីប្រាកដរបស់ចក្កកែវនោះ លោកពណ៌នាទុកក្នុងអដ្ឋកថានៃសូត្រទាំងនោះឯង ។

[៤០៦] ក្នុងបទថា *រតនៈ គឺ សតិសម្ពោជ្ឈង្គៈ (សតិសម្ពោជ្ឈង្គរតនស្ស)* ជាដើម គប្បីជ្រាបសេចក្តីដែលមានលក្ខណៈស្រដៀងគ្នាយ៉ាងនេះ ។ ចក្ករតន៍របស់ស្តេចចក្រពត្តិ ត្រាច់ទៅមុនរតនៈទាំងពួង យ៉ាងណា សតិសម្ពោជ្ឈង្គរតន៍ ត្រាច់ទៅមុនធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ទាំងពួង ដូច្នោះ គឺ ប្រៀបដោយចក្ករតន៍របស់ស្តេចចក្រពត្តិ ព្រោះអត្ថថា ត្រាច់ទៅមុន ។ បណ្តារតនៈទាំងឡាយ ដំរីកែវរបស់ស្តេចចក្រពត្តិ មានរាងធំខ្ពស់ ទូលាយ ធម្មវិចយសម្ពោជ្ឈង្គរតន៍ ចូលដល់ពួកធម៌ដ៏ច្រើន ជារបស់ល្អិត ទូលាយ ធំ ដូច្នោះ ទើបប្រៀបដោយដំរីកែវ ។ សេះកែវរបស់ស្តេចចក្រពត្តិ មានដំហានជើងលឿន វីរិយសម្ពោជ្ឈង្គរតនៈសូម្បីនេះ មានកម្លាំងលឿនរហ័ស ដូច្នោះ ទើបប្រៀបដោយសេះកែវ ព្រោះហេតុមានកម្លាំងរហ័សនេះ ។ កែវមណីរបស់ស្តេចចក្រពត្តិ កម្ចាត់កាពងងឹតឲ្យភ្លឺច្បាស់បាន បីតិសម្ពោជ្ឈង្គរតនៈសូម្បីនេះ នៅក្នុងពួកធម៌ដ៏ច្រើន រមែងកម្ចាត់កាពងងឹត គឺ កិលេសឲ្យភ្លឺច្បាស់ដោយញាណ ដោយអំណាចសហជាត-

ប្បច្ច័យជាដើម ព្រោះជាកុសលតែម្យ៉ាង ដូច្នោះ ទើបប្រៀបដោយកែវមណី ព្រោះហេតុកម្ចាត់ភាពងងឹតឲ្យភ្លឺច្បាស់ ។

ស្ត្រីកែវរបស់ស្តេចចក្រពត្តិ រម្ងាប់សេចក្តីខ្វល់ខ្វាយផ្លូវកាយ និងផ្លូវចិត្ត ឲ្យការក្តៅស្ងប់ បស្សទ្ធិសម្ពោជ្ឈង្គរតនៈសូម្បីនេះ ក៏រម្ងាប់ការខ្វល់ខ្វាយផ្លូវកាយ និងផ្លូវចិត្ត ឲ្យការក្តៅស្ងប់ ដូច្នោះ ទើបប្រៀបដោយស្ត្រី-កែវ ។ គហបតីកែវរបស់ស្តេចចក្រព័ត្តិ កំណាត់សេចក្តីរាយមាយ ធ្វើឲ្យចិត្តមានអារម្មណ៍តែមួយ ដោយការឲ្យទ្រព្យ ក្នុងខណៈដែលខ្លួនប្រាថ្នាហើយ សមាធិសម្ពោជ្ឈង្គរតនៈសូម្បីនេះ ញុំាងអប្បនាឲ្យដល់ព្រម ដោយអំណាចដែលខ្លួនប្រាថ្នាជាដើម កាត់ផ្តាច់ហើយនូវសេចក្តីរាយមាយ ធ្វើចិត្តឲ្យមានអារម្មណ៍តែមួយ ដូច្នោះ ទើបប្រៀបដោយគហបតិកែវ ។ ចំណែកបរិនាយក-កែវរបស់ស្តេចចក្រពត្តិ ធ្វើសេចក្តីខ្វាយខ្វល់តិចឲ្យ ដោយការធ្វើកិច្ចក្នុងទីទាំងពួងឲ្យសម្រេច ឧបេក្ខាសម្ពោជ្ឈង្គរតនៈសូម្បីនេះ រដោះចិត្តឲ្យរួចចាកពីការធុញទ្រាន់ និងសេចក្តីរាយមាយ ធ្វើសេចក្តីខ្វាយខ្វល់តិច តម្កល់ខ្លួនទុកក្នុងកណ្តាល ប្រកបសេចក្តីព្យាយាម ដូច្នោះ ទើបប្រៀបដោយបរិ-នាយកកែវ ។ គប្បីជ្រាបថា ការកំណត់ធម៌ដែលរួមទុកទាំងអស់ ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ បានពោលទុកក្នុងសូត្រនេះ ដោយប្រការដូច្នេះ ។

ចប់អដ្ឋកថា ចក្កវត្តិសូត្រទី ២

# អ ដ្ឋ ក ថា

## ឧប្បញ្ញសូត្រទី ៤

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឧប្បញ្ញសូត្រទី ៤ ។*

*[៥០៨] បទថា មនុស្សគ (ឯឡមូគោ) សេចក្តីថា មនុស្សកាលមិនអាចនឹងបន្ទឹវាចាតាមមាត់បាន ជាមនុស្សគនិយាយមិនបាន ព្រោះទោសទាំងឡាយ ។ ពាក្យដ៏សេសក្នុងបទទាំងពួង ងាយទាំងនោះឯង ។*

ចប់អដ្ឋកថា ឧប្បញ្ញសូត្រទី ៤

## ចប់ចក្កវត្តិវគ្គវណ្ណនាទី ៥

## រួមអដ្ឋកថាក្នុងវគ្គនេះ គឺ

១ អដ្ឋកថា វិធាសូត្រ ២ អដ្ឋកថា ចក្កវត្តិសូត្រ

៣ អដ្ឋកថា ឧប្បញ្ញសូត្រ

---

*-សូត្រទី ៥ ដល់សូត្រទី ១០ មិនមានអដ្ឋកថាកែ ។*

# ពួក ៦ នៃពោជ្ឈង្គទី ៦

## អ ដ្ឋ ក ថា

## អាហារសូត្រទី ១

*គប្បីជ្រាបវិនិច្ឆ័យក្នុង អាហារសូត្រទី ១ ៖*

[៥២៨] *ក្នុងបទថា នេះជាអាហារឲ្យសតិសម្ពោជ្ឈង្គៈដែលមិនទាន់កើត កើតឡើង (អយមាហារោ អនុប្បន្នស្ស វា សតិសម្ពោជ្ឈង្គស្ស ឧប្បាទាយ) ជាដើម នេះជាសេចក្ដីផ្សេងគ្នាអំពីន័យមុន ៗ ធម៌មានប្រការដែលពោលហើយទាំងនោះ រមែងជាបច្ច័យដើម្បីការកើតឡើងនៃសតិពោជ្ឈង្គៈជាដើម ដើម្បីសេចក្ដីចម្រើនបរិបូរនៃពោជ្ឈង្គៈទាំងឡាយ ដែលកើតហើយតែម្យ៉ាងប៉ុណ្ណោះក៏មិនមែន ចំណែកធម៌សូម្បីដទៃ គប្បីជ្រាបយ៉ាងនេះឯង ៗ*

*ពិតណាស់ ធម៌ដទៃ ៤ ប្រការទៀត រមែងប្រព្រឹត្តដើម្បីការកើតឡើងនៃសតិសម្ពោជ្ឈង្គៈ គឺ សតិសម្បជញ្ញៈ ១ , ការវៀរបុគ្គលមិនមានសតិ ១ , ការគប់រកបុគ្គលមានសតិតាំងមាំ ១ , ការបង្អោនចិត្តទៅក្នុងធម៌នោះ ១ ៗ*

ក៏សតិសម្ពោជ្ឈង្គៈ រមែងកើតឡើងក្នុងឋានៈ ៧ មានការឈានទៅជាដើមដោយសតិសម្បជញ្ញៈ ដោយការវៀរចាកបុគ្គលមិនមានសតិ ដូចជាក្អែកលះបង់នុយ ដោយគប់រកអ្នកមានសតិតាំងមាំ ដូចព្រះតិស្សទត្តត្ថេរ និងព្រះអភ័យត្ថេរជាដើម និងដោយមានចិត្តបង្អោនទៅ ទោទន់ទៅ ទេរទៅ ដើម្បីឲ្យកើតសតិឡើងក្នុងឥរិយាបថ មានការឈរ និងការអង្គុយជាដើម ចំណែកសតិសម្ពោជ្ឈង្គៈនោះ ដែលកើតឡើងដោយហេតុ ៤ ប្រការយ៉ាងនេះហើយ រមែងចម្រើនបរិបូរដោយអរហត្តមគ្គ ។

ធម៌ ៧ ប្រការ រមែងប្រព្រឹត្តដើម្បីការកើតឡើងនៃធម្មវិចយសម្ពោជ្ឈង្គៈ គឺ ភាពជាអ្នកសាកសួរ ១ , ការធ្វើឲ្យលះបង់វត្ថុល្អស្អាត ១ , ការធ្វើឥន្ទ្រីយ៍ឲ្យស្មើគ្នា ១ , ការវៀរចាកបុគ្គលមិនមានបញ្ញា ១ , ការគប់រកបុគ្គលមានបញ្ញា ១ , ការពិចារណាបាឋៈដែលត្រូវប្រើបញ្ញាដ៏ជ្រាលជ្រៅ ១ , ការបង្អោនចិត្តទៅក្នុងធម្មវិចយៈនោះ ១ ។

បណ្ដាបទទាំងនោះ បទថា **ការសាកសួរ (បរិបុច្ឆកតា)** បានដល់ភាពជាអ្នកច្រើនដោយការសួរ ដែលអាស្រ័យរបស់អត្ថនៃខន្ធ ធាតុ អាយតនៈ ឥន្ទ្រីយ៍ ពលៈ ពោជ្ឈង្គៈ អដ្ឋមគ្គ ឈាន សមថៈ និងវិបស្សនា ។ បទថា **ការធ្វើវត្ថុឲ្យស្អាត (វត្ថុវិសទកិរិយា)** បានដល់ ការធ្វើវត្ថុទាំងឡាយខាងក្នុង

និងខាងក្រៅឲ្យស្អាត ។ ក៏កាលណា សក់ ក្រចក រោមរបស់ព្រះយោគា-វចរនោះវែង ឬថា រាងកាយមានទោសច្រើន និងប្រឡាក់ដោយញើសក្អែល កាលនោះ ឈ្មោះថា វត្ថុខាងក្នុងមិនស្អាត គឺ មិនបរិសុទ្ធ ។ ក៏កាលណា ចីវរគ្រាំគ្រា មានក្លិនអាក្រក់ ឬថា សេនាសនៈរាត់រាយ កាលនោះ ឈ្មោះថា វត្ថុខាងក្រៅមិនស្អាត ។ ព្រោះដូច្នោះ គួរធ្វើវត្ថុខាងក្នុងឲ្យស្អាត ដោយការកាត់សក់ជាដើម ធ្វើឲ្យរាងកាយស្រាលដោយថ្នាំបញ្ចុះទាំងខាងលើ និងខាងក្រោម និងដោយការជូតសម្អាត និងងូតទឹក ។ គួរធ្វើវត្ថុខាងក្រៅឲ្យស្អាត ដោយធ្វើសូចិកម្ម ការបោសសម្អាត និងរបស់ប្រើប្រាស់ជាដើម ។ សូម្បីញាណក្នុងចិត្ត និងចេតសិកដែលកើតឡើងក្នុងវត្ថុខាងក្នុង និងខាងក្រៅនោះដែលមិនស្អាត ក៏មិនបរិសុទ្ធទៅផង ដូចពន្លឺរបស់អណ្តាតប្រទីបដែលអាស្រ័យគោម ប្រេះ និងប្រេង មិនស្អាតកើតឡើង ក៏មិនស្អាតផងដែរ ដូច្នោះ ។ ព្រោះហេតុនោះ លោកទើបពោលថា ការធ្វើវត្ថុឲ្យស្អាត រមែងប្រព្រឹត្តទៅដើម្បីការកើតឡើងនៃធម្មវិចយសម្ពោជ្ឈង្គៈ ដូច្នេះ ។

ការធ្វើឥន្ទ្រិយទាំងឡាយ មានសទ្ធាជាដើមឲ្យស្មើគ្នា ឈ្មោះថា ការធ្វើឥន្ទ្រិយឲ្យស្មើគ្នា ។ ព្រោះថា ប្រសិនបើសទ្ធិន្ទ្រីយ៍របស់គេចាស់ក្លាឥន្ទ្រិយក្រៅពីនេះទន់ខ្សោយ ។ កាលនោះ វិរិយិន្ទ្រិយ នឹងមិនអាចធ្វើបគ្គហកិច្ច

(កិច្ច គឺ ការលើកចិត្តទុក) សតិន្ទ្រិយ នឹងមិនអាចធ្វើឧបដ្ឋានកិច្ច (កិច្ច គឺ ការឧបការៈចិត្ត) សមាធិន្ទ្រិយ នឹងមិនអាចធ្វើអវិក្ខេបកិច្ច (កិច្ច គឺ ធ្វើចិត្តមិនឲ្យរាយមាយ) បញ្ញិន្ទ្រិយ នឹងមិនអាចធ្វើទស្សនកិច្ច (កិច្ច គឺ ការឃើញតាមសេចក្តីពិត) ។ ព្រោះដូច្នោះ សទ្ធិន្ទ្រិយដែលចាស់ក្លានោះ ត្រូវធ្វើឲ្យថយចុះ ដោយពិចារណាសភាវៈនៃធម៌ ដោយមិនធ្វើទុកក្នុងចិត្ត ដូចកាលគេមនសិការសទ្ធិន្ទ្រិយដែលមានកម្លាំងនោះ ។ ក៏ក្នុងសេចក្តីនេះ មានរឿងព្រះវក្កលិត្ថេរជាតួយ៉ាង ។ តែបើវីរិយិន្ទ្រិយចាស់ក្លា ពេលនោះ សទ្ធិន្ទ្រិយក៏នឹងមិនអាចធ្វើអធិមោក្ខកិច្ចបាន (កិច្ច គឺ ការបង្អោនចិត្តជឿ) ។ ឥន្ទ្រិយក្រៅពីនេះ ក៏នឹងមិនអាចធ្វើកិច្ចក្រៅនេះ ។ ព្រោះដូច្នោះ វីរិយិន្ទ្រិយដែលចាស់ក្លានោះ ត្រូវធ្វើឲ្យថយចុះដោយចម្រើនបស្សទ្ធិសម្ពោជ្ឈង្គៈជាដើម ។ សូម្បីក្នុងសេចក្តីនោះ ក៏គប្បីសម្តែងរឿងព្រះសោណត្ថេរ ។ សភាពដែលចាស់ក្លានៃឥន្ទ្រិយណាមួយមានហើយ ឥន្ទ្រិយក្រៅពីនេះ នឹងមិនអាចក្នុងកិច្ចរបស់ខ្លួនបាន គប្បីជ្រាបក្នុងឥន្ទ្រិយដ៏សេសយ៉ាងនេះឯង ។

ក៏ដោយចំពោះក្នុងឥន្ទ្រិយ ៥ នេះ បណ្ឌិតទាំងឡាយសរសើរហើយនូវការស្មើគ្នានៃសទ្ធាជាមួយបញ្ញា និងសមាធិជាមួយវីរិយៈ ។ ព្រោះបុគ្គលមានសទ្ធាចាស់ក្លា តែបញ្ញាទន់ខ្សោយ និងជាអ្នកជឿងាយ ជ្រះថ្លាក្នុងវត្ថុ

ដែលមិនជាវត្ថុ ។ ចំណែកអ្នកមានបញ្ញាចាស់ក្លា តែសទ្ធាទន់ខ្សោយ និង ធ្លាក់ទៅក្នុងការអួតអាង និងជាបុគ្គលកែខៃមិនបាន ដូចរោគដែលកើតអំពីថ្នាំ រក្សាមិនបានដូច្នោះ ស្មុះទៅដោយគិតថា ចិត្តជាកុសលទាំងនោះក៏ល្មម ដូច្នេះហើយ មិនធ្វើបុណ្យ មានទានជាដើម រមែងកើតក្នុងនរក ។ រហូតធម៌ទាំង ២ ស្មើគ្នា បុគ្គលទើបនឹងជ្រះថ្លាក្នុងវត្ថុពិត ។ កោសជ្ជៈ (សេចក្តីខ្ជិលច្រអូស) រមែងគ្របសង្កត់អ្នកមានសមាធិចាស់ក្លា តែវីរិយៈទន់ខ្សោយ ព្រោះសមាធិជាចំណែកជិតកោសជ្ជៈ ។ ឧទ្ធច្ចៈរមែងគ្របសង្កត់បុគ្គលមានវីរិយៈចាស់ក្លា តែសមាធិទន់ខ្សោយ ព្រោះវីរិយៈជាចំណែកជិតឧទ្ធច្ចៈ ។ តែសមាធិដែលមានវីរិយៈប្រកបចូលជាមួយគ្នាហើយ នឹងមិនធ្លាក់ទៅក្នុងកោសជ្ជៈ ។ វីរិយៈទីមាន សមាធិប្រកបព្រមគ្នាហើយ នឹងមិនធ្លាក់ទៅក្នុងឧទ្ធច្ចៈ ។ ព្រោះដូច្នោះ ឥន្ទ្រិយទាំង ២ នោះ ត្រូវធ្វើឲ្យស្មើគ្នា ។ ព្រោះថា អប្បនានឹងមានបាន ក៏ព្រោះការស្មើគ្នានៃឥន្ទ្រិយទាំង ២ ។

ម្យ៉ាងទៀត សទ្ធាសូម្បីមានកម្លាំង ក៏គួរសម្រាប់សមាធិកម្មិកៈ (អ្នកបំពេញសមថៈកម្មដ្ឋាន) ។ លោកកាលសទ្ធាមានកម្លាំងយ៉ាងនេះ សេចក្តីជឿក៏នឹងសម្រេចអប្បនាបាន ។ ក្នុងសមាធិ និងបញ្ញាណា ឯកគ្គតា (សមាធិ) មានកម្លាំងក៏គួរ សម្រាប់សមាធិកម្មិកៈ ព្រោះកាលឯកគ្គតាមានកម្លាំងយ៉ាង

នោះ លោកនឹងសម្រេចអប្បនាបាន ។ បញ្ញាមានកម្លាំង រមែងគួរសម្រាប់វិបស្សនាកម្មិកៈ (អ្នកបំពេញវិបស្សនាកម្មដ្ឋាន) ។ ព្រោះកាលបញ្ញាមានកម្លាំងយ៉ាងនោះ លោករមែងសម្រេចលក្ខណបដិវេធ (ការឃើញច្បាស់ត្រៃលក្ខណ៍) បាន ។ តែសមាធិ និងបញ្ញាទាំង ២ ស្មើគ្នា អប្បនាក៏គង់មានបាន ។

ចំណែកសតិ មានកម្លាំងក្នុងទីទាំងពួង ទើបគួរ ព្រោះសតិរក្សាចិត្តទុកមិនឲ្យធ្លាក់ទៅក្នុងឧទ្ធច្ចៈ ព្រោះអំណាចនៃសទ្ធា វីរិយៈ និងបញ្ញាដែលជាចំណែកជិតឧទ្ធច្ចៈ និងរក្សាចិត្តទុកមិនឲ្យធ្លាក់ទៅក្នុងកោសជ្ជៈ ព្រោះសមាធិជាចំណែកជិតកោសជ្ជៈ. ព្រោះដូច្នោះ សតិនោះ ទើបគួរប្រាថ្នាក្នុងទីទាំងពួង ដូចអំបិលជាវត្ថុដែលគប្បីប្រាថ្នាជាមួយបាយទាំងពួង និងដូចសព្វកម្មិកអាមាត្យ (អ្នកចេះដឹងក្នុងការងារទាំងពួង) ជាអ្នកគប្បីប្រាថ្នាក្នុងសព្វរាជកិច្ច ដូច្នោះ ។ ព្រោះដូច្នោះ លោកទើបពោលថា ក៏សតិ ព្រះ-មានព្រះភាគជាម្ចាស់ត្រាស់ថា ជាគុណជាតិគួរប្រាថ្នាក្នុងទីទាំងពួង ។

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះចិត្តមានសតិជាទីពឹងអាស្រ័យ និងសតិមានការរក្សាទុកជាគ្រឿងប្រាកដ ការលើក និងសង្កត់ចិត្ត វៀរសតិមិនបាន ដូច្នេះ ។

ការគេច ការវៀរចាកឆ្ងាយពីបុគ្គលមិនមានបញ្ញា បុគ្គលមិនឈាន ចុះក្នុងប្រភេទនៃធម៌ មានខន្ធជាដើម ឈ្មោះថា ការគេចចេញពីបុគ្គលមិន មានបញ្ញា ។ ការគប់រកបុគ្គលប្រកបដោយបញ្ញា ឃើញការកើត និងការ រលត់ កំណត់បាន ៥០ លក្ខណៈ សេចក្តីថា ការគប់រកបុគ្គលមានបញ្ញា ។ ការពិចារណាប្រភេទបាឋៈ ដោយបញ្ញាដ៏ជ្រាលជ្រៅ ប្រព្រឹត្តទៅក្នុងខន្ធ ជាដើម ដែលល្អិត ឈ្មោះថា ការពិចារណាបាឋៈដែលត្រូវប្រើបញ្ញាដ៏ជ្រាល ជ្រៅ ។ សភាពនៃចិត្តអន្ទោនទៅ ទោរទៅ ឱនទៅ ក្នុងឥរិយាបថ មានការ ឈរ និងការអង្គុយជាដើម ដើម្បីឲ្យកើតធម្មវិចយសម្ពោជ្ឈង្គៈឡើង ឈ្មោះ ថា ការអន្ទោនចិត្តទៅក្នុងធម្មវិចយៈនោះ ។ ក៏ធម្មវិចយសម្ពោជ្ឈង្គៈនោះ ដែលកើតឡើងយ៉ាងនេះហើយ រមែងចម្រើនបរិបូរបាន ដោយអរហត្តមគ្គ ។

ធម៌ ១១ ប្រការ ប្រព្រឹត្តទៅដើម្បីការកើតឡើងនៃវីរិយសម្ពោ- ជ្ឈង្គៈ គឺ ការពិចារណាឃើញភ័យក្នុងអបាយ ១ , ភាពជាអ្នកមានប្រក្រតី ឃើញអានិសង្ស ១ , ការពិចារណាឃើញផ្លូវដំណើរទៅ ១ , ការគោរព ក្នុងការត្រាច់បិណ្ឌបាត្រ ១ , ការពិចារណាឃើញភាពជាធំនៃមត៌ក ១ , ការពិចារណាឃើញភាពជាធំនៃព្រះសាស្តា ១ , ការពិចារណាឃើញភាព ជាធំនៃជាតិ ១ , ការពិចារណាឃើញភាពជាធំនៃសព្រហ្មចារី ១ , ការវៀរ

ចាកបុគ្គលខ្ជិលច្រអូស ១ , ការគប់រកបុគ្គលប្រារព្ធសេចក្ដីព្យាយាម ១ និងការបង្អោនចិត្តទៅក្នុងវិរិយៈនោះ ១ ។

ក្នុងបទទាំងនោះ កាលបុគ្គលពិចារណាឃើញនូវភ័យ ក្នុងអបាយយ៉ាងនេះថា នរណាៗ ក៏មិនអាចឲ្យវីរិយសម្ពោជ្ឈង្គៈកើតឡើងបាន ក្នុងវេលាសោយទុក្ខយ៉ាងខ្លាំង ផ្ដើមពីទទួលដោយគ្រឿងចង ៥ យ៉ាង ក្នុងនរកក្ដី ក្នុងវេលាត្រូវចាប់ដោយការសំណាញ់ និងទ្រូដាក់ត្រីជាដើម ក្នុងកំណើតតិរច្ឆានក្ដី ក្នុងវេលាដែលគេចាក់ដោយគ្រឿងប្រហារ មានជន្ទញដេញទៅជាដើម នាំរទេះទៅជាដើមក្ដី ក្នុងវេលាក្ដៅដោយការស្រេកឃ្លានក្នុងបេត្ត-វិស័យ អស់វេលាច្រើនពាន់ឆ្នាំ មួយពុទ្ធន្តរក្ដី ក្នុងវេលាសោយទុក្ខកើតពីខ្យល់ និងកំដៅថ្ងៃជាដើម ព្រោះអត្តភាពដែលមានត្រឹមតែស្បែកដណ្ដប់ឆ្អឹងប៉ុណ្ណោះ (ខ្ពស់) ប្រមាណ ៦០ ហត្ថ និង ៨០ ហត្ថ ក្នុងកាឡកញ្ចិកអសុរក្ដី ម្នាលភិក្ខុទាំងឡាយ នេះឯងជាវេលារបស់អ្នក ដូច្នេះ វីរិយសម្ពោជ្ឈង្គៈក៏រមែងកើតឡើង ។

កាលមានប្រក្រតីឃើញអានិសង្សយ៉ាងនេះថា បុគ្គលខ្ជិលច្រអូសមិនអាចនឹងបានលោកុត្តរធម៌ ៩ បុគ្គលប្រារព្ធសេចក្ដីព្យាយាមប៉ុណ្ណោះ ទើបបាន ។ នេះជាអានិសង្សនៃសេចក្ដីព្យាយាម ដូច្នេះ វីរិយសម្ពោជ្ឈង្គៈ ក៏

រមែងកើតឡើង ។ កាលពិចារណាឃើញដំណើរផ្លូវយ៉ាងនេះថា យើងគួរដើរតាមផ្លូវដែលព្រះពុទ្ធជាម្ចាស់ ព្រះបច្ចេកពុទ្ធ និងមហាសាវកទាំងពួងដើរទៅហើយ និងផ្លូវនោះ បុគ្គលខ្ជិលច្រអូសមិនអាចធ្វើដំណើរទៅបាន ដូច្នេះ វីរិយសម្ពោជ្ឈង្គៈក៏រមែងកើតឡើង ។

កាលពិចារណាឃើញការគោរពក្នុងបិណ្ឌបាត្រយ៉ាងនេះថា បុគ្គលដែលឧបដ្ឋាកអ្នកដោយបិណ្ឌបាត្រជាដើមទាំងនេះ មិនមែនញាតិ ទាស-កម្មកររបស់យើង ពួកគេទាំងនោះថ្វាយបិណ្ឌបាត្រជាដើមដ៏ប្រណីត ដោយគិតថា ពួកយើងអាស្រ័យលោកចិញ្ចឹមជីវិតក៏មិនមែន ដោយពិត គេសង្ឃឹមថា សក្ការៈរបស់ខ្លួននឹងមានផលច្រើន ទើបបានថ្វាយ ។ សូម្បីព្រះសាស្តាទ្រង់ពិចារណាឃើញយ៉ាងនេះថា ភិក្ខុនេះបរិភោគបច្ច័យទាំងនេះហើយ មានរាងកាយមាំមួន នៅយ៉ាងសប្បាយ ដូច្នេះ ទើបទ្រង់អនុញ្ញាតបច្ច័យដល់អ្នកការពិត ទ្រង់បានអនុញ្ញាតបច្ច័យទាំងនោះ ដោយព្រះតម្រិះថា ភិក្ខុនេះកាលបរិភោគបច្ច័យទាំងនេះ នឹងបំពេញសមណធម៌ ហើយរួចចាកវដ្តទុក្ខឥឡូវនេះ បើអ្នកខ្ជិលច្រអូស មិនគោរពក្នុងដុំបាយនោះ តែលោកជាអ្នកប្រារព្ធសេចក្តីព្យាយាមប៉ុណ្ណោះ ឈ្មោះថា គោរពក្នុងបិណ្ឌបាត្រ ដូច្នេះ វីរិយសម្ពោជ្ឈង្គៈក៏រមែងកើតឡើង ដូចកើតឡើងដល់ព្រះមហាមិត្តត្ថេរអ្នក

ពិចារណានូវសេចក្តីគោរពក្នុងបិណ្ឌបាត្រ ។

បានឮថា ព្រះថេរៈអាស្រ័យនៅប្រចាំក្នុងល្អាងកសកៈ មហាឧបា-សិកាម្នាក់នៅក្នុងគោចរគាមរបស់ព្រះថេរៈនោះឯង ធ្វើព្រះថេរៈឲ្យជាបុត្តទំនុកបម្រុងហើយ ។ ថ្ងៃមួយ កាលនាងចូលព្រៃ ទើបពោលនឹងធីតាថា នាង អង្ករនៅទីនោះ ទឹកដោះនៅទីនោះ ទឹកដោះថ្លានៅទីនោះ ទឹកអំពៅនៅទីនោះ កូនដាំបាយហើយថ្វាយព្រមជាមួយទឹកដោះ ទឹកដោះថ្លា ទឹកអំពៅក្នុងវេលាលោកម្ចាស់បងប្រុសរបស់កូនមក និងកូនបរិភោគខ្លួនឯងចុះ ចំណែកម៉ែ បរិភោគបាយកកនឹងទឹកជ្រក់បានហើយ ដូច្នេះ ។

កូនស្រីសួរថា ម៉ែ ពេលថ្ងៃម៉ែពិសាអ្វី ?

ម្តាយប្រាប់ថា កូនចូរយកអង្ករខ្ទួច (កញ្ចុំអង្ករ) ដាំជាបបរ ដាក់ជ្រក់ ហើយរៀបទុកចុះ ។

ព្រះថេរៈដណ្តប់ចីវរហើយ នាំបាត្រចេញទៅ ឮបានពាក្យនោះ ទើបពោលទូន្មានខ្លួនថា បានឮថា មហាឧបាសិកាបរិភោគបាយកកនឹងទឹកជ្រក់សូម្បីពេលថ្ងៃ ក៏បរិភោគបបរជាមួយទឹកជ្រក់ទៀត ។ តែប្រាប់ (ឲ្យដាំបាយ) ដោយអង្ករស្រូវចាស់ជាដើម ដើម្បីប្រយោជន៍ដល់អាត្មាអញ ឯនាងអាស្រ័យកម្មនោះ មិនបានប្រាថ្នាស្រែ វត្ថុ ភត្ត តែនាងប្រាថ្នាសម្បត្តិ ៣ ទើបថ្វាយ

អាត្មាអញនឹងឲ្យសម្បត្តិទាំងនោះដល់នាងបានឬទេ លោកគិតថា អត្មាអញនៅមានរាគៈ ទោសៈ និងមោហៈ មិនអាចទទួលបិណ្ឌបាត្រនេះបាន ដូច្នេះ ទើបយកបាត្រប្រកបូលថង់បិទទុក ត្រឡប់ទៅកាន់ល្អាងកសកៈវិញ ដាក់បាត្រទុកក្រោមគ្រែ ពាក់ចីវរទុកលើស្នួរចីវរ អង្គុយតម្កល់ចិត្ត ធ្វើសេចក្តីព្យាយាមថា អាត្មាអញមិនទាន់សម្រេចព្រះអរហត្តផលដរាបណា នឹងមិនចេញទៅ ដូច្នេះ ។ ភិក្ខុនៅដោយសេចក្តីមិនប្រមាទអស់កាលយូរ ចម្រើនវិបស្សនា សម្រេចអរហត្តមុនភត្ត ជាព្រះមហាខីណាស្រព ធ្វើការញញឹមដូចផ្កាបទុមដែលកំពុងរីក ។ ទេវតាដែលស្ថិតនៅហ្នឹងដើមឈើជិតទ្វារគុហា បន្លឺឧទានថា ៖

បពិត្របុរសអាជានេយ្យ ការនមស្ការ ចូរមានដល់លោក

បពិត្របុរសដ៏ប្រសើរ ការថ្វាយបង្គំចូរមានដល់លោក

បពិត្រលោកនិរទុក្ខ លោកជាទក្ខិណេយ្យបុគ្គល អ្នក

មានអាសវៈអស់ហើយ ដូច្នេះ ។

ទើបប្រាប់ថា បពិត្រលោកម្ចាស់ដ៏ចម្រើន ស្ត្រីចាស់ថ្វាយភិក្ខាដល់ព្រះអរហន្តដូចជាលោក ដែលចូលទៅបិណ្ឌបាតហើយ នឹងផុតចាកទុក្ខ ។ ព្រះថេរៈក្រោកឡើង បើកទ្វារមើលវេលា ជ្រាបថា នៅព្រឹកនៅឡើយទើប

កាន់យកបាត្រ និងចីវរចូលទៅកាន់ស្រុក ។ ចំណែកនាងទាសិកាត្រៀមភត្ត ស្រេចហើយ អង្គុយចាំមើលផ្លូវត្រង់ទ្វារថា លោកបងរបស់យើងនឹងមក ឥឡូវនេះ ម្ចាស់បងរបស់យើងនឹងមកឥឡូវនេះ ។ កាលព្រះថេរៈមកដល់ ទ្វារផ្ទះ នាងក៏ទទួលបាត្រទៅដាក់ពេញដោយបិណ្ឌបាត្រ ទឹកដោះ ផ្សំដោយ ទឹកដោះថ្លា និងទឹកអំពៅដាក់ទុកក្នុងដៃ ។ ព្រះថេរៈធ្វើការអនុមោទនាថា ចូរមានសេចក្តីសុខចុះ ដូច្នេះ ហើយចៀសចេញទៅ ។ សូម្បីនាងក៏ឈរ សម្លឹងមើលព្រះថេរៈក្មេងខ្លួន ។ ព្រោះថា ពណ៌សម្បុររបស់ព្រះថេរៈក្នុង ថ្ងៃនោះផូរផង់ក្រៃលែងណាស់ ឥន្ទ្រីយ៍ក៏ស្រស់ថ្លា ទឹកមុខស្រស់បស់ដូច ផ្លែត្នោតទុំដែលជ្រុះចាកទង ដូច្នោះ ។

មហាឧបាសិកាត្រឡប់អំពីព្រៃ សួរថា កូន លោកបងរបស់កូនមក ហើយឬ ។ នាងបានប្រាប់ការប្រព្រឹត្តនោះទាំងអស់ ។ ឧបាសិកាជ្រាបថា កិច្ចបព្វជិតនៃបុត្តយើងដល់ទីបំផុតហើយក្នុងថ្ងៃនេះ ទើបពោលថា កូនអើយ បងប្រុសរបស់ឯង រមែងត្រេកអរក្នុងព្រះពុទ្ធសាសនា នឹងមិនស្រើបស្រាល ក្នុងកាមទេ ដូច្នេះ ។

កាលពិចារណាឃើញភាពជាធំនៃមត្តិកថា អរិយទ្រព្យ ៧ នេះ ជាមត្តិក ដ៏ក្រៃលែងរបស់ព្រះសាស្តា បុគ្គលខ្ជិលច្រអូស មិនអាចទទួលមត្តិកនោះ

បាន ។ ប្រៀបដូចមាតាបិតា រមែងមិនរាប់រងបុត្រដែលបដិបត្តិខុសថា អ្នកនេះ មិនមែនបុត្ររបស់យើង ដោយការកន្ទ្រងទៅនៃមាតាបិតាទាំងនោះ គេក៏មិនបានមត៌ក យ៉ាងណា សូម្បីបុគ្គលខ្ជិលច្រអូស រមែងមិនបានមត៌ក គឺ អរិយទ្រព្យនេះ ដូច្នោះ បុគ្គលប្រារព្ធនូវសេចក្ដីព្យាយាមប៉ុណ្ណោះ រមែងបាន ដូច្នេះ វិរិយសម្ពោជ្ឈង្គៈក៏រមែងកើតឡើង ។ សូម្បីកាលពិចារណាឃើញភាពជាធំរបស់ព្រះសាស្ដាយ៉ាងនេះថា ក៏ព្រះសាស្ដារបស់យើងទ្រង់ជាធំ គឺ ក្នុងកាលដែលព្រះសាស្ដាទ្រង់ចុះចាប់បដិសន្ធិក្នុងព្រះគភ៌ព្រះមាតាក្ដី ក្នុងកាលស្ដេចទ្រង់ព្រះផ្នួសក្ដី ក្នុងការត្រាស់ដឹងក្ដី ក្នុងកាលទ្រង់ញ៉ាំងធម្មចក្កឲ្យប្រព្រឹត្តទៅ ទ្រង់សម្ដែងយមកប្បាដិហារ្យ ស្ដេចយាងចុះចាកទេវលោក និងក្នុងការដាក់ព្រះជន្មាយុសង្ខារក្ដី ក្នុងកាលបរិនិព្វានក្ដី មុឺនលោកធាតុក៏កម្រើកញាប់ញ័រហើយ បុគ្គលដែលបួសក្នុងសាសនារបស់ព្រះសាស្ដាបែបនេះហើយ ជាអ្នកខ្ជិលច្រអូស សមគួរឬ ដូច្នេះ វិរិយសម្ពោជ្ឈង្គៈ ក៏រមែងកើតឡើង ។

សូម្បីកាលពិចារណាឃើញភាពជាធំនៃជាតិយ៉ាងនេះថា ឥឡូវនេះ សូម្បីជាតិ អ្នកក៏មិនមែនមានជាតិទន់ទាប គឺ អ្នកកើតក្នុងវង្សនៃព្រះបាទឱក្កាករាជ បន្តពីព្រះបាទមហាសម្មតៈ មិនលាយឡំគ្នា ជាញាតិរបស់ព្រះបាទ

សុទ្ធោទនមហារាជ និងព្រះនាងមហាមាយាទេវី ជាប្អូនព្រះរាហុលដ៏ចម្រើន អ្នកបានឈ្មោះថា ជាជនបុគ្គលបែបនេះ ខ្ជិលច្រអូស មិនសមគួរឡើយ ។ វិរិយសម្ពោជ្ឈង្គៈ ក៏រមែងកើតឡើង សូម្បីកាលពិចារណាឃើញភាពជាធំនៃមិត្តសព្រហ្មចារី យ៉ាងនេះថា ព្រះសារីបុត្រ ព្រះមោគ្គល្លាន និងមហាសាវ័ក ៨០ អង្គ ចាក់ធ្លុះលោកុត្តរធម៌បានដោយសេចក្ដីព្យាយាមប៉ុណ្ណោះ ចំណែកអ្នកធ្វើដំណើរ ឬមិនធ្វើដំណើរទៅតាមផ្លូវរបស់សព្រហ្មចារីទាំងនោះ ដូច្នេះ វិរិយសម្ពោជ្ឈង្គៈក៏រមែងកើតឡើង ។

សូម្បីកាលវៀរចាកបុគ្គលខ្ជិលច្រអូស លះបង់សេចក្ដីព្យាយាមផ្លូវកាយ និងផ្លូវចិត្តចេញ ដូចពស់វែកស៊ីឆ្អែតហើយក៏ឈប់ស្ងៀម សូម្បីគប់រកបុគ្គលប្រារព្ធសេចក្ដីព្យាយាម មានចិត្តមុតមាំ សូម្បីមានចិត្តបង្អោនទៅ ទោរទៅ ទេរទៅ ដើម្បីការកើតឡើងនៃសេចក្ដីព្យាយាមក្នុងឥរិយាបថ មានការឈរ និងការអង្គុយជាដើម វិរិយសម្ពោជ្ឈង្គៈរមែងកើតឡើង តែវិរិយសម្ពោជ្ឈង្គៈនោះ ដែលកើតឡើងហើយយ៉ាងនេះ រមែងចម្រើនបរិបូរបានដោយអរហត្តមគ្គ ។

ធម៌ ១១ ប្រការ រមែងប្រព្រឹត្តដើម្បីការកើតឡើងនៃបីតិសម្ពោជ្ឈង្គៈ គឺ ការរឭកដល់ព្រះពុទ្ធគុណ ១ ការរឭដល់ព្រះធម្មគុណ ១ ការរឭកដល់

ព្រះសង្ឃគុណ ១ រឭកដល់សីល ១ រឭកដល់ការបរិច្ចាគ ១ រឭកដល់ទេវតា ១ រឭកដល់គុណព្រះនិព្វាន ១ គេចចេញពីបុគ្គលសៅហ្មង ១ គប់រកបុគ្គលផូរផង់ ១ ការពិចារណាសេចក្ដីនៃព្រះសូត្រដែលនាំឲ្យជ្រះថ្លា ១ ការបង្អោនចិត្តទៅក្នុងបីតិនោះ ១ ។

កាលរឭកដល់ព្រះពុទ្ធគុណក្ដី បីតិសម្ពោជ្ឈង្គៈរមែងកើតឡើង ផ្សាយទូទៅសរីរៈរហូតដល់ឧបចារៈ កាលរឭកព្រះធម៌គុណ ព្រះសង្ឃគុណក្ដី បព្វជិតអ្នកពិចារណាឃើញចតុបារិសុទ្ធិសីល ដែលខ្លួនរក្សាហើយមិនដាច់រហូតអស់កាលយូរក្ដី គ្រហស្ថពិចារណាសីលក្ដី អ្នកថ្វាយភោជនដ៏ប្រណីតក្នុងគ្រាកើតទុព្ភិក្ខភ័យជាដើមដល់សព្រហ្មចារីហើយ ពិចារណាឃើញចាគៈថា យើងបានថ្វាយភោជនឈ្មោះយ៉ាងនេះហើយក្ដី សូម្បីគ្រហស្ថពិចារណាឃើញទានដែលខ្លួនថ្វាយដល់អ្នកមានសីលទាំងឡាយ ក្នុងកាលឃើញបែបនេះក្ដី បុគ្គលប្រកបដោយគុណណា ដល់ភាពជាទេវតា កាលពិចារណាឃើញគុណបែបនោះមាននៅក្នុងខ្លួនក្ដី កាលពិចារណាឃើញថា កិលេសដែលគ្របសង្កត់បានដោយសមាបត្តិ មិនកើតឡើងអស់វេលា ៦០ ឆ្នាំ ៧០ ឆ្នាំ ដូច្នេះក្ដី កាលគេចចេញពីបុគ្គលសៅហ្មង ដូចធូលីលើខ្នងលា ដោយមិនមានសេចក្ដីជ្រះថ្លា និងពេញចិត្តក្នុងព្រះពុទ្ធជាម្ចាស់ជាដើម ជាសេចក្ដី

សៅហ្មងដែលសន្សំទុកហើយ ក្នុងការធ្វើសេចក្តីមិនគោរព ក្នុងការឃើញលានព្រះចេតិយ លានពោធិព្រឹក្ស និងព្រះថេរៈក្តី ។ បុគ្គលសេពគប់អ្នកបរិសុទ្ធ មានចិត្តទន់ភ្លន់ ច្រើនដោយសេចក្តីជ្រះថ្លាក្នុងព្រះពុទ្ធជាម្ចាស់ជាដើមក្តី ពិចារណាឃើញព្រះសូត្រដែលទូន្មានឲ្យជ្រះថ្លា ដែលសម្តែងគុណនៃព្រះរតនត្រៃក្តី មានចិត្តបង្អោនទៅ ទោរទន់ទៅ ទេរទៅ ដើម្បីការកើតឡើងនៃបីតិ ក្នុងឥរិយាបថទាំងឡាយ មានការឈរ និងការអង្គុយជាដើមក្តី បីតិសម្ពោជ្ឈង្គៈរមែងកើតឡើង តែបីតិសម្ពោជ្ឈង្គៈនោះ កើតឡើងហើយយ៉ាងនោះ រមែងចម្រើនបរិបូណ៌បានដោយអរហត្តមគ្គ ។

ធម៌ ៧ ប្រការ រមែងប្រព្រឹត្តដើម្បីការកើតឡើងនៃបស្សទ្ធិសម្ពោ-ជ្ឈង្គៈ គឺ សេពភោជនដ៏ប្រណីត ១ សេពរដូវដែលជាសុខ ១ សេពឥរិយាបថដែលជាសុខ ១ ប្រកបសេចក្តីព្យាយាមជាកណ្តាល ១ ចៀសវាងបុគ្គលអ្នកមានកាយរសាប់រសល់ ១ គប់រកបុគ្គលអ្នកមានកាយស្ងប់ ១ បង្អោនចិត្តទៅក្នុងបស្សទ្ធិនោះ ១ ។

កាលបរិភោគភោជនដែលជាទីសប្បាយ ប្រណីត ល្អិតក្តី សេពរដូវជាទីសប្បាយ និងឥរិយាបថដែលសប្បាយ ក្នុងបណ្តារដូវត្រជាក់ និងរដូវក្តៅ និងក្នុងឥរិយាបថ មានការឈរជាដើមក្តី បស្សទ្ធិរមែងកើតឡើង ។

ចំណែកភិក្ខុណាមានជាតិជាមហាបុរស រមែងអត់ធន់ក្នុងឥរិយាបថតាមរដូវទាំងពួង ប្រការនោះលោកមិនបានពោលសំដៅពាក្យនោះទេ កាលវៀររដូវ និងឥរិយាបថដែលមានចំណែកមិនស្មើគ្នានៃរដូវ និងឥរិយាបថ ដែលមានចំណែកស្មើ និងមិនស្មើគ្នាហើយ សេពរដូវ និងឥរិយាបថដែលមានចំណែកស្មើគ្នា បស្សទ្ធិក៏រមែងកើតឡើង ។ ការពិចារណាឃើញ ភាពនៃខ្លួន និងអ្នកដទៃមានកម្មជារបស់ខ្លួន ហៅថា ប្រកបសេចក្តីព្យាយាមជាកណ្តាល ។ ដោយការប្រកបសេចក្តីព្យាយាមជាកណ្តាលនេះ បស្សទ្ធិក៏រមែងកើតឡើង បុគ្គលណាត្រាច់ទៅបៀតបៀនអ្នកដទៃ ដោយដុំដី និងដំបងជាដើម កាលគេចចេញបុគ្គលអ្នកមានកាយសោប់សល់បែបនោះក្តី គប់រកបុគ្គលអ្នកមានកាយស្ងប់ អ្នកសង្រួមដៃក្តី អ្នកមានចិត្តបង្អោនទៅ ទោរទៅ ទេរទៅ ដើម្បីការកើតឡើងនៃបស្សទ្ធិក្នុងឥរិយាបថទាំងឡាយ មានការឈរ និងការអង្គុយជាដើមក្តី បស្សទ្ធិក៏រមែងកើតឡើង តែបស្សទ្ធិសម្ពោជ្ឈង្គៈកើតឡើងហើយយ៉ាងនេះ រមែងបរិបូណ៌បានដោយអរហត្តមគ្គ ដោយប្រការដូច្នេះ ។

ធម៌ ១០ ប្រការ រមែងប្រព្រឹត្តដើម្បីការកើតនៃសមាធិសម្ពោជ្ឈង្គៈ គឺ ការធ្វើវត្ថុឲ្យស្អាត ១ ការធ្វើឥន្រ្ទិយ៍ឲ្យស្មើគ្នា ១ ភាពជាអ្នកឈ្លាសវៃក្នុងនិមិត្ត ១ ការលើកចិត្តឡើងក្នុងសម័យ (ដែលគួរលើក) ១ ការសង្កត់

ចិត្តក្នុងសម័យ (ដែលគួរសង្កត់) ១ ការធ្វើចិត្តឲ្យរីករាយក្នុងសម័យ (ដែលគួរធ្វើឲ្យរីករាយ) ១ ការសម្លឹងមើលចិត្តព្រងើយៗ ក្នុងសម័យ (ដែលគួរសម្លឹងមើល) ១ ការចៀសវាងបុគ្គលអ្នកមានចិត្តមិនជាសមាធិ ១ គប់រកបុគ្គលអ្នកមានចិត្តជាសមាធិ ១ បង្អោនចិត្តទៅក្នុងសមាធិនោះ ១ ។

បណ្តាបទទាំងនោះ ការធ្វើវត្ថុឲ្យស្អាត និងការធ្វើឥន្ទ្រិយ៍ឲ្យស្មើគ្នា គប្បីជ្រាបដោយន័យដូចពោលហើយ ។ ភាពឈ្លាសវៃក្នុងការកាន់យកកសិណនិមិត្ត ឈ្មោះថា ភាពឈ្លាសវៃក្នុងនិមិត្ត ។ បទថា **ការលើកចិត្តក្នុងសម័យ (សមយេ ចិត្តស្ស បគ្គណ្ហណតា)** សេចក្តីថា ក្នុងសម័យណាមានចិត្តរាយមាយ ព្រោះហេតុប្រារព្ធសេចក្តីព្យាយាមខ្លាំងពេកជាដើម ក្នុងសម័យនោះ លើកចិត្តនោះ ដោយការញ៉ាំងធម្មវិចយៈ វិរិយៈ និងបីតិសម្ពោជ្ឈង្គៈតាំងឡើង ។ បទថា **ការសង្កត់ចិត្តក្នុងសម័យ (សមយេ ចិត្តស្ស និគ្គណ្ហណតា)** សេចក្តីថា ក្នុងសម័យណា មានចិត្តរាយមាយ ព្រោះហេតុប្រារព្ធសេចក្តីព្យាយាមខ្លាំងពេកជាដើម ក្នុងសម័យនោះ សង្កត់ចិត្តនោះ ដោយការញ៉ាំងបស្សទ្ធិ សមាធិ និងឧបេក្ខាសម្ពោជ្ឈង្គៈតាំងឡើង ។

បទថា **ការធ្វើចិត្តឲ្យរីករាយក្នុងសម័យ (សមយេ សម្បហំសមតា)** សេចក្តីថា ក្នុងសម័យណា ចិត្តមិនរីករាយ ព្រោះសេចក្តីព្យាយាម បញ្ញាទន់

ខ្វាយក្តី ព្រោះមិនបានសុខដែលកើតពីសេចក្តីស្ងប់ក្តី ក្នុងសម័យនោះ ព្រះយោគាវចរគប្បីពិចារណាសង្វេគវត្ថុ (ទីតាំងនៃសេចក្តីសង្វេគ) ៨ យ៉ាង ។ វត្ថុទាំងឡាយ គឺ ជាតិ ជរា ព្យាធិ និងមរណៈ ជា ៤ អបាយទុក្ខជាទី ៥ ទុក្ខមានវដ្តៈជាមូលក្នុងអតីត ទុក្ខដែលមានវដ្តៈជាមូលក្នុងអនាគត ទុក្ខមានការស្វែងរកអាហារជាមូលក្នុងបច្ចុប្បន្ន ឈ្មោះថា សង្វេគវត្ថុ ៨ ។ អ្នកគប្បីញុាំងសេចក្តីជ្រះថ្លាឲ្យកើត ដោយការរឭកដល់គុណរបស់ព្រះរតនត្រៃនេះហៅថា ការធ្វើចិត្តឲ្យរីករាយក្នុងសម័យ ។ ឈ្មោះថា ការសម្លឹងមើលចិត្តព្រងើយៗ ក្នុងសម័យ បានដល់ ក្នុងសម័យណា ចិត្តអាស្រ័យការបដិបត្តិត្រូវ ជាចិត្តមិនរួញរា មិនរាយមាយ មិនមានភាពរីករាយប្រព្រឹត្តទៅស្មើក្នុងអារម្មណ៍ ដំណើរទៅតាមវិថីនៃសមថៈ ក្នុងសម័យនោះ អ្នកមិនត្រូវខ្វល់ខ្វាយក្នុងការលើកចិត្ត ការសង្កត់ចិត្ត និងការចិត្តឲ្យរីករាយ ដូចនាយសារថី កាលសេះទាំងឡាយរត់ទៅរៀបរយ ក៏មិនខ្វល់ខ្វាយ ដូច្នោះនេះហៅថា ការសម្លឹងមើលចិត្តព្រងើយៗ ក្នុងសម័យ ។ ការវៀរចាកបុគ្គលអ្នកមានចិត្តរាយមាយ ជាអ្នកមិនចូលដល់ឧបចារៈ ឬអប្បនា ឈ្មោះថា វៀរចាកបុគ្គលមិនមានចិត្តជាសមាធិ ។ ការសេព ការគប់រក ការចូលទៅអង្គុយជិតបុគ្គលមានចិត្តជាសមាធិ ដោយឧបចារៈ ឬអប្បនា ឈ្មោះថា ការ

គប់រកបុគ្គលមានចិត្តជាសមាធិ ។ ការដែលចិត្តបង្អោនទៅ ទោរទៅ ទេរទៅ ដើម្បីកើតសមាធិក្នុងឥរិយាបថទាំងឡាយ មានការឈរ និងការអង្គុយជាដើម ឈ្មោះថា ការបង្អោនចិត្តទៅក្នុងសមាធិនោះ ។ កំអ្នកកាលបដិបត្តិយ៉ាងនេះ សមាធិសម្ពោជ្ឈង្គៈនោះ រមែងកើតឡើង ។ ក៏សមាធិសម្ពោជ្ឈង្គៈនោះ កើតឡើងហើយយ៉ាងនេះ រមែងចម្រើនបរិបូណ៌ដោយអរហត្តមគ្គ ។

ធម៌ ៥ ប្រការ រមែងប្រព្រឹត្តដើម្បីការកើតឡើងនៃឧបេក្ខាសម្ពោជ្ឈង្គៈ គឺ ការព្រងើយក្នុងសត្វ ១ ការព្រងើយក្នុងសង្ខារ ១ ការវៀរចាកបុគ្គលអ្នកជាប់ជំពាក់ក្នុងសត្វ និងសង្ខារ ១ ការគប់រកបុគ្គលអ្នកព្រងើយក្នុងសត្វ និងសង្ខារ ១ ការបង្អោនចិត្តទៅក្នុងឧបេក្ខានោះ ១ ។

បណ្តាបទទាំងនោះ ព្រះយោគាវចរញុំាងការព្រងើយក្នុងសត្វ ឲ្យកើតឡើងដោយអាការ ២ យ៉ាង គឺ ដោយការពិចារណាឃើញសត្វមានកម្មជារបស់ខ្លួន យ៉ាងនេះថា លោកមកតាមកម្មរបស់ខ្លួន ក៏នឹងទៅតាមកម្មរបស់ខ្លួននោះឯង លោកនឹងជាប់ជំពាក់ជាមួយនរាំ ដូច្នេះ និងដោយការពិចារណាឃើញមិនមែនសត្វយ៉ាងនេះថា ដោយបរមត្ថសត្វមិនមានឡើយ អ្នកនឹងទៅជាប់ជំពាក់ជាមួយនរណា ដូច្នេះ ។ រមែងញុំាងការព្រងើយក្នុងសង្ខារឲ្យកើតឡើង ដោយអាការ ២ យ៉ាង គឺ ដោយពិចារណាឃើញការ

មិនមានម្ចាស់របស់យ៉ាងនេះថា ចីវរនេះ ចូលដល់ការប្រែប្រួលពណ៌ និងការគ្រាំគ្រាដោយលំដាប់ ហើយក្លាយទៅជាសំពត់ជូតជើង នឹងជារបស់គួរយកចុងឈើច្រត់ថ្កឹះចោល ប្រសិនបើម្ចាស់សំពត់នោះមាន មិនគួរឲ្យសំពត់នោះវិនាសទៅយ៉ាងនេះ ។ និងដោយការពិចារណាឃើញថា ជារបស់មួយគ្រាមួយខណៈ យ៉ាងនេះថា វត្ថុនេះមិនស្ថិតស្ថេរ នៅបានមួយរយៈ ដូច្នេះ ។ សូម្បីក្នុងបាត្រជាដើម គប្បីប្រកបសេចក្តីដូចក្នុងចីវរ ដូច្នោះ ។

ក្នុងបទថា **ការវៀរបុគ្គលដែលជាប់ជំពាក់ក្នុងសត្វ និងសង្ខារ (សត្ត-សង្ខារកេលាយនបុគ្គលបរិវជ្ជនតា)** នេះ មានសេចក្តីថា បុគ្គលណាជាគ្រហស្ថ រមែងប្រកាន់បុត្រ និងធិតាជាដើមរបស់ខ្លួនថា ជារបស់យើងក្តី ។ ចំពោះបព្វជិត ប្រកាន់អន្តេវាសិក និងអ្នករួមឧបជ្ឈាយ៍ជាដើមរបស់ខ្លួនថា របស់យើង ជួយធ្វើការងារ មានការកោរសក់ ការដេរ ការបោកគក់ ការជ្រលក់ និងដុតបាត្រជាដើម របស់អន្តេវាសិកជាដើមដោយដៃរបស់ខ្លួន កាលមិនឃើញសូម្បីត្រឹមតែមួយភ្លែត រមែងសម្លឹងរកខាងនេះខាងនោះ ដូចម្រឹគដែលផ្អើល ថា សាមណេររូបនោះទៅណា ភិក្ខុកម្លោះរូបនោះទៅណាហើយ ដូច្នេះ សូម្បីត្រូវអ្នកដទៃសំណូមពរនឹងលោក ដើម្បីប្រយោជន៍នៃការកោរសក់ជាដើមថា លោកនឹងឲ្យសាមណេររូបឯណោះដល់ខ្ញុំមួយភ្លែតចុះ រមែងមិនឲ្យ

ដោយពោលថា ការផាវចំណែកខ្លួនមិនទាន់ប្រើឲ្យធ្វើផង ពួកលោកនាំគេទៅនឹងលំបាក ដូច្នេះ នេះឈ្មោះថា ការជាប់ជំពាក់ក្នុងសត្វ ។ ចំណែកភិក្ខុណាប្រកាន់បាត្រ ចីវរ បំពង់ម្ជុល ឈើច្រត់ជាដើមថា ជារបស់យើង មិនឲ្យអ្នកដទៃសូម្បីយកដៃប៉ះ សូម្បីនឹងត្រូវសូមខ្ចីមួយភ្លែត ក៏ពោលថា សូម្បីពួកយើងក៏ពេញចិត្តក្នុងទ្រព្យ ទើបមិនប្រើប្រាស់ទ្រព្យនេះ យើងនឹងឲ្យដល់លោកទាំងឡាយបានដូចម្តេច ភិក្ខុនេះឈ្មោះថា ជាប់ជំពាក់ក្នុងសង្ខារ ។ ចំណែកបុគ្គលណា ជាអ្នកព្រងើយកន្តើយសូម្បីក្នុងវត្ថុទាំង ២ នោះ បុគ្គលនេះ ឈ្មោះថា ជាអ្នកព្រងើយក្នុងសត្វ និងសង្ខារ ។ ដោយអាការយ៉ាងនេះ ឧបេក្ខាសម្ពោជ្ឈង្គៈនេះ ទើបកើតឡើងដល់បុគ្គលដែលវៀរចាកឆ្ងាយពីអ្នកជាប់ជំពាក់ក្នុងសត្វ និងសង្ខារបែបនេះខ្លះ អ្នកគប់រកបុគ្គលដែលព្រងើយក្នុងសត្វ និងសង្ខារខ្លះ អ្នកមានចិត្តបង្អោនទៅ ទោរទៅ ទេរទៅ ដើម្បីការកើតឡើងឧបេក្ខាសម្ពោជ្ឈង្គៈនោះ ក្នុងឥរិយាបថទាំងឡាយ មានការឈរ និងការអង្គុយជាដើមខ្លះ ។ តែឧបេក្ខាសម្ពោជ្ឈង្គៈនោះ កើតឡើងយ៉ាងហើយយ៉ាងនេះ រមែងចម្រើនបរិបូណ៌បានដោយអរហត្តមគ្គ ។

បទថា **អសុភនិមិត្ត** (និមិត្តថាមិនស្អាត) **(អសុភនិមិត្តំ)** បានដល់ធម៌មានអសុភៈជាអារម្មណ៍ មានឧទ្ធុមាតកអសុភកម្មដ្ឋានជាដើម ការធ្វើទុក

ក្នុងចិត្តដល់ឧបាយ ការធ្វើទុកក្នុងចិត្តដល់ផ្លូវ ការធ្វើទុកក្នុងចិត្តដល់ការកើត ឈ្មោះថា **យោនិសោមនសិការ** ក្នុងបទថា **ការធ្វើឲ្យច្រើននូវយោនិសោមនសិការ (យោនិសោមនសិការពហុលីការោ)** នេះ ។

ម្យ៉ាងទៀត ធម៌ ៦ ប្រការ រមែងប្រព្រឹត្តដើម្បីលះកាមច្ឆន្ទៈ គឺ ការរៀនយកអសុភនិមិត្ត ១ ការតាមប្រកបក្នុងអសុភភាវនា ១ ការរក្សាទ្វារក្នុងឥន្ទ្រិយទាំងឡាយ ១ ការស្គាល់ប្រមាណក្នុងភោជន ១ ការមានមិត្តល្អ ១ និយាយតែរឿងដែលជាទីសប្បាយ ១ ។ ព្រោះថា ពេលរៀនយកអសុភនិមិត្ត ១០ យ៉ាងក្តី កាលចម្រើនអសុភនិមិត្ត ១០ យ៉ាងក្តី អ្នកមានទ្វារដែលខ្លួនរក្សាហើយក្នុងឥន្ទ្រីយ៍ក្តី អ្នកស្គាល់ប្រមាណក្នុងភោជនៈ ដោយវៀរដុំបាយ ៤-៥ ដុំហើយផឹកទឹកជាប្រក្រតីក្តី ក៏រមែងលះកាមច្ឆន្ទៈបាន ។ ព្រោះហេតុនោះ លោកទើបពោលទុកថា ៖

> ភិក្ខុគួរវៀរដុំបាយ ៤-៥ ដុំចេញ ហើយផឹកទឹក ក៏ល្មម
> សម្រាប់ភិក្ខុអ្នកមានខ្លួនដែលបញ្ជូនដើម្បីនៅជាសុខ ។

កាលគប់រកកល្យាណមិត្ត ដែលជាអ្នកត្រេកអរក្នុងអសុភភាវនា ដូចជាព្រះតិស្សៈអ្នកបំពេញអសុភកម្មដ្ឋាន ក៏លះកាមច្ឆន្ទៈបាន ។ សូម្បីក្នុងការពោលពាក្យជាទីសប្បាយ ក្នុងអសុភនិមិត្ត ១០ ក្នុងឥរិយាបថ មានការ

ឈរ និងការអង្គុយជាដើម ក៏លះបានដូចគ្នា ។ ព្រោះហេតុនោះ លោកទើបពោលថា ធម៌ ៦ ប្រការ រមែងប្រព្រឹត្តដើម្បីលះកាមច្ឆន្ទៈដូច្នេះ ។ ចំណែកកាមច្ឆន្ទៈដែលលះបានដោយធម៌ ៦ ប្រការទាំងនេះ រមែងមិនកើតឡើងតទៅទៀត ដោយអរហត្តមគ្គ ។

អប្បនាក្តី ឧបចារៈក្តី ក៏គួរក្នុងបទដែលពោលថា **មេត្តា** ក្នុងបទថា **មេត្តា ចេតោវិមុត្តិ** នេះ ។ អប្បនាតែម្យ៉ាង ឈ្មោះថា **ចេតោវិមុត្តិ** ។ យោនិសោមនសិការ មានលក្ខណៈតាមដែលពោលហើយ ។ ម្យ៉ាងទៀត ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះព្យាបាទ គឺ ការកាន់យកមេត្តា-និមិត្ត ១ ការប្រកបមេត្តាភាវនា ១ ការពិចារណាដល់សត្វមានកម្មជារបស់ខ្លួន ១ ភាពជាអ្នកពិចារណាច្រើន ១ សេពគប់មិត្តល្អ ១ រឿងជាទីសប្បាយ ១ ។ ពិតណាស់ សូម្បីកាលកាន់យកមេត្តា ដោយអំណាចនៃមេត្តាដែលផ្សាយទូទាំងទិស ដោយចំពោះ និងមិនចំពោះណាមួយ លះព្យាបាទបានក្នុងកាលនោះ កាលចម្រើនមេត្តាដោយអំណាចការផ្សាយទូទាំងទិស ទាំងចំពោះទាំងមិនចំពោះក្តី ពិចារណាដល់ខ្លួន និងអ្នកដទៃមានកម្មជារបស់ខ្លួន យ៉ាងនេះថា លោកក្រោធ នឹងធ្វើអ្វីគេបាន លោកនឹងអាចធ្វើសីលជាដើមរបស់គេឲ្យវិនាសបានឬ លោកមកហើយដោយកម្មរបស់ខ្លួន នឹងទៅដោយកម្ម

របស់ខ្លួនទុំះឯង សេចក្តីក្រោធដល់អ្នកដទៃ ក៏ដូចគ្នានឹងបុគ្គលកាន់យកដុំរងើកភ្លើងដែលមិនមានអណ្តាត ឬដុំដែកក្តៅ និងលាមកជាដើម ហើយបំណងប្រហារអ្នកដទៃ ។ សូម្បីគេក្រោធ នឹងធ្វើអ្វីដល់លោកបាន គេអាចធ្វើសីលជាដើមរបស់លោកឲ្យវិនាសបានឬ គេមកដោយកម្មរបស់គេ ក៏នឹងទៅតាមកម្មរបស់គេទុំះឯង សេចក្តីក្រោធនោះនឹងធ្លាក់ចុះលើក្បាលរបស់គេទុំះឯង ដូចគ្រឿងប្រហារដែលមិនបានរក្សាដោយល្អ និងដូចនាំធូលីបាចទៅក្នុងទីច្រាស់ខ្យល់ដូច្នោះ ដូច្នេះក្តី កាលពិចារណាដល់ខ្លួន និងអ្នកដទៃមានកម្មជារបស់ខ្លួនទាំងពីរចំណែក តាំងមាំក្នុងការពិចារណាក្តី សេពគប់កល្យាណមិត្តពេញចិត្តក្នុងមេត្តាភាវនា ដូចព្រះអស្សគុត្តត្ថេរក្តី រមែងលះព្យាបាទបាន ។ សូម្បីក្នុងរឿងជាទីសប្បាយ អាស្រ័យមេត្តាក្នុងឥរិយាបថទាំងឡាយ មានការឈរ និងការអង្គុយជាដើមក៏លះបានដូចគ្នា ។ ព្រោះហេតុនោះ លោកទើបពោលថា ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះព្យាបាទ ដូច្នេះ ។ ក៏ព្យាបាទដែលលះបានដោយធម៌ ៦ ប្រការនេះ រមែងមិនកើតតទៅដោយអនាគាមិមគ្គ ។

បទជាដើមថា **ការមិនត្រេកអរមាន ម្នាលភិក្ខុទាំងឡាយ (អត្ថិ ភិក្ខវេ អរតិ)** មានសេចក្តីដែលពោលហើយនោះឯង ។ មួយវិញទៀត ធម៌ ៦ ប្រការ

រមែងប្រព្រឹត្តទៅដើម្បីលះថីនមិទ្ធៈ គឺ ការកាន់យកនិមិត្តក្នុងភោជនដែលលើស ១ ការផ្លាស់ប្តូរឥរិយាបថ ១ ការធ្វើទុកក្នុងចិត្តដល់អាលោកសញ្ញា ១ ការនៅកណ្តាលវាល ១ សេពគប់មិត្តល្អ ១ រឿងដែលជាទីសប្បាយ ១ ។

សូម្បីកាលកាន់យកនិមិត្តក្នុងភោជនៈដែលលើសយ៉ាងនេះថា ភិក្ខុកាលបរិភោគភោជន ដូចព្រាហ្មណ៍ដែលឈ្មោះ អាហារហត្ថកៈ ដែលឈ្មោះថា កុត្តវិម្ចិតកៈ ដែលឈ្មោះថា តត្រវដ្តកៈ ដែលឈ្មោះ អលង្សាសាជកៈ ដែលឈ្មោះថា កាកមាសកៈ ហើយអង្គុយក្នុងទីសម្រាកពេលយប់ និងទីសម្រាកពេលថ្ងៃ ធ្វើសមណធម៌ ថីនមិទ្ធៈរមែងមកគ្របសង្កត់ដូចដំរីធំ ។ តែថីនមិទ្ធៈនោះ នឹងមិនមានដល់ភិក្ខុដែលវៀរឱកាសនៃដុំបាយ ៤-៥ ដុំ ហើយផឹកទឹកជាប្រក្រតី រមែងលះថីនមិទ្ធៈបាន ។ ថីនមិទ្ធៈរមែងគ្របសង្កត់ក្នុងឥរិយាបថណា កាលផ្លាស់ប្តូរឥរិយាបថដទៃពីឥរិយាបថនោះក្តី ការធ្វើទុកក្នុងចិត្តដល់ពន្លឺព្រះច័ន្ទ ពន្លឺប្រទីប ពន្លឺគប់ភ្លើងក្នុងវេលាយប់ ពន្លឺព្រះអាទិត្យពេលថ្ងៃក្តី នៅក្នុងទីវាលក្តី សេពគប់កល្យាណមិត្តអ្នកលះថីនមិទ្ធៈបាន ដូចជាព្រះមហាកស្សបត្ថេរក្តី រមែងលះថីនមិទ្ធៈបាន ។ សូម្បីក្នុងរឿងដែលជាទីសប្បាយ អាស្រ័យធុតង្គក្នុងឥរិយាបថទាំងឡាយ មានការឈរ

និងការអន្តួយជាដើមក្តី រមែងលះបង់ថីនមិទ្ធៈបានដូចគ្នា ។ ព្រោះដូច្នោះ លោកទើបពោលធម៌ ៦ ប្រការនេះ រមែងប្រព្រឹត្តទៅដើម្បីលះថីនមិទ្ធៈ ដូច្នេះ ។ ក៏ថីនមិទ្ធៈដែលលះបានដោយធម៌ ៦ ប្រការនេះ រមែងមិនកើតតទៅដោយអរហត្តមគ្គ ។

បទជាដើមថា ***សេចក្តីស្ងប់នៃចិត្តមាន ម្នាលភិក្ខុទាំងឡាយ (អត្ថិ ភិក្ខវេ ចេតសោ វូបសមោ)*** មានសេចក្តីដូចដែលពោលហើយនោះឯង ។ ម្យ៉ាងទៀត ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះឧទ្ធច្ចកុក្កុច្ចៈ គឺ ភាពជាពហុស្សុត ១ ភាពជាអ្នកសាកសួរ ១ ភាពជំនាញក្នុងព្រះវិន័យ ១ ការគប់រកបុគ្គលដែលចម្រើន ១ ការមានកល្យាណមិត្ត ១ រឿងជាទីសប្បាយ ១ ។ សូម្បីកាលភិក្ខុរៀនមួយនិកាយ ឬបីនិកាយ បួននិកាយ ឬប្រាំនិកាយសូត្រ ដោយអំណាចបែព្រះបាលី និងដោយអំណាចនៃអត្ថ សូម្បីដោយភាពជាពហុស្សុតបុគ្គល រមែងលះឧទ្ធច្ចកុក្កុច្ចៈបាន ។ អ្នកច្រើនដោយការសាកសួរវត្ថុដែលគួរ និងមិនគួរក្តី អ្នកជំនាញ ព្រោះជាអ្នកជំនាញក្នុងព្រះវិន័យ-បញ្ញត្តិក្តី អ្នកចូលរកព្រះថេរៈចាស់ក្តី សេពគប់កល្យាណមិត្តអ្នកទ្រទ្រង់វិន័យ ដូចជាព្រះឧបាលិត្ថេរក្តី រមែងលះឧទ្ធច្ចកុក្កុច្ចៈបាន ។ សូម្បីក្នុងរឿងដែលជាទីសប្បាយ ដែលអាស្រ័យវត្ថុដែលគួរ និងមិនគួរ ក្នុងឥរិយាបថ

ទាំងឡាយ មានការឈរ និងការអង្គុយជាដើម រមែងលះបានដូចគ្នា ។ ព្រោះហេតុនោះ លោកទើបពោលថា ធម៌ ៦ ប្រការនេះ រមែងប្រព្រឹត្តទៅដើម្បីលះឧទ្ធច្ចកុក្កុច្ចៈ ដូច្នេះ ។ ក៏ក្នុងឧទ្ធច្ចកុក្កុច្ចៈដែលលះបានដោយធម៌ ៦ ប្រការនេះ ឧទ្ធច្ចៈរមែងមិនកើតតទៅ ដោយអរហត្តមគ្គ , កុក្កុច្ចៈមិនកើតឡើងដោយអនាគាមិមគ្គ ដោយប្រការដូច្នេះ ។

សូម្បីបទជាដើមថា **ធម៌ដែលជាកុសល និងអកុសល (កុសលាកុសលា ធម្មា)** មានសេចក្តីដូចដែលពោលហើយនោះឯង ។ម្យ៉ាងទៀត ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះវិចិកិច្ឆា គឺ ភាពជាពុស្សូត ១ ភាពជាអ្នកសាកសួរ ១ ភាពជំនាញក្នុងព្រះវិន័យ ១ ភាពជាអ្នកច្រើនដោយអធិមោក្ខៈ ១ ការមានកល្យាណមិត្ត ១ រឿងដែលជាទីសប្បាយ ១ ។

សូម្បីកាលភិក្ខុរៀនយកមួយនិកាយ ។ល។ ឬប្រាំនិកាយ ដោយអំណាចនៃព្រះបាលី និងដោយអំណាចនៃអត្ថ សូម្បីដោយភាពជាពហុស្សូត បុគ្គលរមែងលះវិចិកិច្ឆាបាន ។ ភិក្ខុប្រារព្ធព្រះរតនត្រ័យ ច្រើនដោយសាកសួរក្តី ភិក្ខុជំនាញក្នុងព្រះវិន័យក្តី ភិក្ខុច្រើនដោយការបង្អោនចិត្តទៅ ពោលគឺ សទ្ធាដែលសម្រេចក្នុងព្រះរតនត្រ័យក្តី សេពគប់កល្យាណមិត្ត ដូចជាព្រះវក្កលិអ្នកបង្អោនចិត្តទៅក្នុងសទ្ធាក្តី រមែងលះវិចិកិច្ឆាបាន ។ សូម្បីក្នុងរឿងជាទី

សប្បាយ ដែលអាស្រ័យគុណរបស់ព្រះរតនត្រ័យ ក្នុងឥរិយាបថទាំងឡាយ មានការឈរ និងការអង្គុយជាដើម រមែងលះបានដូចគ្នា ។ ព្រោះហេតុនោះ លោកទើបបានពោលថា ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះវិចិកិច្ឆា ដូច្នេះ ។ ក៏វិចិកិច្ឆាដែលលះបានដោយធម៌ ៦ ប្រការទាំងនេះ រមែងមិនកើតតទៅដោយសោតាបត្តិមគ្គ ។

ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ផ្គូរទេសនា ដោយឋានៈ ៣ ទ្រង់កាន់យកធម៌ដែលជាកំពូលដោយព្រះអរហត្ត ដោយប្រការដូច្នេះ ។ ក្នុងទីបំផុតនៃទេសនា ពួកភិក្ខុ ៥០០ រូបបានសម្រេចព្រះអរហត្ត ។

ចប់អដ្ឋកថា អាហារសូត្រទី ១

# អ ដ្ឋ ក ថា

## បរិយាយសូត្រទី ២

*គប្បីជ្រាបវិនិច្ឆ័យក្នុង **បរិយាយសូត្រទី ២** ៖*

*[៥៨៧] បទថា **ច្រើន (សម្ពហុលា)** សេចក្ដីថា ជន ៣ នាក់ លោកហៅថា ច្រើន ដោយបរិយាយក្នុងវិន័យ ។ ច្រើនជាង ៣ នាក់នោះ ហៅថា សង្ឃ ។ ៣ នាក់ ហៅថា ៣ នាក់ដូចគ្នា ដោយបរិយាយនៃព្រះសូត្រ តែ ៣ នាក់ឡើងទៅ ហៅថា ច្រើន ។ ក្នុងទីនេះ គប្បីជ្រាបថា **ច្រើន** ដោយបរិយាយនៃព្រះសូត្រ ។ បទថា **ចូលទៅបិណ្ឌបាត្រ (បិណ្ឌាយ បវិសឹសុ)** បានដល់ ចូលទៅដើម្បីបិណ្ឌបាត ។ ក៏ភិក្ខុទាំងនោះមិនទាន់បានចូលទៅ តែហៅថា ចូលទៅហើយ ព្រោះចេញទៅ ដោយគិតថា នឹងចូលទៅ ។*

*សួរថា ដូចម្ដេច?*

*ឆ្លើយថា ដូចអ្នកចេញទៅដោយគិតថា នឹងទៅស្រុក សូម្បីនៅមិនទាន់ដល់ស្រុកនោះ កាលត្រូវគេសួរថា អ្នកឈ្មោះនេះ ទៅណា ។ គេនឹងឆ្លើយថា ទៅស្រុកហើយ យ៉ាងណា ក៏ដូច្នោះ ។*

*បទថា **អារាមរបស់បរិញ្វជក (បរិញ្វជកានំ អារាមោ)** នោះ លោក*

ពោលសំដៅដល់អារាមរបស់ពួកអញ្ញតិត្ថិយបរិព្វាជក មាននៅក្នុងទីមិនឆ្ងាយព្រះជេតពន ។ បទថា **អ្នកមានអាយុ ព្រះសមណ (សមណោ អាវុសោ)** សេចក្តីថា ម្នាលអ្នកដ៏មានអាយុ ព្រះសមណគោតមជាគ្រូរបស់លោកទាំងឡាយ ។

បទថា **អ្នកមានអាយុទាំងឡាយ សូម្បីពួកយើងក៏សម្តែងធម៌ដល់សាវកទាំងឡាយ យ៉ាងនេះ (មយំបិ ខោ អាវុសោ សាវកានំ ឯវំ ធម្មំ ទេសេម)** សេចក្តីថា ក្នុងលទ្ធិរបស់ពួកតិត្ថិយ មិនមានពាក្យនេះថា នីវរណៈ ៥ ពួកលោកគប្បីលះ ពោជ្ឈង្គៈ ៧ ពួកលោកគប្បីចម្រើន ចំណែកពួកតិត្ថិយទាំងនោះ ទៅកាន់អារាមឈរនៅក្រោយបរិស័ទ ស្តាប់ធម៌ទេសនារបស់ព្រះមានព្រះភាគជាម្ចាស់ ដូចជាសម្លឹងមើលវត្ថុដទៃ ដូចបញ្ជូនចិត្តទៅក្នុងទីដទៃ ។ តពីនោះក៏កំណត់ថា សមណគោតមនឹងពោលថា ពួកលោកចូរលះវត្ថុនេះ ចូរចម្រើនវត្ថុនេះចុះ ហើយទើបទៅកាន់អារាមរបស់ខ្លួន ឲ្យបាត់បែងអាសនៈទុកកណ្តាលអារាម ដែលឧបដ្ឋាកប្រុសស្រីចោមរោម ងើបសីសៈបង្អោនកាយចូលទៅ កាលសម្តែងអាការចាក់ធ្លុះដោយសម្មញ្ញាណរបស់ខ្លួន ទើបពោលថា អ្នកគួរលះនីវរណៈ ៥ គួរចម្រើន ពោជ្ឈង្គៈ ៧ ដូច្នេះ ។

ក្នុងបទថា **អ្នកមានអាយុទាំងឡាយ ក្នុងការសម្តែងធម៌របស់យើង**

អ្វីជាសេចក្តីប្លែកគ្នា (ឥធ នោ អាវុសោ កោ វិសេសោ) នេះ បទថា ឥធ ប្រែថា ក្នុងបញ្ញត្តិនេះ ។ បទថា កោ វិសេសោ គឺ អ្វីវិសេសជាងគ្នា ។ បទថា អ្វីជាប្រយោជន៍យ៉ាងក្រៃលែង (កោ អធិប្បាយសោ) គឺ អ្វីជាការព្យាយាម ជាគ្រឿងប្រកបដ៏ក្រៃលែង ។ បទថា អ្វីជាសេចក្តីផ្សេងគ្នា (កិន្នានាករណំ) គឺ អ្វីជាការផ្សេងគ្នា ។ បទថា ធម្មទេសនារបស់ពួកយើង ឬធម្មទេសនារបស់ព្រះគោតម (ធម្មទេសនាយ វា ធម្មទេសនំ) សេចក្តីថា ពួកអញ្ញតិរ្ថិយពោលប្រការដែលពួកគេ គប្បីប្រារព្ធធម្មទេសនារបស់ពួកយើង ជាមួយធម្មទេសនារបស់ព្រះសមណគោតម ឬធម្មទេសនារបស់ព្រះសមណគោតម ជាមួយធម្មទេសនារបស់ពួកយើង ហៅថា ការធ្វើឲ្យផ្សេងគ្នានោះ ឈ្មោះអ្វី? សូម្បីក្នុងបទទីពីរក៏ន័យនេះដូចគ្នា ។

[៥៤៨] បទថា មិនរីករាយ (នេវ អភិនន្ទឹសុ) បានដល់ ពួកភិក្ខុរមែងមិនទទួលថា យ៉ាងនេះ យ៉ាងនេះ ។ បទថា មិនហាមឃាត់ (នប្បដិក្កោសឹសុ) បានដល់ មិនជំទាស់ថា វត្ថុនេះមិនជាយ៉ាងនេះ ។ សួរថា ក៏ពួកភិក្ខុទាំងនោះ កាលបានធ្វើយ៉ាងនេះព្រមឬ ឬថាមិនព្រម ។ ឆ្លើយថា ព្រម ។ ភិក្ខុទាំងនោះ រមែងមិនអាចពោលពាក្យប្រមាណប៉ុណ្ណោះបានថា ម្នាលអ្នកមានអាយុ ក្នុងលទ្ធិរបស់លោកទាំងឡាយ មិនមាននីវរណៈ ៥ នឹង

ត្រូវលះ មិនមានពោជ្ឈង្គៈ ៧ នឹងត្រូវចម្រើន ដូច្នេះ ។ តែភិក្ខុទាំងនោះមានការត្រិះរិះយ៉ាងនេះថា ប្រការដែលគេនាំមកពោលនោះមិនមាន ពួកយើងនឹងទូលសូមសេចក្តីនោះចំពោះព្រះសាស្តា កាលបើដូច្នោះ ព្រះសាស្តានឹងសម្តែងព្រះធម្មទេសនាដ៏ពីរោះដល់ពួកយើង ដូច្នេះ ។

[៥៥១] បទថា **បរិយាយោ** ប្រែថា **ហេតុ** ។ បទថា **នឹងដោះស្រាយមិនបាន (ន ចេវ សម្បាយិស្សន្តិ)** សេចក្តីថា ពួកអញ្ញតិរ្ថិយនឹងមិនអាចពោលដោះស្រាយបានឡើយ ។ បទថា **សេចក្តីចង្អៀតចង្អល់ចិត្តក្រៃលែង (ឧត្តរិញ្ច វិឃាតំ)** សេចក្តីថា និងដល់សេចក្តីទុក្ខយ៉ាងក្រៃលែង ព្រោះដោះស្រាយមិនបាន ។ ពិតណាស់ ទុក្ខរមែងកើតឡើងដល់ពួកគេ អ្នកមិនអាចនឹងពោលដោះស្រាយបាន ។ បទថា **តំ** ក្នុងបទថា **យថា តំ ភិក្ខវេ អវិសយស្មឹ** នេះ ត្រឹមតែជានិបាត ។ បទថា **យថា** ប្រែថា ពាក្យជាហេតុ អធិប្បាយថា ព្រោះបញ្ហាដែលត្រូវសួរក្នុងឋានៈមិនមែនជាវិស័យ ។ បទថា **សទេវកេ** បានដល់ ក្នុងលោកព្រមទាំងទេវលោក និងទេវតាទាំងឡាយ ។ សូម្បីក្នុងបទថា **សមារកៈ** ជាដើម ក៏មានន័យនេះដូចគ្នា ។ លោកសម្តែងថា យើងសម្លឹងមើលមិនឃើញទេវតា ឬមនុស្សនោះក្នុងលោក ព្រមទាំងទេវលោកជាដើមដែលផ្សេងគ្នានោះ សំដៅដល់សត្វលោក សូម្បីដោយឋានៈ

៥ គឺ ពួកសត្វ ២ បន្ថែមឋាន: ៣ ក្នុងលោក ដោយអាការយ៉ាងនេះ ។ បទថា **ឬបុគ្គលដែលស្តាប់ពីព្រះតថាគត ឬពីសាវករបស់ព្រះតថាគតនោះ (ឥតោ វា បន សុត្វា)** បានដល់ ឬស្តាប់អំពីសាសនារបស់តថាគត ។ លោកសម្តែងថា ព្រោះថា ព្រះតថាគតក្តី សាវករបស់ព្រះតថាគតក្តី ស្តាប់ដោយអាការយ៉ាងនេះ គប្បីឲ្យត្រេកអរ គឺ ឲ្យពេញចិត្តបាន ។ ឈ្មោះថាសេចក្តីត្រេកអរនឹងមិនមានដោយប្រការដទៃ ។

[៥៥២] ព្រះដ៏មានព្រះភាគ កាលទ្រង់សម្តែងព្រះទ័យត្រេកអរដោយការដោះស្រាយបញ្ហាទាំងនោះរបស់ព្រះអង្គ ទើបត្រាស់ពាក្យថា **កតមោ ច ភិក្ខវេ បរិយាយោ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **កាមច្ឆន្ទៈក្នុងខាងក្នុង (អជ្ឈត្តំ កាមច្ឆន្ទោ)** បានដល់ ឆន្ទរាគៈកើតឡើង ព្រោះប្រារព្ធបញ្ចក្ខន្ធរបស់ខ្លួន ។ បទថា **កាម-ច្ឆន្ទៈក្នុងខាងក្រៅ (ពហិទ្ធា កាមច្ឆន្ទោ)** បានដល់ ឆន្ទរាគៈកើតឡើង ព្រោះប្រារព្ធបញ្ចក្ខន្ធរបស់បុគ្គលដទៃ ។ បទថា **រមែងមកកាន់ឧទ្ទេស (ឧទ្ទេសំ គច្ឆតិ)** គឺ រមែងដល់ការរាប់ ។

[៥៥៤] បទថា **ព្យាបាទក្នុងខាងក្នុង (អជ្ឈត្តំ ព្យាបាទោ)** បានដល់ បដិឃៈដែលកើតឡើងខាងក្នុងព្រោះអវយវៈ មានដៃ និងជើងជាដើមរបស់

ខ្លួន ។ បទថា **ព្យាបាទក្នុងខាងក្រៅ (ពហិទ្ធា ព្យាបាទោ)** បានដល់ បដិឃៈ ដែលកើតឡើង ព្រោះដៃ និងជើងទាំងនោះរបស់អ្នកដទៃ ។

[៥៥៧] បទថា **សូម្បីវិចិកិច្ឆាក្នុងធម៌ទាំងឡាយក្នុងខាងក្នុង (អជ្ឈត្តំ ធម្មេសុ វិចិកិច្ឆា)** បានដល់ ការសង្ស័យក្នុងខន្ធរបស់ខ្លួន ។ បទថា **សេចក្ដីសង្ស័យក្នុងធម៌ទាំងឡាយក្នុងខាងក្រៅ (ពហិទ្ធា ធម្មេសុ វិចិកិច្ឆា)** បានដល់ សេចក្ដីសង្ស័យក្នុងឋានៈ ៨ ក្នុងខាងក្រៅ ។

[៥៦០] បទថា **សតិក្នុងធម៌ដែលប្រព្រឹត្តទៅក្នុងខាងក្នុង (អជ្ឈត្តំ ធម្មេសុ សតិ)** សេចក្ដីថា កាលកំណត់សង្ខារទាំងឡាយក្នុងខាងក្នុង សតិក៏កើតឡើង ។ បទថា **សតិក្នុងធម៌ទាំងឡាយក្នុងខាងក្រៅ (ពហិទ្ធា ធម្មេសុ សតិ)** សេចក្ដីថា កាលកំណត់សង្ខារទាំងឡាយក្នុងខាងក្រៅ សតិក៏កើតឡើង ។ សូម្បីក្នុងធម្មវិចយសម្ពោជ្ឈង្គៈ ក៏មានន័យនេះដូចគ្នា ។

[៥៦២] បទថា **ដែលប្រព្រឹត្តទៅផ្លូវកាយ (កាយិកំ)** បានដល់ ការព្យាយាមកើតឡើងដល់អ្នកអធិដ្ឋានដើរចង្ក្រមណ៍ ។ បទថា **ដែលប្រព្រឹត្តទៅផ្លូវចិត្ត (ចេតសិកំ)** សេចក្ដីថា សេចក្ដីព្យាយាមដែលកើតឡើង វៀរការព្យាយាមផ្លូវកាយ យ៉ាងនេះថា យើងនឹងមិនទម្លាយភ្នែននេះ រហូតដល់ចិត្តរបស់យើងនឹងផុតចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ ។

[៥៦៤] បទថា **ការស្ងប់កាយ (កាយបស្សទ្ធិ)** បានដល់ ស្ងប់ការខ្វល់ខ្វាយនៃខន្ធ ៣ ។ បទថា **ការស្ងប់ចិត្ត (ចិត្តបស្សទ្ធិ)** បានដល់ ស្ងប់ការខ្វល់ខ្វាយនៃវិញ្ញាណក្ខន្ធ ។ ក្នុងឧបេក្ខាសម្ពោជ្ឈង្គៈ មានវិនិច្ឆ័យដូចសតិសម្ពោសជ្ឈង្គៈនោះឯង ។ ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគជាម្ចាស់ត្រាស់ពោជ្ឈង្គៈលាយគ្នា ។ ពោជ្ឈង្គៈទាំងនេះ គឺ សតិ វិចយៈ និងឧបេក្ខា ក្នុងធម៌ក្នុងខាងក្នុងទាំងនោះ ឈ្មោះថា លោកិយៈ ព្រោះមានខន្ធរបស់ខ្លួនជាអារម្មណ៍ សេចក្តីព្យាយាមផ្លូវកាយដែលមិនទាន់ដល់មគ្គ ក៏ដូច្នោះ ។ ក៏ព្រោះមិនមានវិតក្កៈ និងវិចារៈ បីតិ និងសមាធិ ជារូបាវចរៈក៏ពិត តែក្នុងរូបាវចរៈនឹងមិនបានពោជ្ឈង្គៈ ដូច្នោះ ក៏ជាលោកុត្តរៈនោះឯង ។ ព្រះថេរៈពួកណារមែងលើកសម្ពោជ្ឈង្គៈឡើងសម្តែងក្នុងព្រហ្មវិហារ និងក្នុងឈានដែលជាបាទនៃវិបស្សនាជាដើម តាមមតិរបស់ព្រះថេរៈទាំងនោះ ពោជ្ឈង្គៈក៏ជារូបាវចរៈខ្លះ អរូបាវចរៈខ្លះ ។ ក៏ក្នុងពោជ្ឈង្គៈ បីតិទាំងនោះ មិនមានក្នុងអរូបាវចរៈ ។ ពោជ្ឈង្គៈដ៏សេស ៦ ប្រការ ជាមិស្សកៈ ដោយប្រការដូច្នេះ ។ ក្នុងទីបំផុតនៃទេសនា ភិក្ខុពួកខ្លះជាសោតាបន្ន ពួកខ្លះជាសកទាគាមី ពួកខ្លះជាអនាគាមី ពួកខ្លះជាអរហន្ត ដោយប្រការដូច្នេះឯង ។

ចប់អដ្ឋកថា បរិយាយសូត្រទី ២

# អ ដ្ឋ ក ថា

## អគ្គិសូត្រទី ៣

[៥៦៨] គប្បីជ្រាបវិនិច្ឆ័យក្នុង អគ្គិសូត្រទី ៣ ។

[៥៧២] បទថា តថាគតត្រាស់ថា សតិមានប្រយោជន៍ក្នុងទីទាំងពួង (សតិញ្ច ខ្វាហំ ភិក្ខវេ សព្វត្ថិកំ វទាមិ) សេចក្តីថា តថាគតត្រាស់សតិថា ដូចក្រឡអំបិល និងដូចអាមាត្យអ្នកប្រកបការងារទាំងពួង ដែលបុគ្គលគប្បីប្រាថ្នាក្នុងទីទាំងពួង ។ ដូចជា ក្រឡអំបិលរមែងនៅ សូម្បីក្នុងបាយទាំងពួង យ៉ាងណា និងអាមាត្យអ្នកប្រកបការងារទាំងពួង រមែងធ្វើមុខនាទីច្បាំង ធ្វើមុខនាទីប្រឹក្សាខ្លះ ធ្វើមុខនាទីទំនុកបំរុងខ្លះ រួមសេចក្តីថា រមែងធ្វើកិច្ចគ្រប់យ៉ាងឲ្យសម្រេចបាន យ៉ាងណា ការគ្រប់សង្កត់ចិត្តដែលរាយមាយ ការលើកចិត្តដែលរួញរាក៏ដូច្នោះ ដូច្នោះ កិច្ចសូម្បីទាំងអស់ នឹងសម្រេចបានដោយសតិ វៀរសតិចេញ មិនអាចញុំាងកិច្ចនោះឲ្យសម្រេចបាន ព្រោះដូច្នោះ ព្រះអង្គទើបត្រាស់យ៉ាងនេះ ។ ក្នុងព្រះសូត្រនេះ ព្រះអង្គត្រាស់ពោជ្ឈង្គៈដែលជាវិបស្សនាចំណែកខាងដើមតែម្យ៉ាង ។

ចប់អដ្ឋកថា អគ្គិសូត្រទី ៣

# អ ដ្ឋ ក ថា

## មេត្តាសូត្រទី ៤

*គប្បីជ្រាបវិនិច្ឆ័យក្នុង មេត្តាសូត្រទី ៤ ។*

[៥៧៤] *បទថា* ***មានចិត្តប្រកបដោយមេត្តា (មេត្តាសហគតេន ចេ-តសា)*** *ជាដើមទាំងអស់ លោកឲ្យពិស្តារទុកក្នុងវិសុទ្ធមគ្គ ដោយអាការទាំងពួងហើយ ។*

[៥៧៨] *ពួកអញ្ញតិត្ថិយទាំងនោះ ស្តាប់ធម្មទេសនារបស់ព្រះសាស្តា ដោយន័យមុននោះឯង ទើបពោលបទសូម្បីនេះថា* ***អ្នកមានអាយុទាំងឡាយ សូម្បីពួកយើងក៏សម្តែងធម៌ដល់សាវកទាំងឡាយយ៉ាងនេះ (មយម្បិ ខោ អាវុសោ សាវកានំ ឯវំ ធម្មំ ទេសម)*** *ដូច្នេះ ។ ពិតណាស់ ក្នុងលទ្ធិរបស់ពួកតិត្ថិយ ការលះនិវរណៈ ៥ ឬការចម្រើនព្រហ្មវិហារ មានមេត្តាជាដើម រមែងមិនមាន ។*

[៥៩៤] *បទថា* ***មានអ្វីជាគតិ (កឹគតិកា ហោតិ)*** *គឺ មានអ្វីសម្រេច ។ បទថា* ***មានអ្វីដ៏ក្រៃលែង (កិម្បរមា)*** *គឺ អ្វីខ្ពស់បំផុត ។ បទថា* ***មានអ្វីជាផល (កិម្ផលា)*** *គឺ មានអ្វីជាអានិសង្ស ។ បទថា* ***មានអ្វីជាទីបំផុត (កិម្ប-***

វិយោសានា) គឺ មានអ្វីជាទីបញ្ចប់ ។

[៩៩៥] បទថា **ប្រកបដោយមេត្តា (មេត្តាសហគតំ)** បានដល់ សតិសម្ពោជ្ឈង្គៈដែលសម្បយុត្តដោយមេត្តា ។ ក្នុងបទទាំងពួងក៏ន័យនេះឯង ។ បទថា **ដែលអាស្រ័យវិវេក (វិវេកនិស្សិតា)** ជាដើម មានន័យដូចពោលហើយនោះឯង ។

បទថា **វត្ថុដែលមិនបដិកូល (អប្បដិកូលំ)** សេចក្ដីថា វត្ថុមិនបដិកូលមាន ២ យ៉ាង គឺ មិនបដិកូលក្នុងសត្វ និងមិនបដិកូលក្នុងសង្ខារ ។ អធិប្បាយថា ក្នុងវត្ថុដែលគួរប្រាថ្នាដែលមិនបដិកូលនោះ ។ បទថា **មានសេចក្ដីសម្គាល់ថា បដិកូលក្នុងវត្ថុមិនបដិកូល (បដិកូលសញ្ញី)** គឺ មានសេចក្ដីសម្គាល់ថា មិនគួរប្រាថ្នា ។

សួរថា ប្រការដែលលោកមានការសម្គាល់ថា បដិកូលក្នុងវត្ថុមិនបដិកូលនោះដូចម្ដេច ទើបនៅយ៉ាងនេះបាន?

ឆ្លើយថា លោកធ្វើការផ្សាយទៅថា មិនស្អាត ឬមនសិការថា មិនទៀង ទើបនៅយ៉ាងនេះបាន ។ ប្រការនោះ សមពិតដូចលោកពោលទុកក្នុងបដិសម្ភិទាថា លោកមានការសម្គាល់ថា បដិកូល ក្នុងវត្ថុមិនបដិកូលដូចម្ដេច លោករមែងផ្សាយទៅក្នុងវត្ថុដែលគួរប្រាថ្នាថា ជារបស់មិនស្អាត

ឬពិចារណាថាជារបស់មិនទៀង ។ តែកាលលោកធ្វើការផ្សាយមេត្តា ឬធ្វើទុកក្នុងចិត្តដល់ភាពជាធាតុ ក្នុងវត្ថុដែលជាបដិកូល មិនគួរប្រាថ្នា ឈ្មោះថា មានការសម្គាល់ថា មិនបដិកូល ។ ដូចដែលលោកពោលទុកថា បុគ្គលមានការសម្គាល់ថា មិនបដិកូលក្នុងវត្ថុបដិកូលដូចម្តេច លោកផ្សាយទៅក្នុងវត្ថុដែលមិនគួរប្រាថ្នាដោយមេត្តា ឬពិចារណាដោយភាពជាធាតុ ដូច្នេះ ។ សូម្បីក្នុងបទដែលលាយគ្នាទាំងពីរ ក៏មានន័យនេះដូចគ្នា ។ ក៏លោកពេលធ្វើការផ្សាយទៅថា មិនស្អាត ឬមនសិការថា មិនទៀងនោះៗ ឯង ទាំងក្នុងវត្ថុមិនបដិកូល និងបដិកូល ឈ្មោះថា មានការសម្គាល់ថា បដិកូលហើយ ។ ក៏លោកធ្វើការផ្សាយមេត្តា ឬធ្វើទុកក្នុងចិត្តដល់ភាពជាធាតុនោះៗ ឯង ទាំងក្នុងវត្ថុបដិកូល និងមិនបដិកូល ឈ្មោះថា មានការសម្គាល់ថា មិនបដិកូលនោះឯង ។ តែកាលញុំាងឆឡង្គុបេក្ខា ដែលលោកពោលទុកដោយន័យជាដើមថា ភ្នែកឃើញរូប មិនត្រេកអរ ដូច្នេះ ឲ្យប្រព្រឹត្តទៅគប្បីជ្រាបថា លោកចែកវត្ថុទាំងពីរនោះ ក្នុងវត្ថុមិនបដិកូល ឬវត្ថុបដិកូលចេញ ហើយព្រងើយ មានសតិសម្បជញ្ញៈនៅក្នុងវត្ថុទាំងពីរនោះ ។

ក៏ទេសនា គប្បីចែកចេញពីគ្នា ព្រោះមគ្គពោជ្ឈង្គៈ និងអរិយិទ្ធិជាមួយវិបស្សនា ទ្រង់សម្តែងដល់ភិក្ខុនេះដែលញុំាងឈានពួក ៣ ឬឈាន

ពួក ៤ ឲ្យកើតដោយមេត្តា ធ្វើឈាននោះឯងឲ្យជាបាទ ចម្រើនវិបស្សនា សម្រេចព្រះអរហត្ត ដោយពាក្យមានប្រមាណប៉ុណ្ណេះ ។ ចំណែកភិក្ខុណា ធ្វើមេត្តាឈាននេះឲ្យជាបាទហើយ សូម្បីពិចារណាសង្ខារទាំងឡាយ នៅមិនអាចនឹងសម្រេចព្រះអរហត្តបាន ព្រោះមេត្តា មានព្រះអរហត្តដ៏យ៉ាងក្រៃលែងមិនមានដល់ភិក្ខុនោះ ។ តែគប្បីសម្ដែងប្រការដែលមេត្តា មានព្រះអរហត្តដ៏យ៉ាងក្រៃលែងនោះ ។ ដូច្នោះ ទ្រង់ផ្ដើមទេសនានេះ ដើម្បីសម្ដែងសេចក្ដីនោះ ។

[៥៩៦] សូម្បីក្នុងបទជាដើមថា **ព្រោះកន្លងរូបសញ្ញាដោយប្រការទាំងពួង (សព្វសោ វា បន រូបសញ្ញានំ សមតិក្កមា)** គប្បីជ្រាបដល់ប្រយោជន៍ ក្នុងការចាប់ផ្ដើមទេសនាដោយន័យនេះតទៅទៀត ។

បទថា **មានសុភវិមោក្ខដ៏យ៉ាងក្រៃលែង (សុភបរមំ)** សេចក្ដីថា មានសេចក្ដីស្អាតជាទីបំផុត មានសេចក្ដីស្អាតជាបរិយោសាន មានសេចក្ដីស្អាតសម្រេច ។ បទថា **បញ្ញារបស់លោកក្នុងធម្មវិន័យនេះ (ឥធ សញ្ញស្ស)** សេចក្ដីថា បញ្ញារបស់លោកក្នុងធម្មវិន័យនេះ បញ្ញាក្នុងទីនេះ នៅកន្លងលោកនេះមិនបាន ។ អធិប្បាយថា បញ្ញានោះ ជាលោកិយប្បញ្ញា ។ បទថា **មិនទាន់ចាក់ធ្លុះវិមុត្តិដ៏ប្រសើរ (ឧត្តរិវិមុត្តិំ អប្បដិវិជ្ឈតោ)** សេចក្ដីថា នៅ

មិនទាន់ចាក់ធ្លុះលោកុត្តរធម៌ ។ អធិប្បាយថា ចំណែកភិក្ខុណាអាចចាក់ធ្លុះបាន ភិក្ខុនោះបានមេត្តា មានអរហត្តជាយ៉ាងក្រៃលែង ។ សូម្បីក្នុងបទថា ករុណាជាដើម ក៏មានន័យនេះដូចគ្នា ។

សួរថា ក៏ព្រោះហេតុអ្វី ? ព្រះមានព្រះភាគជាម្ចាស់ ទើបត្រាស់ធម៌មានសេចក្តីស្អាតដ៏យ៉ាងក្រៃលែងជាដើម នៃធម៌ មានមេត្តាជាដើមទាំងនោះ ។ ឆ្លើយថា ព្រោះធម៌នោះ ជាឧបនិស្ស័យរបស់ភិក្ខុនោះៗ ដោយអំណាចជាធម៌មានចំណែកស្មើគ្នា ។ ពិតណាស់ ពួកសត្វមិនជាវត្ថុបដិកូលសម្រាប់ភិក្ខុអ្នកនៅដោយមេត្តា ។ លំដាប់នោះ កាលលោកនាំចិត្តចូលទៅក្នុងពណ៌ខៀវជាដើម ដែលជាពណ៌បរិសុទ្ធ មិនបដិកូល ចិត្តរមែងស្ទុះទៅក្នុងវត្ថុដែលមិនជាបដិកូលនោះដោយមិនលំបាក មេត្តាជាឧបនិស្សយប្បច្ច័យនៃសុភវិមោក្ខ ដោយអាការយ៉ាងនេះ រកឲ្យក្រៃលែងជាងនោះមិនមាន ព្រោះដូច្នោះ ទើបត្រាស់ថា **សុភបរមា** ដូច្នេះឯង ។

ភិក្ខុអ្នកនៅដោយករុណា ពិចារណាឃើញទុក្ខរបស់សត្វ មានការត្រូវបៀតបៀនដ៏ខ្លាំងក្លាជាដើម ជាគ្រឿងសម្គាល់នៃរូប ។ ទោសក្នុងរូបទើបជាការសម្តែង ព្រោះការប្រព្រឹត្តទៅ និងការកើតនៃករុណា ។ លំដាប់នោះ កាលលោកបើកកសិណក្នុងបណ្តាកសិណ ៤ មានបឋវីកសិណជាដើម

កសិណយ៉ាងណាមួយបានហើយ ព្រោះទោសនៃរូប (ដែលភិក្ខុនោះ) បានដឹងអស់ហើយ នាំចិត្តចូលទៅក្នុងអាកាសជាទីស្ងាត់ចាករូប ចិត្តរមែងស្ទុះទៅក្នុងកសិណនោះដោយមិនលំបាក ។ ករុណា ជាឧបនិស្សយប្បច្ច័យដល់អាកាសានញ្ចាយតនៈ ដោយអាការៈយ៉ាងនេះ រកក្រៃលែងជាងនោះមិនមាន ព្រោះដូច្នោះ ទើបត្រាស់ថា **អាកាសានញ្ចាយតនបរមា** ដូច្នេះ ។

ចំណែកភិក្ខុអ្នកនៅដោយមុទិតា ពិចារណាឃើញសេចក្តីសុខរបស់ពួកសត្វមានបាមោជ្ជៈកើតឡើង ដោយធ្វើបាមោជ្ជៈនោះ សេចក្តីគិតក្នុងការកាន់យក គឺ សេចក្តីសុខទីងមាន ព្រោះការប្រព្រឹត្តទៅ និងការកើតនៃមុតិតា ។ លំដាប់នោះ កាលលោកនាំចិត្តចូលទៅក្នុងវិញ្ញាណ កន្លងអាកាសានញ្ចាយតនៈដែលបានហើយតាមលំដាប់ តែនៅមានអាកាសនិមិត្តជាអារម្មណ៍ ចិត្តរមែងស្ទុះទៅក្នុងអាកាសនិមិត្តនោះ ដោយមិនលំបាក មុទិតាជាឧបនិស្សយប្បច្ច័យដល់វិញ្ញានញ្ចាយតនៈ ដោយអាការយ៉ាងនោះ រកក្រៃលែងជាងនោះមិនមាន ។ ព្រោះដូច្នោះ ទើបត្រាស់ថា **វិញ្ញានញ្ចាយ-តនបរមា** ដូច្នេះ ។

ចំណែកភិក្ខុអ្នកនៅដោយឧបេក្ខា មានចិត្តលំបាកដោយការប្រកាន់វត្ថុទីមិនមាន ព្រោះមិនមានការព្រួយបារម្មណ៍ថា សូមសត្វទាំងឡាយចូរ

មានសុខចុះ ឬចូរផុតទុកចុះ ឬថា ចូរកុំព្រាត់ប្រាសចាកសុខដែលបានហើយចុះ ដូច្នេះ ព្រោះមានមុខឆ្ពោះទៅកាន់បរមត្ថ ចាកសុខ និងទុក្ខជាដើម ។ លំដាប់នោះ កាលលោកនាំចិត្តចូលទៅក្នុងការមិនមាននៃវិញ្ញាណ ជាបរមត្ថដែលមិនមាន ព្រោះកើតកន្លងវិញ្ញានញ្ចាយតនៈដែលបានហើយតាមលំដាប់របស់ចិត្ត ដែលលំបាក ព្រោះប្រកាន់វត្ថុដែលមិនមានដោយបរមត្ថរបស់ចិត្តដែលមិនជាប់ជំពាក់ ឆ្ពោះមុខប្រកាន់បរមត្ថ ចិត្តរមែងស្ទុះទៅក្នុងវិញ្ញា-ណញ្ចាយតនៈនោះដោយមិនលំបាក ឧបេក្ខា ជាឧបនិស្សយប្បច្ច័យដល់អាកិញ្ចាយតនៈដោយអាការយ៉ាងនេះ រកក្រៃលែងជាងនោះមិនមាន ព្រោះដូច្នោះ ទើបត្រាស់ថា **អាកិញ្ចញ្ញាយតនបរមា** ដូចពោលមកដោយប្រការដូច្នេះ ។

ក្នុងទីបំផុតនៃទេសនា ពួកភិក្ខុ ៥០០ រូប សម្រេចព្រះអរហត្ត ។

ចប់អដ្ឋកថា មេត្តាសូត្រទី ៤

# អដ្ឋកថា

## សគារវសូត្រទី ៥

គប្បីជ្រាបវិនិច្ឆ័យក្នុង សគារវសូត្រទី ៥ ។

[៥៩៩] បទថា បគេវ ប្រែថា មួយរំពេច ។

[៦០០] បទថា រាយមាយដោយកាមរាគៈ (កាមរាគបរិយុដ្ឋិតេន) បានដល់ ដែលកាមរាគៈរួបរឹតទុក ។ បទថា ដែលកាមគ្របសង្កត់ទុក (កាមរាគបរេតេន) បានដល់ ទៅតាមកាមរាគៈ ។ បទថា ជាគ្រឿងរលាស់ចេញ (និស្សរណំ) សេចក្ដីថា ឧបាយជាគ្រឿងរលាស់ចេញនូវកាមរាគៈ មាន ៣ យ៉ាង គឺ វិក្ខម្ភននិស្សរណៈ (រលាស់ចេញដោយការគ្របសង្កត់) តទង្គនិស្សរណៈ (រលាស់ចេញដោយខណៈ) សមុច្ឆេទនិស្សរណៈ (រលាស់ចេញបានដាច់ខាត) ។ ក្នុងឧបាយគ្រឿងរលាស់ចេញ ៣ យ៉ាងនេះ បឋមជ្ឈានក្នុងអសុភៈ ឈ្មោះថា រលាស់ចេញដោយការគ្របសង្កត់ទុក ។ វិបស្សនា ឈ្មោះថា រលាស់ចេញដោយខណៈ ។ អរហត្តមគ្គ រលាស់ចេញដោយសមុច្ឆេទ ។ អធិប្បាយថា គេរមែងមិនដឹងឧបាយជាគ្រឿងរលាស់ចេញសូម្បី ៣ យ៉ាងនោះ ។ ក្នុងបទថា ប្រយោជន៍ខ្លួន (អត្តត្ថម្បីតិ) ជា

ដើម ប្រយោជន៍ខ្លួន ពោលគឺ អរហត្ត ឈ្មោះថា ប្រយោជន៍របស់ខ្លួន ។ ប្រយោជន៍របស់អ្នកថ្វាយបច្ច័យទាំងឡាយ ឈ្មោះថា ប្រយោជន៍របស់អ្នកដទៃ ។ ប្រយោជន៍សូម្បីពីរយ៉ាងនោះឯង ឈ្មោះថា ប្រយោជន៍ទាំងពីរ ក្នុងវារៈ ទាំងពួង គប្បីជ្រាបខ្លឹមសារដោយន័យនេះ ។

[៦០២] ចំណែកការផ្សេងគ្នាដូច្នេះ ក៏ក្នុងបទថា **ការរលាស់ចេញពីព្យាបាទ** (ព្យាបាទស្ស និស្សរណំ) ជាដើម មានឧបាយជាគ្រឿងរលាស់ចេញពីរយ៉ាង គឺ វិក្ខម្ភននិស្សរណៈ និងសមុច្ឆេទនិស្សរណៈ ក្នុងឧបាយទាំង ២ នោះ **បឋមជ្ឈានក្នុងមេត្តា** រលាស់ព្យាបាទចេញបាន ដោយការគ្របសង្កត់ ។ **អនាគាមិមគ្គ** រលាស់ព្យាបាទចេញបានដោយសមុច្ឆេទ ។ **អាលោកសញ្ញា** រលាស់ថីនមិទ្ធៈចេញបានដោយការគ្របសង្កត់ ។ **អរហត្ត-មគ្គ** រលាស់ចេញបានសមុច្ឆេទ ។ **សមថកម្មដ្ឋានណាមួយ** រលាស់ឧទ្ធច្ច-កុក្កុច្ចៈចេញបានដោយការគ្របសង្កត់ ចំណែកក្នុងឧទ្ធច្ចកុក្កុច្ចៈនេះ **អរហត្តមគ្គ** ជាគ្រឿងរលាស់ឧទ្ធច្ចៈចេញបានដោយសមុច្ឆេទ ។ **អនាគាមិមគ្គ** ជាគ្រឿងរលាស់កុក្កុច្ចៈចេញបានដោយសមុច្ឆេទ ។ **ការកំណត់ធម៌** ជាគ្រឿងរលាស់ចេញចាកវិចិកិច្ឆាបានដោយការគ្របសង្កត់ ។ **បឋមមគ្គ** ជាគ្រឿងរលាស់ចេញបានសមុច្ឆេទ ។

[៦០៣] ចំណែកក្នុងប្រការនេះ ព្រះមានព្រះភាគជាម្ចាស់ត្រាស់ឧបមា មានបទថា ប្រៀបដូចភាជនៈដាក់ទឹកលាយដោយពណ៌អាចម៍ល័ក្ខ (សេយ្យថាបិ ព្រាហ្មណ ឧទបត្តោ សំសដ្ឋោ លាខាយ វា) ជាដើមណា ក្នុងឧបមាទាំងនោះ បទថា ភាជនៈដាក់ទឹក (ឧទបត្តោ) បានដល់ ភាជនៈពេញដោយទឹក ។ បទថា លាយ (សំសដ្ឋោ) បានដល់ លាយដោយអំណាចធ្វើពណ៌ឲ្យផ្សេងគ្នា ។ បទថា កើតចំហាយ (ឧស្មាទកជាតោ) គឺ មានចំហាយទឹកហុយឡើង ។

[៦០៥] បទថា សារាយ និងចកត្រៀបត្រាជុំជិត (សេវាលបណកបរិយោនទ្ធោ) សេចក្ដីថា ដែលសារាយ និងពូជល្ងជាដើម ឬកូនចក មានស្លឹកពណ៌ខៀវកើតឡើងត្រៀបត្រាគ្របលើទឹក ។

[៦០៧] បទថា ដែលខ្យល់បក់ត្រូវ (វាតេរិតោ) បានដល់ ត្រូវខ្យល់បក់ឲ្យកម្រើក ។

[៦០៩] បទថា ល្អក់ (អាវិលោ) គឺ មិនថ្លា ។ បទថា កករ (លុឡិតោ) គឺ មិនស្ងៀម ។ បទថា ជាកណ្ដាប់ (កលលីភូតោ) គឺ កក់ល្បាប់ ។ បទថា បុគ្គលទុកក្នុងទីងងឹត (អន្ធការេ និក្ខិត្តោ) បានដល់ ដែលបុគ្គលតម្កល់ទុកក្នុងទីមិនភ្លឺ មានចន្លោះជង្រុកស្រូវជាដើមជាប្រភេទ ។

ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រឡប់ទេសនាពីកពទាំង ៣ ហើយទ្រង់បញ្ចប់ទេសនាដោយធម៌ដ៏ជាកំពូល គឺ អរហត្ត ។ ចំណែកព្រាហ្មណ៍ តាំងនៅហើយក្នុងផ្លូវដែលស្ងប់[១] ។

ចប់អដ្ឋកថា សគារវសូត្រទី ៥

---

១-សមណាគ្គេ ច្បាប់ភូមាជា សរណាបគ្គេ ប្រែថា គុណាដល់ត្រឹមសរណៈ ។

# អ ដ្ឋ ក ថា

## អភយសូត្រទី ៦

គប្បីជ្រាបវិនិច្ឆ័យក្នុង អដ្ឋកថាអភយសូត្រទី ៦ ។

[៦២៧] បទថា **អញ្ញាណាយ អទស្សនាយ** បានដល់ ដើម្បីការមិនដឹង ដើម្បីការមិនឃើញ ។

[៦៣៣] បទថា **និវរណៈជាយ៉ាងនេះ (តត្ថ ភគវា នីវរណា)** បានដល់ បពិត្រព្រះមានព្រះភាគ (ធម៌ទាំងនោះជា) និវរណៈតែម្យ៉ាង ។

[៦៣៧] បទថា **ការលំបាកកាយ (កាយកិលមថោ)** គឺ ការសោប់សេល់ផ្លូវកាយ ។ បទថា **ការលំបាកចិត្ត (ចិត្តកិលមថោ)** គឺ ការសោប់សេល់ផ្លូវចិត្ត ។ បទថា **សូម្បីសេចក្តីលំបាកនោះរបស់ខ្ញុំព្រះអង្គ ក៏ស្ងប់រម្ងាប់ទៅ (សោបិ មេ បដិប្បស្សទ្ធោ)** សេចក្តីថា បានឮថា សេចក្តីសោប់សេល់កាយរបស់ព្រះរាជកុមារនោះ ដែលចូលទៅកាន់ទីសប្បាយនៃវដ្តក៏ត្រជាក់អន្តុយក្នុងសម្នាក់របស់ព្រះសាស្តាក៏ស្ងប់រម្ងាប់ហើយ ។ កាលបើកាយនោះស្ងប់ សូម្បីសេចក្តីសោប់សេល់ផ្លូវចិត្តក៏ស្ងប់ ព្រោះបណ្តាយតាមកាយនោះឯង ។ ម្យ៉ាងទៀត សេចក្តីសោប់សេល់ផ្លូវកាយ និងចិត្ត សូម្បីទាំងពីរ

*នោះ គប្បីជ្រាបថា ស្ងប់រម្ងាប់ហើយដោយមគ្គនោះឯង ។*

ចប់អដ្ឋកថា អភយសូត្រទី ៦

## ចប់ពួក ៦ នៃពោជ្ឈង្គៈ

## រួមអដ្ឋកថាក្នុងវគ្គនេះ គឺ

| | |
|---|---|
| ១ អដ្ឋកថា អាហារសូត្រ | ២ អដ្ឋកថា បរិយាយសូត្រ |
| ៣ អដ្ឋកថា អគ្គិសូត្រ | ៤ អដ្ឋកថា មេត្តាសូត្រ |
| ៥ អដ្ឋកថា សគារវសូត្រ | ៦ អដ្ឋកថា អភយសូត្រ |

# អានាបានវគ្គទី ៧[១]

## អ ដ្ឋ ក ថា

### អដ្ឋិកសញ្ញា

*គប្បីជ្រាបវិនិច្ឆ័យក្នុងអដ្ឋិកសញ្ញា ក្នុងអានាបានវគ្គទី ៧ ជា ដើម ៖*

*[៦៣៨] បទថា* ***អដ្ឋិកសញ្ញា*** *បានដល់ សញ្ញាដែលកើតឡើងដល់ភិក្ខុអ្នកចម្រើនហើយថា ឆ្អឹង ឆ្អឹង ដូច្នេះ ។ ក៏កាលចម្រើនអដ្ឋិកសញ្ញានោះហើយ ពណ៌សម្បុរក្តី ស្បែកក្តី រមែងប្រាកដរហូតវេលាដែលនិមិត្តនៅមិនទាន់កើតឡើង កាលនិមិត្តកើតឡើង ពណ៌សម្បុរ និងស្បែក រមែងមិនប្រាកដឡើយ ។ ម្យ៉ាងទៀត គ្រោងឆ្អឹងសុទ្ធតែមានពណ៌ដូចស័ង្ខ រមែងប្រាកដ ដូចប្រាកដដល់សាមណេរដែលក្រឡេកមើលព្រះបាទតិស្សៈ ដែលទ្រទ្រង់ធម៌ជិះលើ.កដំរី និងដល់ព្រះតិស្សត្ថេរដែលនៅឯចេតិយបព៌ត ដែលក្រឡេកមើលស្ត្រីកំពុងសើចក្នុងរវាងផ្លូវ ។ រឿងទាំងឡាយ អធិប្បាយឲ្យពិស្តារទុកហើយក្នុងវិសុទ្ធិមគ្គ ។*

---

*១-អដ្ឋកថា ជាវគ្គទី ៧ ។*

[៦៣៩] *បទថា ឬនៅមានសល់សេចក្ដីប្រកាន់ (សតិ វា ឧបាទិ-សេស) សេចក្ដីថា នៅមានសេចក្ដីប្រកាន់ គឺថា សេចក្ដីប្រកាន់នៅសល់ ។*

ចប់អដ្ឋកថា អដ្ឋិកសញ្ញាទី ១

# អ ដ្ឋ ក ថា

## បុឡុវកសញ្ញា

[៦៤៤] *បទថា* ***បុឡុវកសញ្ញា*** *បានដល់ សញ្ញាដែលកើតឡើងដល់ភិក្ខុអ្នកចម្រើនហើយថា មានដង្កូវ ។ សូម្បីក្នុងបទថា* ***វិនីលកសញ្ញា*** *ជាដើម ក៏ន័យដូចគ្នា ។ ចំណែកក្នុងសេចក្ដីនេះ រឿងវិនិច្ឆ័យពោលទុកក្នុងវិសុទ្ធិមគ្គ ជាមួយការនាន័យ ។ ព្រហ្មវិហារ មានមេត្តាជាដើម គប្បីជ្រាបដោយអំណាចឈានពួក ៣-៤ ។ ឧបេក្ខា (គប្បីជ្រាប) ដោយអំណាចឈានទី ៤ នោះឯង ។*

ចប់អដ្ឋកថា បុឡុវកសញ្ញាទី២

# អ ដ្ឋ ក ថា

## អសុភសញ្ញាជាដើម

[៦៥៣] បទថា *អសុភសញ្ញា* បានដល់ បឋមជ្ឈានសញ្ញាក្នុងអសុភៈ ។

[៦៥៤] បទថា *មរណសញ្ញា* សេចក្តីថា សញ្ញាដែលកើតឡើងដល់អ្នកពិចារណារឿយៗ ថា យើងត្រូវស្លាប់ពិត ជីវិតរបស់យើងជាប់ដោយសេចក្តីស្លាប់ ។

[៦៥៥] បទថា *អាហារេ បដិកូលសញ្ញា* សេចក្តីថា ក្នុងបាយ និងនំស្រស់ជាដើម ជាបដិកូលសញ្ញា ចំពោះអ្នកទំពារស៊ីប៉ុណ្ណោះ ។

[៦៥៦] បទថា *សព្វលោកេ អនភិរតសញ្ញា* បានដល់ សញ្ញាដែលកើតឡើងដល់ភិក្ខុអ្នកមិនញ៉ាំងសេចក្តីត្រេកអរឲ្យកើតឡើងក្នុងលោកទាំងអស់ ។ បុព្វភាគ ២ គឺ បហានសញ្ញា វិរាគសញ្ញា ។ និរោធសញ្ញា លាយគ្នា ។ លោកសម្តែងកម្មដ្ឋានទាំង ២០ នោះ ៩ ជាអប្បនា ១១ ជាឧបចារៈឈាន[១] ។ ចំណែកសេចក្តីនេះ រឿងវិនិច្ឆ័យដ៏សេស មានហើយក្នុងវិសុទ្ធិ-

---

១-បាឋៈថា តេសំ នវសុ អប្បនា ហោន្តិ, ឯកាទសក ឧបចារជ្ឈានិកានិ (ដូចប្រែខាងលើ) ដីកា កែថា ឯកាទសសុ អប្បនា ហោតិ, នវ ឧបចារជ្ឈានិកា ប្រែថា ជាអប្បនា ១១ ជាឧបចារៈ ៩ ។

មគ្គនោះឯង ។

គង្គាបេយ្យាលជាដើម គប្បីជ្រាបដោយន័យដូចពោលហើយក្នុង

មគ្គសំយុត្តនោះចុះ ។

ចប់អដ្ឋកថា អសុភសញ្ញា

**ចប់អានាបានាទិបេយ្យាលទី ៧**

**រួមអដ្ឋកថាក្នុងវគ្គនេះ គឺ**

១ អដ្ឋកថា អដ្ឋិកសញ្ញា ២ អដ្ឋកថា បុឡុវកសញ្ញា

៣ អដ្ឋកថា អសុភសញ្ញាជាដើម

# ចប់ពោជ្ឈង្គសំយុត្ត

# ចប់

# អដ្ឋកថាសំយុត្តនិកាយ

# មហាវារវគ្គ

# នវមភាគ

# ភាគ ៣៧

# រាយនាមសប្បុរសជន
# ចូលរួមកសាងគម្ពីរអដ្ឋកថា

| | |
|---|---|
| លោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស | $ 1.000 US |
| ភិក្ខុធម្មប្បញ្ញោ ជុំ សារឿន វត្តពន្លឺពុទ្ធចក្រ<br>នៅរដ្ឋមាសាជូសេត សហរដ្ឋអាមេរិក | $ 300 US |
| -ឧបាសក តាំង សុផល ឧបាសិកា ឡុង កេង<br>ព្រមទាំងបុត្ត និងចៅ | $ 70 US |
| -ឧបាសក វ៉ាន់ ស៊ីមវ៉ា ឧបាសិកា តាំង សានីតា<br>ព្រមទាំងបុត្ត | $ 30 US |
| -កុមារី តាំង សុមាវតី | $ 10 US |


ព្រះរាជាណាចក្រកម្ពុជា